ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Oct-2013, 12:03
CMS/CFO: Krystal THOMPSON

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី២១៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន
*(Mr.Nicholas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក ពេជ សម្បត្តិ

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឃីត រេយ៍ន័រ*(Mr. Keith RAYNOR)*

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JAQUIN)*

លោកស្រី បេនី យេ *(Ms. Beini YE)*

លោក អូលីវីយ៉េ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីនិងសាធារណជនកាលពីម្សិលមិញ នៅថ្ងៃនេះអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី ដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការនេះតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់នូវសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១។ សូមអញ្ជើញ!

[០៩:០៤:៣១]

*(មានបញ្ហាបច្ចេកទេស)*

[០៩:០៥:០២]

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេស មានបញ្ហាឧបករណ៍មីក្រូហ្វូនអត់ដំណើរការ!

*(មានបញ្ហាបច្ចេកទេស)*

*(សវនាការសម្រាកពីម៉ោង ០៩:១៣នាទី ដល់ម៉ោង ០៩:៥២នាទី)*

[០៩:៥២:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅលោកជំទាវសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭកដល់ភាគីនៃរឿងក្តី ដែលត្រូវនឹងឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល គឺអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ តាមរយៈអ៊ីម៉ែលកាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ កន្លងទៅនេះ គឺគ្រប់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានមកផ្តល់សក្ខីកម្មរួចហើយនៅក្នុងសវនាការចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ភាគីអាចប្រើប្រាស់ឈ្មោះរបស់ពួកគាត់នៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នេះបាន។ ប៉ុន្តែចំពោះបុគ្គលដទៃទៀតដែលមិនទាន់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឬបុគ្គលណាដែលអាចតម្រូវមកផ្តល់សក្ខីកម្មនៅសវនាការនាពេលខាងមុខ ភាគីត្រូវប្រើប្រាស់តែរហស្សនាមពួកគេតែប៉ុណ្ណោះ។

បាទ សូមប្រគល់វេទិកាជូនទៅលោកជំទាវសហព្រះរាជអាជ្ញាជាតិ។ សូមអញ្ជើញ!

[០៩:៥៤:០៨]

**លោកស្រី ជា លាង៖**

ជាបឋមសូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។ នៅពេលនេះខ្ញុំ និងសហការីរបស់ខ្ញុំ គឺលោក វីណ្ស៊ៀម ស្មីត នឹងធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលសម្រាប់កិច្ចពិភាក្សាដេញដោលសម្រាប់សំណុំរឿង០០២/០១នេះ។

ក្នុងអំឡុងពេលដែលយើងខ្ញុំកំពុងធ្វើសេចក្តីសន្និដ្ឋាននេះ យើងខ្ញុំនឹងដាក់បញ្ចាំងនៅលើអេក្រង់នូវអត្ថបទជាលាយលក្ខណ៍អក្សរ ជារូបភាព និងជាខ្សែវីដេអូខ្លីៗជាមួយផងដែរ។ ការជំនុំជម្រះក្តីនេះពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា និង ខៀវ សំផន ចំពោះបទឧក្រិដ្ឋដែលធ្វើឱ្យមនុស្សទូទាំងសកលលោកភិតភ័យ តក់ស្លុត។ នៅក្នុងរយៈពេលបីថ្ងៃខាងមុខនេះ ខ្ញុំនិងសហការីរបស់ខ្ញុំនឹងបង្ហាញភស្តុតាងក្នុងសំណុំរឿងនេះ ដើម្បីបញ្ជាក់ថា នួន ជា និង ខៀវ សំផន សុទ្ធតែបានដើរតួនាទីសំខាន់ និងពិសេសរៀងៗខ្លួន ក្នុងអង្គការឧក្រិដ្ឋមួយដែលបានធ្វើទុក្ខបុកម្នេញ ធ្វើទារុណកម្ម និងសម្លាប់

ប្រជាជនឯងរាប់លាននាក់ ដែលសុទ្ធតែជាជនស៊ីវិលស្លូតត្រង់ និងស្ត្រី កុមារ មនុស្សចាស់ និងអ្នកទន់ខ្សោយ និងងាយរងគ្រោះ។

[០៩:៥៥:៤៦]

សូម្បីតែមកដល់ពេលបច្ចុប្បន្ននេះ ក៏ក្រុមគ្រួសារខ្មែររាប់មិនអស់កំពុងតែរែកពន់នូវអម្រែកមួយដ៏ធ្ងន់ ដែលបន្សល់ទុកពីរបបខ្មែរក្រហម។ អម្រែកដ៏ធ្ងន់នេះ បានផ្ទុកទៅដោយអនុស្សាវរីយ៍នៃការធ្វើបាបការអត់បាយ និងការធ្វើទារុណកម្ម ការបាត់បង់អ្នកជាទីស្រលាញ់ ដែលពួកខ្មែរក្រហមបានសម្លាប់ ឬបាត់ខ្លួន។ ប្រជាជាតិខ្មែរទាំងមូលនៅតែរងទុក្ខខ្លោចផ្សាដោយសារការបាត់បង់ឱកាសសិក្សា និងការអភិវឌ្ឍ។ ប្រជាជនខ្មែរមួយជំនាន់ ដែលជាអ្នកបានរៀនសូត្រចេះដឹង និងមានជំនាញខ្ពស់ស្ទើរតែទាំងអស់ ត្រូវបានគេបោសសម្អាត សម្លាប់ចោល ឬបង្ខំឲ្យភៀសខ្លួនចេញពីប្រទេសកម្ពុជា ផលប៉ះពាល់នេះកំពុងតែបន្តមាននៅឡើយរហូតមកដល់បច្ចុប្បន្ននេះ។ ការជំនុំជម្រះក្តីនេះមានសារៈសំខាន់ចំពោះប្រទេសកម្ពុជាណាស់ ប៉ុន្តែវាមិនមែនសំខាន់សម្រាប់តែប្រទេសកម្ពុជាមួយប៉ុណ្ណោះទេ វាសំខាន់សម្រាប់ពិភពលោកទាំងមូលផងដែរ។ ការជំនុំជម្រះក្តីនេះបង្ហាញឲ្យឃើញថា បទឧក្រិដ្ឋដែលមានលក្ខណៈធំធេង និងធ្ងន់ធ្ងរដូច្នេះ គេនឹងមិនអាចបំភ្លេចវាបាន។ ចំណែកឯអ្នកដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះត្រូវតែនាំមកផ្តន្ទាទោស។ រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ បានរួមគ្នាបង្កើតតុលាការនេះឡើងក្នុងគោលបំណងធ្វើឲ្យយុត្តិធម៌មានពន្លឺជីវិត និងធ្វើឲ្យជីវិតមានពន្លឺយុត្តិធម៌ ព្រមទាំងស្វែងរកយុត្តិធម៌សមស្រប និងអាចទទួលយកបានសម្រាប់មនុស្សគ្រប់ៗគ្នាផងដែរ។

ជាការពិតណាស់ តាមដីកាបំបែកដំណើរការនីតិវិធី លោក លោកស្រីចៅក្រម និងសម្រេចអំពីពិរុទ្ធភាព ឬភាពគ្មានទោសពៃរ៍របស់ជនជាប់ចោទនៅក្នុងដំណាក់កាលទី១នៃការជំនុំជម្រះក្តីនេះ ដោយមើលតែមួយផ្នែកនៃបទឧក្រិដ្ឋដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបទឧក្រិដ្ឋមួយចំនួនទៀតនៃរបបនោះសិនតែប៉ុណ្ណោះ។

[០៩:៥៨:១៥]

នៅក្នុងផ្នែកទី១ នៃការជំនុំជម្រះក្តីនេះ យើងលើកយកតែបទឧក្រិដ្ឋពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជន នៅក្រោយថ្ងៃជ័យជម្នះរបស់ពួកខ្មែរក្រហម គឺនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបទឧក្រិដ្ឋពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ គឺការជម្លៀសចេញពីតំបន់ជនបទ ទៅកាន់ភូមិភាគឧត្តរ និងពាយ័ព្យក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ហើយនិងការ

សម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃយ៉ាងរង្គាលនៅក្នុងខែមេសា ឆ្នាំ១៩៧៥។ ទោះបីជាផ្នែកដីកាបញ្ជូនរឿងទៅជំនុំជម្រះមានភាពកម្រិតយ៉ាងណាក្តី ក៏ផ្នែកទាំងនេះបានបញ្ចូលនៅបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដ៏ធំទូលាយ និងដែលប៉ះពាល់ដល់ជនរងគ្រោះរាប់លាននាក់ រួមទាំងការជម្លៀសប្រជាជនដោយបង្ខំ ការធ្វើទុក្ខបុកម្នេញ ការបាត់ខ្លួនដោយបង្ខំ មនុស្សឃាត និងការសម្លាប់បំផុតពូជ។ មិនតែប៉ុណ្ណោះ ភស្តុតាងដែលបានបង្ហាញជូននៅក្នុងដំណាក់កាលនៃការជំនុំជម្រះក្តីនេះ បានបង្ហាញបទឧក្រិដ្ឋដែលបានប្រព្រឹត្ត គឺសុទ្ធតែកើតឡើងដោយសារផលវិបាកនៃគោលនយោបាយឧក្រិដ្ឋ និងការបន្តការអនុវត្តផែនការឧក្រិដ្ឋទាំងនៅមុន និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទ ខៀវ សំផន និង នួន ជា និងអ្នកដទៃទៀត ដែលជាមេដឹកនាំជាន់ខ្ពស់បំផុតនៃរបបនោះ បានបង្កើត និងអនុវត្តផែនការ និងគោលនយោបាយទាំងនេះ ដោយបានដឹងថាបទឧក្រិដ្ឋទាំងនេះនឹងកើតមានឡើងជាយថាហេតុ។ ដូច្នេះ អ្វីដែលបានកើតឡើងគឺជាអ្វីដែលពួកគេបានរៀបចំផែនការដើម្បីយល់អំពីការដឹងឮ និងចេតនារបស់ជនជាប់ចោទ និងដើមចមនៃផែនការ និងគោលនយោបាយឧក្រិដ្ឋទាំងនេះ យើងត្រូវត្រឡប់ទៅក្រោយ និងពិនិត្យមើលប្រវត្តិខ្លះៗនៃពួកខ្មែរក្រហម និងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន និង នួន ជា។

[១០:០០:៥៤]

រឿងក្តីនេះនៅចំពោះមុខនេះ គឺជារឿងក្តីព្រហ្មទណ្ឌមួយពាក់ព័ន្ធនឹងអង្គហេតុដ៏ស្មុគស្មាញបំផុតដែលពុំធ្លាប់ត្រូវបានចោទប្រកាន់ពីមុនមក។ ការចេញសាលក្រមនៅក្នុងរឿងក្តីនេះ និងតម្រូវឲ្យមានការវិភាគលើភស្តុតាងជាច្រើនដែលបង្ហាញអំពីការវិវត្តន៍នៃផែនការឧក្រិដ្ឋនៅក្នុងរយៈពេលជាច្រើនឆ្នាំ។ ក៏ប៉ុន្តែ ទោះបីនៅក្នុងរឿងក្តីស្មុគស្មាញបំផុតនេះយ៉ាងណាក៏ដោយ ក៏ចេតនាឧក្រិដ្ឋ និងអំពើឧក្រិដ្ឋអាចត្រូវបានបង្ហាញតាមរយៈហេតុការណ៍សំខាន់ៗមួយចំនួន ហើយនៅក្នុងរឿងក្តីនេះហេតុការណ៍សំខាន់ៗរួមមាន៖ កិច្ចប្រជុំរបស់គណៈមជ្ឈបក្សកុម្មុយនីស្តកម្ពុជានាខែមិថុនា ឆ្នាំ១៩៧៤ ដែលនៅក្នុងរយៈពេលនោះដែលមេដឹកនាំបក្ស ក្នុងនោះរួមទាំងជនជាប់ចោទទាំងនេះផងដែរបានសម្រេចសមូហភាពជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជននានា។

ចំណុចមួយទៀត ដែលយោងទៅលើកិច្ចប្រជុំគណៈកម្មាការនៅតាមសមរភូមិនាដើមខែមេសា ឆ្នាំ១៩៧៥ ដែលនៅក្នុងពេលនោះ មេដឹកនាំ ក្នុងនោះរួមទាំងជនជាប់ចោទទាំងនេះផងដែរបានបញ្ជាក់អំពីសេចក្តីសម្រេច និងដាក់បញ្ជាដល់យោធាដើម្បីធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

សេចក្តីសម្រេចមួយចំនួនទៀតធ្វើឡើងដោយមេដឹកនាំបក្សដែលសម្រេចឲ្យសម្រេចមន្ត្រីយោធាដែលចាប់ខ្លួនបាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងសេចក្តីសម្រេចមួយដែលបានប្រកាសឲ្យដឹងជាសាធារណៈដោយសន្និបាតជាតិលើកទី២ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ និងសេចក្តីសម្រេចរបស់មជ្ឈបក្សកុម្មុយនីស្តកម្ពុជានាខែសីហា ខែកញ្ញា ឆ្នាំ១៩៧៥ ដោយសម្រេចផ្លាស់ទីដោយបង្ខំប្រជាជនជាងកន្លះលាននាក់ទៅតាមតំបន់នានានៅប៉ែកឧត្តរ និងពាយ័ព្យនៃប្រទេស។ សំណួរសួរថាតើជនជាប់ចោទអាចថាមិនដឹង មិនឮបានទេ? បើជនជាប់ចោទទាំងពីរសុទ្ធតែបានចូលរួម និងគាំទ្រសេចក្តីសម្រេចខាងលើនេះ ហើយពួកគេបានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ ដែលកំពុងត្រូវបានចោទប្រកាន់នៅពេលនេះផងដែរ។ ពួកគេមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ដោយធ្វើយ៉ាងណាធានាឲ្យឧក្រិដ្ឋកម្មទាំងនេះប្រព្រឹត្តឡើងតាមរយៈអំពី និងសិទ្ធិអំណាចរបស់ពួកគេ។

[១០:០៣:៣២]

យើងខ្ញុំសូមសន្និដ្ឋានថា គ្រាន់តែអំពើប៉ុណ្ណេះ ក៏វាជាភស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញពិរុទ្ធភាពជនជាប់ចោទទាំងនេះបានហើយ។ ក៏ប៉ុន្តែយើងខ្ញុំក៏បានដាក់នៅចំពោះមុខលោក លោកស្រីចៅក្រមនូវភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលបានមកពីប្រភពជាច្រើន រួមទាំងភស្តុតាងជាឯកសារ និងភស្តុតាងជាសក្ខីកម្មដែលបង្ហាញលម្អិតអំពីការរៀបចំផែនការ និងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

ភស្តុតាងទាំងនេះបង្ហាញថា ឧក្រិដ្ឋកម្មទាំងនេះពុំត្រូវបានប្រព្រឹត្តឡើងនៅក្នុងហេតុការណ៍ដែលពុំបានរំពឹងទុក ឬនៅក្នុងពេលផ្លាស់ប្តូរហេតុការណ៍នោះភ្លាមៗតែម្តងនោះទេ។ ហើយឧក្រិដ្ឋកម្មទាំងនេះក៏ពុំមែនកើតឡើងដោយចៃដន្យផងនោះដែរ។ ផ្ទុយទៅវិញឧក្រិដ្ឋកម្មទាំងនេះត្រូវបានរៀបចំឡើង និងអនុវត្តទៅតាមការរៀបចំយ៉ាងជាក់លាក់តាមរយៈក្រុមដែលមានឋានានុក្រម មានវិន័យ និងមានការរៀបចំដឹកនាំដោយជនជាប់ចោទទាំងនេះ។

សូមអនុញ្ញាតជម្រាបជូនលោក លោកស្រីចៅក្រមថា ជាបឋមករណីនេះគឺវាមិនពាក់ព័ន្ធនឹងមនោគមន៍វិជ្ជានៃពួកកុម្មុយនីស្ត ឬទស្សនៈប្រណាំងប្រជែងផ្នែកនយោបាយនោះទេ។ ហើយរឿងក្តីដែលកំពុងជំនុំជម្រះនៅតុលាការនេះ ក៏មិនមែនជារឿងក្តីពាក់ព័ន្ធនឹងកុម្មុយនីស្តនិយម ឬសង្គមនិយម ឬប្រព័ន្ធនយោបាយណាមួយ ឬក៏មនោគមន៍វិជ្ជាណានោះឡើយ។ រឿងក្តីនេះ គឺជារឿងក្តីដែលមានការពាក់ព័ន្ធយ៉ាងពិតប្រាកដទៅនឹងអំពើហិង្សា ការដាក់ឲ្យទៅជាទាសករ និងការសម្លាប់មនុស្សដ៏រង្គាល។ លើសពីនេះទៀត រឿងក្តីនេះ គឺពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ពេល

គឺបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយកងកម្លាំង និងកម្មាភិបាលដែលដឹកនាំបញ្ជាដោយ នួន ជា, ខៀវ សំផន និងមេដឹកនាំដទៃទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ភស្តុតាងបានបង្ហាញឲ្យឃើញថា គ្រប់បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយកងកម្លាំងទាំងនោះ គឺជាបទឧក្រិដ្ឋដែលជនជាប់ចោទទាំងនេះមានចេតនាគិតទុកជាមុន។ បទឧក្រិដ្ឋទាំងនោះជាចំណុចស្នូលនៃផែនការឧក្រិដ្ឋរួមដែលពួកគេបានរៀបចំឡើងដើម្បីអនុវត្ត។

[១០:០៦:០៨]

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាប់ចោទ នួន ជា, ខៀវ សំផន និងសហចារីរបស់ពួកគេបានបង្កើតរដ្ឋទាសករដំបូងនៅក្នុងយុគសម័យទំនើប។ ពួកគេបានបញ្ជានិងរៀបចំបណ្តេញប្រជាជនចេញឲ្យអស់ពីទីក្រុងនិងទីប្រជុំជននានានៅទូទាំងប្រទេសកម្ពុជា។ ពួកគេបានកម្ទេចផ្ទះសម្បែង និងបំបែកបំបាក់គ្រួសារព្រមទាំងកៀងប្រជាជនដែលត្រូវគេជម្លៀស រាប់លាននាក់ឲ្យទៅក្នុងសហករណ៍ជនបទ។ នៅពេលទៅដល់សហករណ៍ប្រជាជនទាំងនោះត្រូវបានគេឃុំខ្លួន ដកហូតសិទ្ធិសេរីភាពជាមូលដ្ឋានរបស់មនុស្សទទួលរងការធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្ត និងត្រូវបានបង្ខំឲ្យរស់នៅក្នុងស្ថានភាពដ៏ភ័យរន្ធត់។ ជនជាប់ចោទទាំងពីររូប និងសហចារីរបស់ពួកគេបានបញ្ជាឲ្យបោះបង់ចោលទាំងស្រុងនូវមធ្យោបាយក្នុងការរស់នៅ ដូចជា បិទសាលារៀន បិទផ្សារ មិនឲ្យមានតុលាការសម្រាប់កាត់សេចក្តី លុបបំបាត់សាសនា និងកម្មសិទ្ធិឯកជន។ ពួកគេបានបញ្ជា និងគ្រប់គ្រងលើការលុបបំបាត់ជាលក្ខណៈប្រព័ន្ធចំពោះក្រុមមនុស្សទាំងឡាយណាដែលពួកគេចាត់ទុកថាជាខ្មាំងរបស់ពួកគេ។ ទាំងនេះគឺជាចំណុចស្នូលនៃផែនការរួមដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វាគឺជាផែនការមួយដែលមានចេតនាឧក្រិដ្ឋស៊ីជម្រៅជាផែនការឧក្រិដ្ឋស្នូល និងដែលមានគោលបំណងគម្រោងការ និងមធ្យោបាយឧក្រិដ្ឋ។

[១០:០៧:៥៥]

ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ផែនការនោះ បានបណ្តាលឲ្យមនុស្សយ៉ាងហោចណាស់ចាប់ពី ១លាន ៧សែននាក់ ទៅ ២លាន២សែននាក់ ស្លាប់បាត់បង់ជីវិត ឬស្មើនឹងមួយភាគបួននៃចំនួនប្រជាជននាសម័យនោះ។ បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដើម្បីសម្រេចផែនការនេះបានបំផ្លិចបំផ្លាញប្រទេស និងប្រជាជននៅក្នុងប្រទេសនេះផងដែរ។ ដូចខ្ញុំបានជម្រាបពីការចាប់ផ្តើមជំនុំជម្រះក្តីនេះរួចហើយថា គ្មានតុលាការណាអាចជំនុំជម្រះរឿងក្តីពាក់ព័ន្ធបទឧក្រិដ្ឋដែលជនជាប់ចោទទាំងនេះ

ទទួលខុសត្រូវឲ្យអស់បានទេ។ ដូច្នេះ ការជំនុំជម្រះក្តីនេះគឺជាការប្រឹងប្រែងរកយុត្តិធម៌ជូនជនរងគ្រោះដោយធ្វើការជំនុំជម្រះតែលើបទឧក្រិដ្ឋសំខាន់ៗជាក់លាក់មួយចំនួនប៉ុណ្ណោះ។ នៅក្នុងការជំនុំជម្រះក្តីលើកដំបូងក្នុងសំណុំរឿងលេខ០០២នេះ ជនជាប់ចោទកំពុងត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តលើមនុស្សរាប់រយពាន់នាក់នៅក្នុងការជម្លៀសប្រជាជនដោយបង្ខំពីរដំណាក់កាល និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃទៅលើមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបានដួលរំលំ។ ជនជាប់ចោទកំពុងត្រូវបានជំនុំជម្រះក្តីពីបទមនុស្សឃាត ការសម្លាប់បំផុតពូជ ការធ្វើទុក្ខបុកម្នេញខាងនយោបាយ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀតដែលប្រព្រឹត្តតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការជម្លៀសដោយបង្ខំដែលជាផែនការឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ ការជំនុំជម្រះក្តីនេះអាចផ្តល់លទ្ធភាពដល់តុលាការដើម្បីកំណត់បទឧក្រិដ្ឋទាំងនេះក្នុងបរិវត្តន៍ប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធអំណាច និងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ។ ការជំនុំជម្រះក្តីនេះ ក៏អាចពិនិត្យមើលតួនាទីរបស់ជនជាប់ចោទនៅក្នុងរបបដែលពួកគេបានដឹកនាំបន្ថែមទៅលើការទទួលខុសត្រូវរបស់ពួកគេចំពោះបទឧក្រិដ្ឋដែលបញ្ចូលនៅក្នុងការជំនុំជម្រះក្តីវគ្គដំបូងនេះ។

[១០:១០:១៩]

លោក លោកស្រីចៅក្រមទាំងអស់! ប្រហែលជានៅចាំបានថាកាលពីចាប់ផ្តើមជំនុំជម្រះក្តីដំបូងក្នុងសំណុំរឿងនេះជនជាប់ចោទបានស្វាគមន៍កិច្ចដំណើរការនីតិវិធីទាំងនេះ ហើយពួកគេបានបង្ហាញអំពីជំហរថា នេះជាឱកាសជាប្រវត្តិសាស្ត្រមួយ ដើម្បីពួកគេអាចបំភ្លឺឲ្យច្បាស់លាស់ទាំងអស់គ្នា និងដើម្បីបង្ហាញនូវអង្គហេតុតាមការបកស្រាយរបស់ពួកគេ ព្រមទាំងដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់មកលើពួកគេនៅចំពោះមុខតុលាការ និងប្រជាជនកម្ពុជា។

នៅក្នុងអំឡុងពេលជំនុំជម្រះក្តីពួកគេផ្តល់សក្ខីកម្មបានតិចតួច និងបានអះអាងបញ្ជាក់ថា ពួកគេនឹងធ្វើសក្ខីកម្មម្តងទៀតនៅមុនបញ្ចប់កិច្ចដំណើរការនីតិវិធី។ ខៀវ សំផន បាននិយាយថា គាត់ចង់ស្តាប់ភស្តុតាងឲ្យអស់សិនមុននឹងគាត់ឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា។ ក្រោយមកនៅក្នុងដំណាក់កាលចុងក្រោយនៃការជំនុំជម្រះក្តីនេះ នៅពេលមានភស្តុតាងជាច្រើនប្រឆាំងនឹងជនជាប់ចោទទាំងពីររូបនេះ ស្រាប់តែអ្នកទាំងពីរកែប្រែជំហររបស់ខ្លួន ហើយពួកគេសម្រេចចិត្តមិនឆ្លើយនឹងសំណួររបស់ចៅក្រម របស់សហព្រះរាជអាជ្ញា ឬរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ពួកគេបានធ្វើសេចក្តីសន្និដ្ឋានសម្រេចចិត្តជាយុត្តិសាស្ត្រមួយ ដើម្បីទប់ស្កាត់ខ្លួនពួកគេកុំឲ្យគេសួរសំណួរ និងដាក់បន្ទុកបន្ថែម

ទៀត។ ពួកគេសម្រេចចិត្តមិនបន្តធ្វើសក្ខីកម្មតទៅទៀតដោយសារពួកគេគ្មានផ្លូវណាមួយដែលអាចដោះបន្ទុកបាន ប្រសិនបើត្រូវគេចោទសំណួរ។ ប៉ុន្តែពួកគេបែរជាសម្រេចធ្វើសេចក្ដីថ្លែងការណ៍បន្ថែម ដែលសេចក្ដីថ្លែងការណ៍នេះ ទាំងចៅក្រម និងទាំងមេធាវីមិនទាន់បានពិនិត្យ និងពិភាក្សាដេញដោលនៅឡើយទេ។

យើងខ្ញុំអាចសន្និដ្ឋានជាមុនថា នៅក្នុងសេចក្ដីថ្លែងការណ៍ទាំងនេះ និងនៅក្នុងសេចក្ដីថ្លែងការណ៍របស់មេធាវីពួកគេ នួន ជា និង ខៀវ សំផន នឹងស្វះស្វែងស្នើសុំឲ្យរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌតាមវិធីដោះសារគ្រប់រូបភាព។ ពួកគេនឹងលើកជាទឡ្ហីករណ៍ថា ពួកគេធ្វើនេះគឺក្នុងគោលបំណងល្អ ហើយអំណាចទាំងអស់គឺស្ថិតនៅលើមនុស្សតែម្នាក់គត់ ដែលពួកគេបានគាំទ្រគឺ ប៉ុល ពត។ ដោយសំអាងហេតុថា ពួកគេមិនបានដឹងថាការបញ្ជារួមរបស់ពួកគេបានបង្កើតឲ្យមានការកៀបសង្កត់ និងអំពើហិង្សាធំធេងដូច្នេះឡើយ ហើយពួកគេនឹងមិនធ្វើដូច្នេះទេ ប្រសិនបើពួកគេដឹងថាអំពើឃោរឃៅដ៏គួរឲ្យរន្ធត់ទាំងនេះត្រូវបានមនុស្សស្ថិតនៅក្រោមការបញ្ជារួមរបស់ពួកគេជាអ្នកប្រព្រឹត្តនោះ។

[១០:១៣:១៧]

ឆ្លងតាមការបង្ហាញនូវលេសដោះសាទាំងអស់នេះ ពួកគេនឹងបានធ្វើក្បួន -- តាមក្បួនដែលធ្លាប់ប្រើដោយជនផ្ដាច់ការដែលត្រូវបានតុលាការនាំមកកាត់ទោសពីបទឧក្រិដ្ឋទ្រង់ទ្រាយធំមកលើប្រជាជនឯង។ តាមក្បួននោះពួកគេនឹងឆ្លើយថា "អំពើទាំងនេះមិនមែនជាកំហុសខ្ញុំទេ បើចង់បន្ទោសត្រូវបន្ទោសអ្នកផ្សេងទើបត្រូវ"។ យើងខ្ញុំក៏អាចព្យាករទុកជាមុនបានផងដែរថា ដើម្បីបកស្រាយបង្វាងភស្ដុតាងដែលបង្ហាញការចូលរួមដោយបុគ្គលខ្លួនឯងផ្ទាល់ក្នុងការប្រព្រឹត្តឧក្រិដ្ឋទាំងនោះ ពួកគេនឹងលើកឡើងអំពីភាពអយុត្តិធម៌ជាប្រវត្តិសាស្ត្រ ពោលគឺប្រវត្តិសាស្ត្រនៃអាណានិគមនិយមបារាំងនៅកម្ពុជា សង្គ្រាមពីអតីតកាល និងទង្វើរបស់រដ្ឋាភិបាលកម្ពុជាដែលមានមុនរបបកម្ពុជាប្រជាធិបតេយ្យ។ ពួកគេអាចនឹងបង្ហាញអំពីទ្រឹស្ដីនៃការរួមគំនិតក្បត់របស់ប្រទេសជិតខាង ហើយពួកគេនឹងលើកឡើងថា "នៅថ្ងៃ១៧ខែមេសា ឆ្នាំ១៩៧៥ ពួកគេគ្មានជម្រើសអ្វីផ្សេងក្រៅពីធ្វើដូច្នេះនោះទេ" ដូចអ្វីដែល នួន ជា បានសរសេរក្នុងសារណាថា ជាលាយលក្ខណ៍អក្សររបស់គាត់។ ពួកគេនឹងស្នើសុំឲ្យលោក លោកស្រីចៅក្រមឲ្យទទួលស្គាល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុង និងការដាក់ប្រទេសកម្ពុជាឲ្យស្ថិតនៅក្នុងស្ថានភាពរបបទាសករ និងការភ័យតក់ស្លុតគឺជាការធ្វើត្រឹមត្រូវតាមច្បាប់ ដោយមានហេតុផលសមរម្យ និងចាំបាច់។ នួន ជា បានអះអាងក្នុងសារណារបស់គាត់ថា "ទង្វើរបស់ពួកគេគឺជាទង្វើត្រឹមត្រូវ

ហើយពួកគេធ្វើបានលឿនមុនផែនការកំណត់ ហើយនិងធ្វើបានលឿនអស្ចារ្យមែនទៀតផង"។ ភស្តុតាងដែលពួកគេដាក់នៅចំពោះមុខតុលាការនេះ គឺជាភស្តុតាងដែលគ្មានមូលដ្ឋានអ្វីបន្តិចទាល់តែសោះចំពោះការអះអាងដូច្នេះ។ ការអះអាងទាំងនេះវាគ្មានអ្វីក្រៅតែពីការកុហកភូតភរយ៉ាងច្បាស់ក្រឡែតនោះឡើយ។

[១០:១៥:៣៣]

ភស្តុតាងដែលលោក លោកស្រីចៅក្រម ទទួលបានក្នុងរយៈកាលដេញដោល បានបង្ហាញឲ្យឃើញថា ជនជាប់ចោទទាំងនេះគឺជាស្ថាបនិក ជាប្រធាន ជាអ្នកគ្រប់គ្រងផ្ទាល់ និងជាអ្នកចូលរួមដោយស្ម័គ្រចិត្តនៅក្នុងបទឧក្រិដ្ឋដែលពួកគេបានចោទប្រកាន់នេះ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងក្រោមក្រសែភ្នែកយ៉ាងយកចិត្តទុករបស់ជួរថ្នាក់ដឹកនាំជាសមូហភាព ដែលជនជាប់ចោទទាំងនេះបានដើរតួនាទីយ៉ាងសំខាន់។ ភស្តុតាងបានបង្ហាញថា ជនជាប់ចោទបានធ្វើសកម្មភាពទាំងនេះដោយចេតនានៅក្នុងគោលបំណងប្រព្រឹត្តឧក្រិដ្ឋកម្ម។

ខ្ញុំ និងសហការីរបស់ខ្ញុំលោក វីល្លៀម ស្មីត នឹងបង្ហាញសេចក្ដីសន្និដ្ឋានបញ្ចប់ពិភាក្សាការដេញដោលជាបីផ្នែក។ ដំបូងខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានបង្ហាញអំពីភស្តុតាងពាក់ព័ន្ធនឹងបទឧក្រិដ្ឋនៃការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី១ និងដំណាក់កាលទី២ និងផែនការឈានទៅរកការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ពួកគេ។ បន្ទាប់មកទៀតសហការីរបស់ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានបង្ហាញអំពីផែនការឧក្រិដ្ឋពាក់ព័ន្ធនឹងការសម្លាប់ទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ និងបទឧក្រិដ្ឋនៅទួលពោធិ៍ជ្រៃ ហើយគាត់នឹងធ្វើសេចក្ដីសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទនីមួយៗ តាមរយៈការចូលរួមរបស់ពួកគេ និងការចូលរួមចំណែកដ៏សំខាន់នៅក្នុងផែនការឧក្រិដ្ឋរួម។ គាត់នឹងលើកឡើងអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ក្នុងការរៀបចំផែនការ ការបញ្ជា ការជួយនិងជំរុញ និងការញុះញង់ឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ព្រមទាំងខកខានក្នុងការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ពួកគេ ក្នុងនាមជាថ្នាក់លើ ឬនៅក្នុងការដាក់លើចារីដែលផងដែរ។ ហើយជាចុងក្រោយនៅផ្នែកទី៣ ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងការកំណត់ទោស។

[១០:១៧:៤៣]

ហេតុការណ៍ទាំងឡាយដែលបានកើតនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពុំមែនជាហេតុការណ៍ដាច់ដោយឡែក និងលេចចេញដោយពុំដឹងខ្លួននោះទេ។ ហេតុការណ៍នេះបានកើតឡើងបន្តចេញពីគោលនយោបាយ ដែលបង្កើតឡើងយ៉ាងត្រឹមត្រូវដោយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីជម្លៀសប្រជាជនដោយ

បង្ខំនៅតាមទីជួបប្រជុំជន ដែលបក្សនេះបានកាន់កាប់ក្នុងគោលបំណង ដើម្បីធ្វើឱ្យប្រជាជននៅតាមទីប្រជុំជនទាំងនោះក្លាយជាទាសករ និងដើម្បីកាប់សម្លាប់សមាជិកនៃរបបសាធារណរដ្ឋខ្មែរ និងបុគ្គលផ្សេងទៀតដែលត្រូវបានគេចាត់ទុកថាជាខ្មាំង។

ភស្តុតាងដែលបានបង្ហាញអំពីអំពើទាំងនេះនៅចុងទសវត្សរ៍ទី៦០ និងនៅដើមទសវត្សរ៍ទី៧០ និងជាភស្តុតាងសំខាន់។ មូលហេតុដែលសំខាន់គឺថា វាបានបង្ហាញឱ្យឃើញហេតុការណ៍នាខែមេសា ឆ្នាំ១៩៧៥ ដែលជាហេតុការណ៍មួយផ្នែក បង្ហាញឱ្យឃើញនូវប្រព័ន្ធកើតឡើងជាហូរហែនៃអំពើហិង្សាភាពសាហាវយង់ឃ្នង និងការជិះជាន់ ដែលជនជាប់ចោទបានបង្កើតឡើងនៅមុនរយៈពេលនេះជាយូរមកហើយ។

[១០:១៩:០៣]

ភស្តុតាងទាំងនេះបានបង្ហាញផងដែរថា នៅពេលឯកភាពគ្នាជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ក្រោយពីបានទទួលជ័យជម្នះមកនោះ គឺជនជាប់ចោទបានដឹងថា ឧក្រិដ្ឋកម្មធំៗទាំងឡាយនឹងពិតជាត្រូវបានប្រព្រឹត្តឡើង។ ពួកគេបានដឹងរឿងនេះ ដោយសារពួកគេបានធ្វើជាមុន និងបានឃើញការរងទុក្ខវេទនាដែលបានកើតមាន។ ភស្តុតាងទាំងនេះបង្ហាញយ៉ាងជឿជាក់ឱ្យយើងឃើញនូវចេតនា មូលហេតុដើម ការគិតទុកជាមុន និងសភាពផ្លូវចិត្តរបស់ពួកគេ។ គោលនយោបាយក្នុងការផ្លាស់ទីលំនៅដោយបង្ខំ និងការកាប់សម្លាប់ក្រុមដែលមានកំណត់ទុក មានទំនាក់ទំនងគ្នាក្នុងទិដ្ឋភាពមួយយ៉ាងសំខាន់។ គោលនយោបាយទាំងពីរនេះ ជំរុញចេញមកពីការយល់ឃើញរបស់ជនជាប់ចោទទាំងនេះ និងគិតថាវាមានសារៈសំខាន់ត្រូវចាត់ទុកបុគ្គលគ្រប់គ្នាដែលនៅក្រៅជួរបដិវត្តន៍ថា ជាខ្មាំងពិតឬទំនងជាខ្មាំង។ ជនជាប់ចោទទាំងនេះ បានដឹងអំពីការបាបប្រជាជនយ៉ាងធ្ងន់ធ្ងរ ព្រោះជាក់ស្តែងពួកគេចាត់ទុកប្រជាជនទាំងនោះថាជាជនសង្ស័យ និងត្រូវចាត់ទុកថាជាខ្មាំង ជាពិសេសអ្នកដែលមកពីទីក្រុង អ្នកដែលមានការអប់រំខ្ពស់ អ្នកដែលបានជាប់ខ្សែនៅបរទេស សមាជិកនៃក្រុមជាតិពន្ធុភាគតិច អ្នកដែលកាន់សាសនា និងជាពិសេសអ្នកដែលធ្លាប់ជាប់និន្នាការជាមួយរបបចាស់។

ដោយសារភាពខ្លាចស្រមោលខ្លួនឯង ទើបបណ្តាលឱ្យមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអនុវត្តវិធីបង្ខំឱ្យអ្នកដែលរស់នៅក្រោមការត្រួតត្រារបស់ខ្លួន គាំទ្រខ្លួន ដោយការបំភិតបំភ័យឱ្យតក់ស្លុត។ បុគ្គលទាំងឡាយដែលពួកគេបានមើលឃើញថា ប្រឆាំងនឹងពួកគេ គឺជាអ្នកទទួលរងនូវទុក្ខទោស និងទទួលរងនៅសេចក្តីស្លាប់។ អំពើហិង្សានេះ បានបង្ហាញឱ្យឃើញនូវរបៀបដែលពួកគេបានឡើងកាន់អំណាច

របៀបដែលពួកគេអនុវត្តអំណាចទាំងនោះ និងរបៀបដែលពួកគេបានព្យាយាមយកអំណាចទាំងនោះមកអនុវត្តចំពោះបុគ្គលទាំងឡាយដែលនៅក្រៅជួរ។

[១០:២១:៣៤]

អំពើហិង្សានេះ មានដើមកំណើតរបស់វាចេញមកពីការតស៊ូវណ្ណៈរបស់បក្ស ប្រឆាំងនឹងខ្មាំងរបស់ខ្លួន។ ការតស៊ូនេះកើតឡើងចាប់តាំងពីពេលដែលបក្សនេះបានកកើតពីដំបូងនៅក្នុងឆ្នាំ១៩៦០។ សេចក្តីណែនាំរបស់បក្សពោលគឺ ទស្សនាវដ្តីទង់បដិវត្ត បានបញ្ជាក់លើបញ្ហានេះថា "នៅក្នុងសន្និបាតលើកទី១ របស់បក្សនាខែកញ្ញា ឆ្នាំ១៩៦០ មេដឹកនាំបក្សរួមមាន ប៉ុល ពត, នួន ជា និង អៀង សារី បានសម្រេចថា នៅក្នុងសង្គមកម្ពុជា គឺកសិករ និងម្ចាស់ដីមានទំនាស់ស្លាប់រស់នឹងគ្នា"។ ហិង្សាបដិវត្តន៍នេះហើយដែលជាចំណុចចាប់ផ្តើម និងអ្វីដែលពួកគេហៅថា "បដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ"។

ទស្សនៈអំពីទំនាស់សម្លាប់រស់មានអានុភាពខ្លាំងក្លា និងឋិតថេររហូតមក។ វាពុំមែនគ្រាន់តែជាទស្សនវិជ្ជាអរូបីប៉ុណ្ណោះទេ តែវាក៏ជាគោលការណ៍អនុវត្តជាក់ស្តែង និងគ្មានអ្វីអាចមកសម្របសម្រួលបាន។ នៅមន្ទីរស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ទទួលខុសត្រូវចំពោះមរណភាពលើប្រជាជនជាង ១២.០០០នាក់ ដែលមជ្ឈិមបក្សចាត់ទុកថា ខ្មាំង។ ដូច្នេះឃើញថា កាំង ហ្កេកអ៊ាវ ជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់អាចពន្យល់បានថា តើទំនាស់ស្លាប់រស់នោះគឺជាអ្វីដែរ? នៅពេលដែលផ្តល់សក្ខីកម្ម កាំង ហ្កេកអ៊ាវ បានពន្យល់ក្នុងន័យសាមញ្ញបំផុតដែលមានខ្លឹមសារដូចតទៅ៖ "ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងទស្សនវិជ្ជា សម្ភារនិយម បដិច្ចសមុប្បាត វាមានទំនាស់ហ្នឹងគ្នា គឺទំនងរវាងយើង និងខ្មាំង គឺជាទំនាស់ស្លាប់រស់។ មានន័យថា បើមួយនៅរស់រីកចម្រើនបាន ត្រូវតែអត់មានមួយទៀត ក៏ប៉ុន្តែទោះបីជាយ៉ាងក៏ដោយ ក៏ជាប់ចោទប្រាកដជាតវ៉ា បដិវត្តន៍នេះពុំមែនជាការវាយប្រឆាំងនឹងប្រជាជននោះទេ។ វាគឺជាការប្រយុទ្ធប្រឆាំងនឹងប្រពន្ធនៃការជិះជាន់តែប៉ុណ្ណោះ។ ដូច្នេះ សូមលោក លោកស្រីចៅក្រម កុំមានការភ័ន្តច្រឡំនឹងការភូតភរបែបនេះ។

[១០:២៤:១៣]

ប្រជាជនរាប់រយពាន់នាក់បានស្លាប់ដោយសារលទ្ធផលនៃសេចក្តីសម្រេចប្រើប្រាស់ហិង្សាបដិវត្តន៍តាំងពីមុនខែមេសា ឆ្នាំ១៩៧៥នោះមកម្ល៉េះ។ ដើម្បីអនុវត្តហិង្សាប្រដាប់អាវុធប្រឆាំងនឹងខ្មាំងរបស់ពួកគេ មេដឹកនាំបក្សបានបង្កើតកងការពារសម្ងាត់ចាប់ពីឆ្នាំ១៩៦១មក ក្រោយមកកងឈ្លបប្រដាប់អាវុធទាំងនោះ បានក្លាយជាកងទ័ពខ្មែរក្រហម។ នៅក្នុងសៀវភៅបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៤ របស់ ខៀវ

សំផន បានទទួលស្គាល់ថា នៅទសវត្សរ៍ឆ្នាំ៦០ កងទាំងនេះមានមុខងារដូចជា ការកាប់ស្លាប់ប្រជាជនដែលចាប់បាននៅពេលមកលួចលបស្តាប់ ឬតាមដានការប្រជុំរបស់បក្ស។ នៅជនបទមិនគ្រាន់តែមានសមាគមកសិករតាមរូបភាពផ្សេងៗជាច្រើនប៉ុណ្ណោះទេ គឺថែមទាំងមានកងការពារសម្ងាត់ថែមទៀត។ ពេលខ្លះគិញសម្ងាត់របស់រដ្ឋអំណាចមូលដ្ឋានដែលមកលួចលបស្តាប់ ឬតាមដានការប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវចាប់ចង និងយកទៅបាត់។ ការកម្ទេចខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា មិនដែលត្រូវបានកម្រិតត្រឹមតែស្វ័យការពារខ្លួន ឬការសម្លាប់នៅក្នុងភ្នក់ភ្លើងសង្គ្រាមប៉ុណ្ណោះទេ កម្មាភិបាលបក្ស និងកងឈ្លបបានប្រហារជីវិតពួកទាហាន ដែលពួកគេចាប់ខ្លួនបានចាប់តាំងពីដើមដំបូងបំផុតនៃចលនាបះបោររបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងរបបសម្តេច នរោត្តម សីហនុ ក្នុងឆ្នាំ១៩៦៨មកម្ល៉េះ។

[១០:២៦:០២]

លោក ហ្វីលីព ស្ហូត បានរៀបរាប់អំពីកាលៈទេសៈដំបូងៗនៃការអនុវត្តគោលនយោបាយនេះ។ ខ្ញុំសូមដកស្រង់ខ្លឹមសារដូចតទៅ៖ “ខ្ញុំ ហើយនៅក្នុងអំឡុងពេលនោះ នៅពេលគេចាប់បាន អ្នកទោសជាឈ្លើយសឹកហ្នឹង គឺថាប្រសិនបើពួកគេជាមនុស្សមូលដ្ឋាន ហើយត្រូវបានគេស្គាល់ គេអាចនឹងលែងទៅវិញដោយមិនមានការធ្វើទុក្ខបុកម្នេញអ្វីទេ។ តែបើគេមិនស្គាល់ទេ គេអាចសម្លាប់ចោលតែម្តង។ ដូច្នេះគោលនយោបាយមិនទុកអ្នកទោសនេះមានតាំងពីដំបូងមកម្ល៉េះ”។ បន្ទាប់មកលោក ស្ហូត ត្រូវបានតុលាការចោទសួរថា តើការសិក្សាស្រាវជ្រាវរបស់គាត់បានបង្ហាញថាការកាប់សម្លាប់ទាំងនេះធ្វើឡើងនៅក្រោមការណែនាំជាលាយលក្ខណ៍អក្សរ ឬយ៉ាងណានោះ? គាត់បានឆ្លើយដូចតទៅ៖ “មិនមានការណែនាំជាលាយលក្ខណ៍អក្សរទេ។ វាគ្រាន់តែថាអ្វីដែលអ្នកបានធ្វើ អ្វីដែលអ្នកបានដឹង អ្នកត្រូវតែធ្វើ។ អ្វីដែលអ្នកដឹងថាបក្សចង់ឲ្យអ្នកធ្វើគឺគេពិតជាយល់ថា ត្រូវធ្វើបែបហ្នឹង”។

[១០:២៧:២២]

នៅឆ្នាំ១៩៧១ ការប្រើប្រាស់ ការបំភិតភ័យរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងអ្នកដែលគេយល់ថាជាភ្នាក់ងាររបស់ខ្មាំង និងគិញបានក្លាយជាប្រព័ន្ធទៅហើយ។ នៅក្នុងសំណុំរឿងមានភស្តុតាងពីមន្ទីរសន្តិសុខមួយចំនួនបង្ហាញឲ្យឃើញនៅក្នុងអំឡុងពេលនេះ។ ច្បាស់បំផុត គឺលោក លោកស្រីចៅក្រមបានស្តាប់ពួកភស្តុតាងអំពីការបង្កើតមន្ទីរសន្តិសុខម-១៣ នៅក្នុងខែកក្កដា ឆ្នាំ១៩៧១ នៅក្នុងឃុំអមលាំង ស្ថិតនៅក្នុងភូមិភាគពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជា។

កាំង ហ្កេកអ៊ាវ ហៅឌុច បានចាត់ចែងមន្ទីរម-១៣ ចាប់តាំងពីខែកក្កដា ១៩៧១ ដល់ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងការផ្ដល់សក្ខីកម្មរបស់ ឌុច បានរៀបរាប់អំពីរបៀបដែលកងទ័ពខ្មែរក្រហមបានបញ្ជូនប្រជាជនដែលគេសង្ស័យថាជាគិញមកកាន់មន្ទីរសន្តិសុខនេះដើម្បីសួរចម្លើយ និងសម្លាប់ចោល។ ខ្ញុំសូមដកស្រង់ខ្លឹមសារដូចខាងក្រោម៖

"ប្រជាជនដែលពួកកងទ័ពបានបញ្ជូនមកមន្ទីរម-១៣ ដើម្បីសួរចម្លើយ និងកម្ទេចចោលនោះគឺជាផ្នែកមួយនៃគោលនយោបាយរបស់បក្ស។ ទោះបីជាពួកគេជាអ្នកក្រក៏ដោយ ឬជាអ្នកមានក៏ដោយ ក៏ពួកគេត្រូវបានបញ្ជូនមកម-១៣ដែរ។ ហើយពួកគេត្រូវបានចោទប្រកាន់ថាជាគិញ ហើយបន្ទាប់មកត្រូវបានគេកម្ទេចចោលតែម្ដង"។

[១០:២៩:០៤]

ឌុច បានអះអាងថាអ្នកទោសនៅម-១៣ ត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់ចោលទៅតាមគោលនយោបាយរបស់បក្ស។ ឧក្រិដ្ឋកម្មដំបូងៗនេះត្រូវបានប្រព្រឹត្តនៅក្រោមការបញ្ជារបស់មេបញ្ជាការមូលដ្ឋានដែលទទួលបញ្ជាពីមជ្ឈិមបក្សដូចដែលមេធាវីការពារក្ដីអាចជឿជាក់បាន។ ឌុច បានបំពេញការងារនេះនៅក្រោមការត្រួតត្រាផ្ទាល់ពី វន វ៉េត ដែលជាលេខាភូមិភាគពិសេស ហើយសហការីរបស់គាត់ គឺនួន ជា និងខៀវ សំផន ជាសមាជិកគណៈកម្មាការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ ឌុច បាននិយាយថា វន វ៉េត ខ្លួនឯងផ្ទាល់បានណែនាំខ្ញុំពីរបៀបធ្វើទារុណកម្មអ្នកទាំងនោះ។ មធ្យោបាយល្អបំផុតដែលគាត់ចូលចិត្ត គឺការយកស្បោងផ្លាស្ទិកគ្របទៅលើក្បាល។ គាត់និយាយថា៖ "មិត្តត្រូវមើលត្រង់សរសៃ-ក បើវាភ័យ ឬវាញ័រត្រង់ហ្នឹង ឬវាភ័យញ័រខ្លាំង អាហ្នឹងហើយវាជាខ្លួនជាគិញ មានខ្លួនថាជាគិញ"។ ឧទាហរណ៍នេះគូសបញ្ជាក់អំពីភាពផ្ទុយគ្នាស្រឡះ ទៅនឹងអ្វីដែលមេដឹកនាំខ្មែរក្រហមបានអះអាង។ ទស្សនៈរបស់ពួកគេចំពោះខ្មាំង ត្រូវបានកប់ឫសយ៉ាងជ្រៅ និងអនុវត្តយ៉ាងម៉ឺងម៉ាត់ទៅតាមសភាពខ្លាចស្រមោលខ្លួនឯង និងភាពគ្មានមូលដ្ឋាននៃការពិត។ បន្តិចក្រោយមកទៀត ឌុច បានរៀបរាប់អំពីរបៀបធ្វើទារុណកម្មជាលម្អិតថា៖ "នៅម-១៣ហ្នឹង ដំបូងគេឲ្យយើងវាយអ្នកទោសហើយបន្ទាប់មកប្រើទូរសព្ទ័ គឺទូរស័ព្ទឆក់ ជារបៀបធ្វើទារុណកម្ម។ ការជ្រមុជទឹក និងការយកស្បោងផ្លាស្ទិកគ្របពីលើមុខអ្នកជាប់ឃុំឃាំងដើម្បីឲ្យពួកគេថប់ដង្ហើម"។ ឌុច បានផ្ដល់សក្ខីកម្មថា ប្រភេទខ្មាំងដែលគេបញ្ជូនមក ម-១៣ ដើម្បីសួរចម្លើយ និងសម្លាប់ចោលរួមមាន ទាហានលន់នល់ ដែលគេចាប់បានកម្មាភិបាលដែលគេបញ្ជូនទៅឲ្យរៀននៅវៀតណាម និងអ្នកនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា។

[១០:៣១:២៥]

ភស្តុតាងដ៏រឹងមាំនៃការអនុវត្ត ការសម្លាប់ក្រៅផ្លូវតុលាការ ដែលបានរៀបរាប់ឡើងដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅក្រោមសិទ្ធិអំណាចផ្ទាល់របស់មជ្ឈិមបក្ស។ ភស្តុតាងនេះគួរឲ្យជឿជាក់បំផុតដោយហេតុថា ឌុច មិនត្រឹមតែបង្ហាញថាជាមនុស្សដែលមានការចងចាំលម្អិតពិសេសប៉ុណ្ណោះទេ ប៉ុន្តែយើងឃើញថានៅពេលដែលគាត់ផ្តល់ភស្តុតាងនេះគាត់គ្មានចេតនាភូតកុហក ឬបញ្ចេញបញ្ចូលនោះឡើយ។ នៅដំណាក់កាលនោះ គាត់ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតទៅហើយ។ គាត់បានសារភាពអំពីតួនាទីរបស់គាត់ក្នុងការធ្វើទារុណកម្ម និងការសម្លាប់មនុស្សគ្មានទោសពៃរ៍ទាំងនៅម-១៣ និងទាំងនៅស-២១។ ឌុច បានបញ្ជាក់អះអាងថា របៀបសួរចម្លើយ និងការធ្វើទារុណកម្មដែលបានរៀបចំឡើងនៅ ម-១៣ គឺស្របតាមការណែនាំរបស់មេដឹកនាំបក្ស និងក្រោយមកត្រូវបានយកមកប្រើប្រាស់នៅ ស-២១ និងនៅមន្ទីរ សន្តិសុខដទៃទៀតក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ នួន ជា ខ្លួនឯងផ្ទាល់បានសារភាពអំពីអត្ថិភាពនៃមន្ទីរសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅមុនឆ្នាំ១៩៧៥ ក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយ លោក ថេត សម្បត្តិ, នួន ជា បានរៀបរាប់អំពីមន្ទីរសន្តិសុខមួយឈ្មោះ “ស-៣៩” ដែលតាមគាត់ចាំបាន គឺត្រូវបានបង្កើតឡើងដោយ ប៉ុល ពត ក្នុងឆ្នាំ១៩៧១ ដើម្បីលុបបំបាត់ ជនក្បត់ឲ្យដល់ឫសគល់ និងតាមដានពួកគិញដែលបានជ្រាបចូលក្នុងចលនារបស់ពួកគេ។

[១០:៣៣:២០]

យោងតាម នួន ជា, ស-៣៩មានភារកិច្ចស៊ើបអង្កេត និងតាមដានមនុស្សដែលសង្ស័យថាជាខ្មាំង។ ទាហានលន់នល់ ដែលគេចាប់ខ្លួនបានត្រូវបាន ឌុច សម្លាប់ចោល។ នៅឆ្នាំ១៩៧២ TCW-349 គឺជាអ្នកភូមិម្នាក់នៅក្នុងតំបន់រំដោះក្នុងខេត្តព្រៃវែង និងគ្រួសាររបស់គាត់គឺជាអ្នកស្រែ។ នៅក្នុងចម្លើយរបស់គាត់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត គាត់បានរៀបរាប់អំពីការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅក្នុងឆ្នាំនោះ។ គាត់បានមានប្រសាសន៍ថា នៅពេលនោះមេឃុំ និងមន្ត្រីរដ្ឋាភិបាលលន់នល់ត្រូវបានគេសម្លាប់ចោល។ ឧទាហរណ៍មេឃុំស្វាយអន្ទរ ឈ្មោះ ពៅ ពិន និងកូនៗរបស់គាត់ត្រូវបានគេសម្លាប់ចោល។ នៅក្នុងសក្ខីកម្មរបស់លោក ហ្វីលីព ស្សូត គាត់បានរៀបរាប់អំពីការពង្រឹងកាន់តែខ្លាំងឡើងនូវការអនុវត្តគោលនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា លើជនណាដែលខ្លួនចាត់ទុកថាជាខ្មាំងរបស់បក្ស។ គាត់យល់ស្របនឹងការរកឃើញរបស់គាត់ថា ចាប់តាំងពីឆ្នាំ

១៩៧៣ មកកម្លាំងខ្មែរក្រហមបានវះពោះអ្នកទោស សម្លាប់អ្នកដែលគេសង្ស័យថាសហការជាមួយខ្មាំងនិងអ្នកដែលរត់ចេញពីខ្មែរក្រហម។ ភស្តុតាងនិងសក្ខីកម្មរបស់គាត់មានភាពស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងសេចក្តីណែនាំជាលាយលក្ខណ៍អក្សរដែលមានចុះផ្សាយដោយមជ្ឈិមបក្សក្នុងទង់បដិវត្តខែកក្កដាឆ្នាំ១៩៧៣ ដែលមានខ្លឹមសារដូចតទៅ៖ "ចាប់យកគិញមកធ្វើមីទិ្ទង ប្រកាសកាត់ទោស ហើយនាំគ្នាសម្លាប់វាស្តែងនៅចំពោះប្រជាជនតែម្តង ធ្វើឲ្យប្រជាជនខ្លះខ្លាចរអាយើង ឃើញយើងហាក់ដូចជាឃោរឃៅពេក។ ពិនិត្យជាគោលជំហរក្នុងការកម្ទេចគិញគឺត្រឹមត្រូវ តែវាជាវិធីខុស"។ ក្នុងការធ្វើអត្ថាធិប្បាយក្នុងសេចក្តីណែនាំនេះ លោក ហ្វីលីព ស្សូត បានផ្តល់សក្ខីកម្មថា "ពួកគេដោះស្រាយទៅតាមពេលវេលាផ្សេងៗគ្នាអំពីការថា តើការសម្លាប់ ការប្រហារជីវិតត្រូវតែធ្វើយ៉ាងម៉េច និងអ្នកណាមានសិទ្ធិអំណាចក្នុងការអនុវត្ត អនុញ្ញាតឲ្យមានការប្រហារជីវិតបែបនេះ"។ គឺថាវាតែងតែមានការរំលោភបំពាន ហើយប៉ុន្តែគោលការណ៍ណែនាំខាងក្រោយការកាប់សម្លាប់នេះគឺ សម្លាប់អ្នកទាំងនោះជាការត្រឹមត្រូវហើយ នៅពេលណាដែលគេប្រឆាំងជាមួយបដិវត្តន៍ ជំទាស់បដិវត្តន៍។ ប៉ុន្តែការសម្លាប់នេះគឺកាប់សម្លាប់ក្នុងមធ្យោបាយមួយ ដែលមិនត្រូវធ្វើឲ្យប៉ះពាល់ទៅដល់គោលបំណងរបស់បដិវត្តន៍ទេ។ មិនត្រូវសម្លាប់មនុស្សនៅចំពោះមុខអ្នកដទៃទៀតទេ។ នេះគេធ្វើជាទូទៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។

[១០:៣៦:៣៧]

មិនតែប៉ុណ្ណោះ អង្គហេតុមួយទៀតនៃការកម្ចាត់ជាលក្ខណៈប្រព័ន្ធ និងមានការរៀបចំចាត់តាំងច្បាស់លាស់ចំពោះជនណាដែលខ្មែរក្រហមចាត់ទុកថាជាខ្មាំង។ គឺការកាប់សម្លាប់កម្មាភិបាលខ្មែរក្រហមរាប់រយនាក់ ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញពីប្រទេសវៀតណាម ដែលកាលនៅក្នុងប្រទេសវៀតណាមនោះអស់ជាច្រើនឆ្នាំ ពួកគេបានទទួលការបណ្តុះបណ្តាលបន្ថែមខាងផ្នែកទ្រឹស្តីកុម្មុយនីស្តនិងបន្តទៅជាជនកុម្មុយនីស្តដ៏ស្មោះស្ម័គ្រតទៅទៀត។

នៅដើមទសវត្សឆ្នាំ១៩៧០ នៅពេលចលនាកុម្មុយនីស្តនៅប្រទេសកម្ពុជាចាប់ផ្តើមរឹងមាំ ពួកគេបានវិលត្រឡប់មកប្រទេសកម្ពុជាដើម្បីជួយបដិវត្តន៍ កាលពីដំបូងគេផ្តល់តំណែងដែលមានអំណាចនៅក្នុងជួររដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែចាប់ឆ្នាំ១៩៧២ ថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យចេញបញ្ជាឲ្យបោសសម្អាតមនុស្សទាំងអស់នេះ។ អ្នកដែលវិលត្រឡប់ពីហាណូយស្ទើរតែទាំងអស់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅសល់តែពីរបីនាក់ប៉ុណ្ណោះដែលនៅរស់។ មូលហេតុសាមញ្ញមួយក្នុង

ការសម្រេចដកអ្នកទាំងនោះចេញ និងកម្ទេចចោល គឺដោយសារតែពួកគេជាប់ពាក់ព័ន្ធនឹងប្រទេសវៀតណាម ដែលធ្វើឲ្យមេដឹកនាំកម្ពុជាប្រជាធិបតេយ្យលែងទុកចិត្ត។

[១០:៣៨:០៨]

នៅក្នុងឯកសារចេញផ្សាយនៅក្នុងឆ្នាំ១៩៩៦ អៀង សារី ទទួលស្គាល់ថាមានការកាប់សម្លាប់អ្នកដែលមកពីហាណូយចំនួនប្រហែលជា២០០០នាក់ ដោយ អៀង សារី ប្រើប្រាស់ពាក្យត្រឹមត្រូវមួយថា "ការសម្លាប់រង្គាល"។

លោក លោកស្រីចៅក្រម ប្រាកដជាក្តាប់បានហើយនូវភស្តុតាងនានាដែលបានបង្ហាញដោយសាក្សីជាច្រើនអំពីជោគវាសនារបស់កម្ពុជាមួយក្រុមនេះ។ សាក្សី នូ ម៉ៅ គឺជាកម្មាភិបាលឃុំម្នាក់នៅក្នុងស្រុកឧដុង្គកាលពីឆ្នាំ១៩៧៣។ គាត់ប៉ាន់ស្មានថា ខ្មែរ-វៀតមិញនេះមានប្រហែល ២០០០ ទៅ ៣០០០នាក់។ បន្ទាប់មកគាត់បានរៀបរាប់ពីជោគវាសនារបស់ពួកគេដូចខាងក្រោម៖

"ក្រោយមកទៀតអង្គការលើបានបញ្ជាមកថា ប្រជាជននៅមូលដ្ឋានគ្រប់ថ្នាក់ទាំងអស់ត្រូវប្រមូលគ្នាដើម្បីទៅចូលរួមវគ្គសិក្សារៀនសូត្រ ប៉ុន្តែពួកក្រុមនេះមិនដែលឃើញវិលត្រឡប់មកវិញទេ ក្រោយគេបញ្ជូនទៅចូលរួមវគ្គសិក្សារៀនសូត្រនេះ។ ខ្ញុំសន្និដ្ឋានថា ពួកគេប្រហែលជាបាត់ខ្លួន ឬក៏ស្លាប់បាត់ទៅហើយ ក្រោយការចូលរួមវគ្គសិក្សារៀនសូត្រ អ៊ីចឹងដូចខ្ញុំជម្រាបជូន។ ខ្ញុំនៅតែជឿជាក់ថា ពួកគេស្លាប់អស់ហើយ"។

សាក្សី ឈូក រីន ដែលជាមេបញ្ជាការកងអនុសេនាតូចប្រចាំភូមិភាគនិរតីរបស់កម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៣ ក៏បានធ្វើសក្ខីកម្មរំឭកឡើងវិញនូវការបោសសម្អាតកម្មាភិបាលខ្មែរដែលវិលត្រឡប់មកពីទីក្រុងហាណូយនេះថា៖ "ក្នុងឆ្នាំ១៩៧៣ អ្នកទាំងអស់នេះគឺជាមុខសញ្ញាដែលត្រូវចាប់ខ្លួន ប៉ុន្តែគ្រាន់តែនៅខេត្តកំពតមួយ ខ្ញុំអាចនិយាយបានថាអ្នកដែលទៅវៀតណាមក្នុងសម័យឥស្សរៈ ដែលក្រោយមកបានវិលត្រឡប់មកវិញ សុទ្ធតែត្រូវបានចាប់ខ្លួន និងត្រូវបានចាត់ទុកថាជាខ្មែរហាណូយពិតជាមានការចាប់ខ្លួនមែន"។

[១០:៤០:២០]

លោក ស្ទីវហ្វិន ហេដឌ័រ *(Stephen Heder)* បានសម្ភាសមនុស្សម្នាក់ក្នុងចំណោមអ្នកដែលជួយក្នុងការបោសសម្អាតក្នុងតំបន់១៧នៃភូមិនិរតីរបស់កម្ពុជាប្រជាធិបតេយ្យ។ កិច្ចសម្ភាសន៍នេះធ្វើឡើងក្នុងឆ្នាំ១៩៨០ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំភ្លាម។ ខាងក្រោមនេះគឺជាសម្តីរបស់អ្នក

ដែលផ្តល់បទសម្ភាសន៍ ឲ្យលោក ហេងឆ័រ។ "នៅដើមឆ្នាំ១៩៧២ ខ្មែរដែលមកពីហាណូយត្រូវបានបោសសម្អាតអស់គ្មានសល់។ ការបោសសម្អាតនេះចាប់ផ្តើមដំបូងដោយការបំបែកខ្មែរ ដែលស្ថិតនៅក្រោមអង្គភាពវៀតណាម។ ផែនការនេះមានតាំងពីដំបូង ប៉ុន្តែមិនទាន់បានអនុវត្ត ទើបតែអនុវត្តនៅដើមឆ្នាំ១៩៧២។ អង្គការរបស់យើងចាត់ការបញ្ហានេះតាមវិធីដូចតទៅនេះ៖ "យើងហៅខ្មែរទាំងនោះឲ្យត្រឡប់មកវិញ ដើម្បីមករៀនសូត្រ។ រួចហើយមានមនុស្សនាំខ្លួនពួកគេយកចេញទៅ តាមពិតពួកយើងបណ្តេញពួកគេចេញ។ នៅពេលដែលយើងចាប់ផ្តើមបោសសម្អាតពួកគេ អ្នកផ្សេងមិនដឹងមានរឿងអ្វីកើតឡើងនោះឡើយ។ ហេតុដូច្នេះទើបយើងអាចបោសសម្អាតពួកគេបានស្ទើរតែទាំងអស់។ មានមនុស្សតិចតួចណាស់ដែលបានដឹងរឿងនេះទាន់ និងបានរត់ភៀសខ្លួនទៅវៀតណាម"។

[១០:៤១:៤៩]

លោក ហ្វីលីព ស្ហូត បានស្រាវជ្រាវអំពីជោគវាសនារបស់អ្នកដែលត្រឡប់ពីហាណូយវិញទាំងនោះថា គាត់បានរកឃើញអ្នកទាំងអស់នោះត្រូវបានសម្លាប់តាមបញ្ជារបស់ ប៉ុល ពត។ នៅក្នុងតុលាការលោកមានប្រសាសន៍ថា៖ "អ្នកទាំងនោះរៀបការប្រពន្ធវៀតណាមច្រើនគ្នា ពួកគេជាប់សង្ស័យថាជាអ្នកគាំទ្រវៀតណាម។ ដូច្នេះក្នុងឆ្នាំ១៩៧៣ ទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងវៀតណាមចាប់ផ្តើមតានតឹងខ្លាំង។ បក្សកុម្មុយនីស្តកម្ពុជាកាន់តែលែងត្រូវវៀតណាម ត្បិតខ្លួនកាន់តែរឹងមាំខ្លាំងជាងមុន។ កម្លាំងរបស់ខ្លួនកាន់តែរឹងមាំខ្លាំង ចំណែកឯការសង្ស័យលើអ្នកដែលវិលចូលស្រុកវិញទាំងនោះកាន់តែមានកម្រិតខ្លាំងឡើង។ ពួកគេស្លាក់នៅជំរំមួយ និងស្លាប់ច្រើនណាស់"។

នៅក្នុងសារណារបស់យើង ភស្តុតាងនៃការបោសសម្អាតកម្មាភិបាលខ្មែរក្រហមដែលវិលត្រឡប់ពីហាណូយ គឺជាភស្តុតាងសំខាន់បំផុត។ ភស្តុតាងនេះបង្ហាញឲ្យឃើញនូវការពិតបន្ថែមមួយទៀតថា នៅក្នុងឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំរបស់បក្សដែលមានជនជាប់ចោទទាំងពីរនាក់នេះជាសមាជិក បានអនុម័តគោលនយោបាយសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ កាលណាអ្នកទាំងនោះត្រូវបានចាត់ទុកថាជាសត្រូវរបស់ពួកគេ។

[១០:៤៣:១៧]

ការពិតដ៏គួរឲ្យខ្លោចផ្សា បង្ហាញឲ្យឃើញនូវផលប៉ះពាល់ធំទូលំទូលាយ និងធ្ងន់ធ្ងរនៃចេតនាឧក្រិដ្ឋរបស់ពួកគេ។ កម្មាភិបាលមកពីហាណូយ គឺសុទ្ធតែជនកុម្មុយនីស្តប្តូរផ្តាច់ ពួកគេចង់ជួយបដិវត្តន៍ ពួកគេមិនមែនជាជនជាប់ចោទ ឬជនសង្ស័យក្នុងការចូលដៃជាមួយនឹងពួកចក្រពត្តិ មូលធន ឬវណ្ណៈជិះ

ជាន់ដ៏ទៃទៀតនោះទេ។ កំហុសតែមួយគត់របស់ពួកគេគឺការដែលពួកគេត្រូវបានចាត់ទុកថាជាប់ពាក់ព័ន្ធជាមួយនឹងប្រទេសដទៃ។ នៅក្នុងក្រសែភ្នែករបស់ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា គ្រាន់តែប៉ុណ្ណឹងក៏វាគ្រប់គ្រាន់ល្មមអាចសម្លាប់អ្នកទាំងនោះបានទៅហើយ។

ខៀវ សំផន បានទទួលស្គាល់ថា គាត់ដឹងអំពីការសម្លាប់កម្មាភិបាលហាណូយ នៅក្នុងសៀវភៅមួយដែលបោះពុម្ពផ្សាយក្នុងឆ្នាំ២០០៤។ ប៉ុន្តែគាត់បាននិយាយថាគាត់មិនបានដឹងមានអ្វីកើតឡើងចំពោះអ្នកទាំងនោះនោះទេ។ ទាំងអស់នេះគឺជាការកុហកសុទ្ធសាធ។ ខៀវ សំផន បានដឹងអំពីប្រវត្តិ និងវប្បធម៌របស់បក្សកុម្មុយនីស្តកម្ពុជា និងសម្លាប់មនុស្សដែលគេចាត់ទុកថាជាខ្មាំងជាហូរហែ។ ថាតើគាត់គិតថាអ្នកទាំងនោះត្រូវបានគេបញ្ជូនឱ្យទៅសម្រាកវិស្សមកាល ឬយ៉ាងដូចម្ដេច? ខៀវ សំផន ជាសមាជិកមជ្ឈិមបក្សតាំងពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥។ គាត់ជិតស្និទ្ធជាមួយនឹង ប៉ុល ពត និង នួន ជា។ គាត់បានចូលរួមក្នុងការពិគ្រោះយោបល់ និងសម្រេចចិត្តគោលនយោបាយរបស់បក្សក្នុងកម្រិតកំពូលមួយ។ គាត់បានសារភាពថា គាត់បានចូលរួមក្នុងមហាសន្និបាតក្នុងឆ្នាំ១៩៧១ ដែលនៅក្នុងមហាសន្និបាតនោះ បក្សបានកំណត់ថាវៀតណាមជាមិត្តមានទំនាស់។ ខៀវ សំផន បានចេញសេចក្ដីថ្លែងការណ៍ជាច្រើន ដើម្បីគាំទ្រការកម្ទេចខ្មាំងរបស់បក្ស ប៉ុន្តែបើគ្រាន់តែពិនិត្យមើលសេចក្ដីថ្លែងការណ៍របស់គាត់ យើងឃើញថាមានការព្រមទទួលស្គាល់យ៉ាងសំខាន់មួយ។ គាត់ដឹងថាកម្មាភិបាលខ្មែរក្រហមត្រូវបានដក ហើយគាត់មិនជំទាស់។ នៅក្នុងបក្សក៏មានការបោសសម្អាតផងដែរ។ ក្នុងក្រសែភ្នែករបស់មេដឹកនាំ ការបោសសម្អាតដូច្នេះគឺជាការត្រឹមត្រូវ ត្បិតធាតុខ្មាំងដែលធ្វើសកម្មភាពជ្រៀតចូលនៅក្នុងជួរបក្ស ដោយកម្លាំងសម្ងាត់។ ម្យ៉ាងទៀត សមាជិកបក្សណាដែលខ្វះឆន្ទៈបដិវត្តន៍ គឺជាមុខសញ្ញា។ ចំណុចនេះត្រូវបានបញ្ជាក់នៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយសម្រាប់ខែកុម្ភៈ - មីនា ឆ្នាំ១៩៧៦។

[១០:៤៦:០៩]

ខ្ញុំសូមបង្ហាញជូន លោក លោកស្រីចៅក្រម នូវទស្សនាវដ្ដីយុវជនបដិវត្ត ចេញផ្សាយនៅក្នុងឆ្នាំ១៩៧៤។ ឯកសារនេះជាឯកសារដែលថ្នាក់ដឹកនាំបក្សយកទៅផ្សព្វផ្សាយដល់សមាជិកនៃសម្ព័ន្ធយុវ-កក ឬហៅម្យ៉ាងទៀតថា "ក្រុមយុវជន ដែលបានចូលរួមក្នុងជួរខ្មែរក្រហម"។ ឯកសារនេះទទួលស្គាល់ឥតមន្ទិលថា បក្សសម្លាប់ជនទាំងឡាយណាដែលចូលមកក្នុងតំបន់រំដោះ និងសង្ស័យថាជាគិញ។ អត្ថបទនេះសរសេរថា "ពួកគេត្រូវកងកម្លាំងប្រដាប់អាវុធ និងប្រជាជនតំបន់រំដោះយើងចាប់បានកម្ទេចចោលយ៉ាងថោកទាបបំផុត"។

ត្រង់ផ្នែកផ្សេងមួយទៀត ឯកសារនេះបានបញ្ជាក់ថា សូម្បីតែជនដែលសង្ស័យបានចូលមកក្នុងតំបន់រំដោះ មកយកមនុស្សទៅជាមួយក៏ត្រូវបានសម្លាប់ដោយកងឈ្លប។ ភស្តុតាងដែលខ្ញុំទើបតែដកស្រង់ជូនបង្ហាញថា អ្នកដែលត្រូវគេសង្ស័យថា ជាគិញ ឬបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា ទោះជាមធ្យោបាយណាក៏ដោយ គឺដំបូងត្រូវចាប់ខ្លួន និងក្រោយមកសម្លាប់ចោល។ ពួកគេមិនសម្លាប់អ្នកទាំងនេះនៅក្នុងសមរភូមិប្រយុទ្ធក្ដៅគគុកនោះទេ។ ពួកគេមិនបានជំនុំជម្រះក្ដី មិនបានចោទប្រកាន់ និងមិនបានផ្ដន្ទាទោសតាមផ្លូវតុលាការអ្វីទាំងអស់។ ផ្ទុយទៅវិញ អ្នកទាំងនេះត្រូវបានសម្លាប់ចោលភ្លាមៗ។ ខ្ញុំសូមប្រើពាក្យដែលប្រើក្នុងសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្ដ បក្សដែលខ្ញុំទើបអានជូនអម្បាញ់មិញនេះ ថា "កម្ទេចចោលយ៉ាងថោកទាបបំផុត"។

[១០:៤៧:៥៥]

ឯកសារនេះនៅបានបង្ហាញផងដែរថា ការសម្លាប់ដែលធ្វើឡើងនៅក្នុងតំបន់រំដោះ គឺជាគោលនយោបាយ ជាផ្លូវរបស់បក្ស ដែលមានការឯកភាពពីថ្នាក់ដឹកនាំខាងលើ។ ភស្តុតាងនេះស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងភស្តុតាងនៃការសម្លាប់ជាក់ស្តែងនៅមន្ទីរម-១៣។

ការជម្លៀសប្រជាជនឲ្យចេញពីទីក្រុងនានា ដោយបង្ខំនៅក្នុងខែមេសា ១៩៧៥ គឺធ្វើឡើងទៅតាមការសម្រេចរបស់ នួន ជា និង ខៀវ សំផន ដែលសម្រេចថា នេះគឺជាមធ្យោបាយតែមួយគត់ដើម្បីផ្ដួលរំលំវណ្ណៈអ្នកទីក្រុង និងបំបែកបំបាក់ខ្សែខ្មាំងនៅតាមទីក្រុង។ ការកំណត់អត្តសញ្ញាណខ្មាំង គឺការកម្ទេចខ្មាំង គឺការធ្វើរួមជាមួយនឹងការប្រើប្រាស់ហិង្សាលើប្រជាជនស៊ីវិល ដែលត្រូវបានបង្ខំឲ្យរស់នៅតាមសហករណ៍ខ្មែរក្រហម។ សហករណ៍ត្រូវបានបង្កើតនៅឆ្នាំ១៩៧១ ហើយក្នុងឆ្នាំ១៩៧២ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានសមូហភាពភាវូបនីយកម្មដោយបង្ខំ។ នៅខែឧសភា ឆ្នាំ១៩៧៣ បក្សបានដាក់ប្រជាជនឲ្យរស់នៅក្នុងសហករណ៍កម្រិតខ្ពស់។ នៅក្នុងសហករណ៍កម្រិតខ្ពស់នេះ សិទ្ធិរបស់ប្រជាជនត្រូវបានជិះជាន់សង្កត់សង្កិន កាន់តែធ្ងន់ធ្ងរមួយកម្រិតទៀត។

[១០:៤៩:២៥]

នៅក្នុងកិច្ចសម្ភាសន៍កាលពីពេលថ្មីៗនេះ ខៀវ សំផន បានទទួលស្គាល់បន្ថែមទៀតថា ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យចូលសហករណ៍។ ដំបូងទាល់តែបង្ខំសិនឲ្យចូលសហករណ៍ ធ្វើឲ្យសហករណ៍តាមស្ម័គ្រចិត្ត ឲ្យធ្វើសហករណ៍ស្ម័គ្រចិត្ត គ្មានអ្នកណាចូលទេ។ ដូច្នេះទាល់តែបង្ខំសិន។

មេធាវីការពារក្ដីនឹងតវ៉ា ការបង្កើតសហករណ៍ គឺជាផ្នែកមួយនៃកម្មវិធីស្របច្បាប់ ដើម្បីដោះ

ស្រាយភាពមិនស្មើគ្នាក្នុងសង្គម និងការកេងប្រវ័ញ្ចកសិករពីសំណាក់វណ្ណៈជិះជាន់។ ប៉ុន្តែបើពិនិត្យលើរៀបប្រព្រឹត្តិនៃសហករណ៍ទាំងនោះ គឺវាផ្ទុយនឹងការអះអាងនេះស្រឡះ។ ឆ្លងតាមសេចក្ដីសម្រេចរបស់គណៈកម្មាការមជ្ឈិម នៅក្នុងខែឧសភា ឆ្នាំ១៩៧២។ ការដាក់ឲ្យទៅជាសមូហភាពត្រូវបានអនុវត្តដោយបង្ខំ។ ចាប់តាំងពីពេលនោះមកការប្រឆាំងនឹងកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់រំដោះ គឺមានន័យថាស្លាប់។ គោលបំណងចម្បង និងពិតប្រាកដនៃការបង្កើតសហករណ៍ គឺដើម្បីរក្សាអំណាចរបស់អ្នកដឹកនាំបក្សតាមរយៈការដាក់ឲ្យប្រជាជនទាំងអស់ក្លាយជាទាសករ។ ផ្ទុយទៅវិញ អ្វីដែលក្រុមមេធាវីការពារក្ដីនេះបានអះអាង នៅមុនឆ្នាំ១៩៧៥ បក្សកុម្មុយនីសកម្ពុជាមានគោលនយោបាយមួយពាក់ព័ន្ធនឹងការសម្លាប់ទាំងយោធា និងមន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ។

[១០:៥១:០៦]

សាក្សីមួយរូបដែលបានលើកឡើងនៅក្នុងកំណត់ហេតុស្តួរចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានឯកសារ E3/5636ថា នៅឆ្នាំ១៩៧៤ លោកជាប្រធានការិយាល័យស្រុកកែវសីមា។ គាត់ជាមនុស្សដែលស័ក្តិសមបំផុតក្នុងការបំភ្លឺអំពីប្រវត្តិប្រតិបត្តិការរបស់សហករណ៍ នៅឆ្នាំ១៩៧៤ និងការសម្លាប់ជួរមន្ត្រី លន់ នល់ មន្ត្រីរដ្ឋការស៊ីវិល និងអ្នកដែលប្រឆាំងសហករណ៍។ គាត់មានប្រសាសន៍ថា៖ "ក្នុងឆ្នាំ១៩៧៤ មេដឹកនាំប្រជាជនមករស់នៅតាមសហករណ៍ ការសម្លាប់មនុស្សចាប់ផ្តើមកើតឡើង។ ប្រជាជនធម្មតាមិនសូវស្លាប់ច្រើនទេ ស្លាប់ច្រើនតែអតីតទាហានដែលពាក់ស័ក្តិវរសេនីយ៍ត្រី អនុសេនីយ៍ឯក"។

លោក ស្សូត ធ្វើសក្ខីកម្មពាក់ព័ន្ធនឹងការកើតឡើង និងការប្រើហិង្សាលើប្រជាជនធម្មតា និងសមូហភាវូបនីយកម្មដោយបង្ខំថា ភាពតានតឹងបានកើតឡើង។ វាផ្នែកមួយនៃប្រធានបទដែលកើតដែលយើងកំពុងពិភាក្សានេះ។ មូលហេតុចម្បងគឺមកពីការកើនឡើងនៃកងកម្លាំងខ្មែរដែលឈានដល់កម្រិតមួយ លែងចាំបាច់យកចិត្តកសិករតទៅទៀតហើយ គឺលែងចាំបាច់ប្រើវិធីស្លូតដើម្បីយកការគាំទ្រពីកសិករទៀតដែរហើយដែរ។

[១០:៥២:៤៨]

នៅក្នុងសក្ខីកម្មរបស់លោក ស្ទីវហ្វិន ហេដឌ័រ គាត់យល់ស្របនឹងឃ្លាមួយខាងក្រោមក្នុងសៀវភៅរបស់គាត់ស្ដីពីលទ្ធិកុម្មុយនីស្តកម្ពុជាដែលលើកឡើងអំពីការប្រើអំពើហិង្សា -- ប្រើប្រាស់ហិង្សា និងកាប់សម្លាប់ដោយបក្សក្នុងរូបភាពទូលំទូលាយនៅក្នុងអំឡុងឆ្នាំ១៩៧៥។ អត្ថបទនោះបានសរសេរថា៖

នៅក្នុងឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ប្រជាជនភាគច្រើននៅតែមានភាពសង្ស័យមិនទុកចិត្ត និងភ័យខ្លាចលើបដិវត្តន៍ដែលរក្សាជំហររបស់ខ្លួនតាមរយៈការគំរាមកំហែង និងការកាប់សម្លាប់។ នៅពេលបក្សកុម្មុយនីស្តកម្ពុជាបានបណ្តេញកងទ័ពវៀតណាមចេញនៅក្នុងឆ្នាំ១៩៧២ និងក្នុងឆ្នាំ១៩៧៣ បក្សបានជំនួសការត្រួតត្រាផ្នែកយោធាខ្លួនតាមការបង្ខិតបង្ខំកាន់តែខ្លាំងឡើង ដើម្បីឲ្យប្រជាជនគោរពតាមការទាមទាររបស់ពួកគេ។ បក្សកុម្មុយនីស្តកម្ពុជាកាន់តែប្រើហិង្សា និងកៀបសង្កត់កាន់តែខ្លាំងឡើងក្រោយពាក់កណ្តាលឆ្នាំ១៩៧៣ នៅពេលដែលខ្លួនធ្វើឲ្យគោលនយោបាយរបស់ខ្លួន។

[១០:៥៤:០៦]

សហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះនូវភស្តុតាងសម័យនោះដែលបង្ហាញពីភាពឃោរឃៅនៃការគ្រប់គ្រងរបស់ខ្មែរក្រហមនៅក្នុងតំបន់ដែលគេហៅថាតំបន់រំដោះ។ របាយការណ៍ ទូរលេខសម្ងាត់របស់សហរដ្ឋអាមេរិកបានសរសេរបញ្ជាក់អំពីចំណុចនេះ។ នៅក្នុងឆ្នាំ១៩៧៤ ព្រះភិក្ខុ ភូ អាត ព្រះចៅអធិការវត្តតាភើយ បានរត់ភៀសព្រះកាយទៅកាន់ប្រទេសឡាវ ជាទីដែលលោកបានផ្តល់បទសម្ភាសន៍។ របាយការណ៍នោះបានលើកឡើងថា តាមសង្ឃដីការរបស់សង្ឃ អង្គនេះថា ព្រះអង្គអាចរត់ភៀសព្រះកាយពីតំបន់រំដោះនោះនៅពេលយប់។ ប៉ុន្តែនៅពេលថ្ងៃវិញមានការតាមដានយ៉ាងតឹងរ៉ឹងជាប្រចាំ។ ព្រះអង្គបានមានសង្ឃដីការបន្តទៀតថា ពាក់ព័ន្ធនឹងបញ្ជាយោធាវិញមានបញ្ជាពិសេសពីលោកខៀវ សំផន ដែលបានហាមឃាត់ប្រជាជន រស់នៅក្នុងតំបន់ដែលមានព្រំប្រទល់ជាប់នឹងប្រទេសឡាវមិនឲ្យមានការគោរពចំពោះសម្តេច សីហនុ អ្នកដែលមិនគោរពតាមបទបញ្ជានេះនឹងត្រូវសម្លាប់ចោលយ៉ាងព្រៃផ្សៃ។

សហករណ៍ក៏ត្រូវបានប្រើប្រាស់ជាឧបករណ៍ដើម្បីវាយប្រហារ និងកម្ទេចខ្មាំង ទាំងខ្មាំងនៅទីជនបទ ទាំងខ្មាំងនៅទីក្រុង។ នៅក្នុងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជានៅខែ ឧសភា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា "រំឭកខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ" បានសរសេរថា៖ ដោយផ្អែកលើសហករណ៍កសិករ បក្សមិនគ្រាន់តែវាយរំលំ វណ្ណៈសក្តិភូមិ ម្ចាស់ដីទេ បក្សវាយទាំងវណ្ណៈនាយទុននៅទីក្រុង និងកសិករ មាននៅជនបទទៀត។ សក្តិភូមិ ម្ចាស់ដី កសិករ មានរហូតរបបឯកជនផ្សេងៗទាំងអស់ក៏ត្រូវវាយឲ្យរំលំរលាយ។

ឥឡូវនេះខ្ញុំសូមងាកមកមើលលើភស្តុតាងបង្ហាញការបង្កើតចេតនាឧក្រិដ្ឋ ស្តីពីការអនុវត្ត ការជម្លៀសប្រជាជនដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១០:៥៦:២៩]

ជាថ្មីម្តងទៀត ភស្តុតាងនៃអំពើឧក្រិដ្ឋ និងមូលហេតុដើមចមដែលបានអត្ថិភាពមុនឆ្នាំ១៩៧៥ ជាចំណុចគន្លឹះសំខាន់។ ហេតុការណ៍ទាំងនេះគឺ ដើមហេតុនាំមកដល់ការជម្លៀសក្រុងភ្នំពេញដោយបង្ខំ។ ហើយវាបង្ហាញនៅដំណើរការស៊ីសង្វាក់នៃទង្វើឧក្រិដ្ឋ។ ដូចលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ បានផ្តល់សក្ខីកម្មរួចហើយ របៀបអនុវត្តដូចៗគ្នានៃការជម្លៀសប្រជាជនចេញដោយបង្ខំពីទីក្រុង និងពីទីប្រជុំជននានាបានកើតឡើងតាំងពីមុនឆ្នាំ១៩៧៥ និងបានឈានដល់ការអនុវត្តចុងក្រោយ និងធំបំផុត គឺការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ។ ភស្តុតាងនានាដែលបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះសុទ្ធតែបានបង្ហាញថា ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសប្រជាជនចេញដោយបង្ខំពីទីប្រជុំជន និងទីក្រុងទៅកាន់តំបន់ដែលត្រួតត្រាដោយកម្លាំងបដិវត្តន៍ត្រូវបានអនុម័ត និងអនុវត្តចាប់តាំងពីដើមទសវត្សរ៍៧០មក។ នៅក្នុងអំឡុងពេលនោះនៅពេលដែលកម្លាំងបក្សកុម្មុយនីស្តដណ្តើមកាន់កាប់បានទីប្រជុំជនដែលសត្រូវរបស់ខ្លួនពោល គឺរបបសាធារណរដ្ឋខ្មែរធ្លាប់បានគ្រប់គ្រង។ ពួកគេបានជម្លៀសប្រជាជនដោយបង្ខំ។

[១០:៥៨:០៨]

ការជម្លៀសប្រជាជនដោយបង្ខំពីទីប្រជុំជនរបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥ ត្រូវបានរៀបចំឡើងដើម្បីកាត់ផ្តាច់កុំឱ្យកម្លាំងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរមានមូលដ្ឋានគាំទ្រ និងផ្លាស់ប្តូរទីលំនៅដោយបង្ខំដល់ប្រជាជនដែលត្រូវជម្លៀសទៅកាន់សហករណ៍ជនបទនៅក្នុងតំបន់រំដោះ ដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា ដោយដាក់ប្រជាជនទាំងនោះទៅជាទាសករ និងប្រើប្រាស់ជាមូលដ្ឋានផលិតកម្មសម្រាប់បម្រើបដិវត្តន៍។ ការជម្លៀសក៏ធ្វើឡើងរួមជាមួយការកាប់សម្លាប់ផងដែរ។ ការជម្លៀសទាំងនេះគឺជាអំពើឧក្រិដ្ឋប្រឆាំងនឹងប្រជាជនរាប់ពាន់នាក់ដែលប្រព្រឹត្តឡើងនៅក្នុងលក្ខណៈរៀបចំ និងដោយមានការសម្របសម្រួលគ្នា ព្រមទាំងដោយមានការបញ្ជាពីថ្នាក់កំពូលបំផុតរបស់បក្ស។ នៅក្នុងសុន្ទរកថាមួយដែលបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្តប្រចាំខែធ្នូ ឆ្នាំ១៩៧៦ និងខែមករា ឆ្នាំ១៩៧៧ នួន ជា បានពិព័ណ៌នាអំពីការជម្លៀសប្រជាជនដោយបង្ខំនៅមុនឆ្នាំ១៩៧៥ និងបានពន្យល់អំពីមាគ៌ាបក្សក្នុងការដណ្តើមប្រជាជន និងពង្រឹងប្រជាជនពីខ្មាំង។ គាត់សរសេរថា៖ “វាយខ្មាំងខាងនយោបាយលើកឧទាហរណ៍តែមួយគឺដណ្តើមប្រជាជន។ នៅក្នុងសាកលលោក គេមិនដែលដណ្តើមប្រជាជនទេ។ មាគ៌ាយើងគឺដណ្តើមប្រជាជន ម្នាក់ក៏យក ពីរនាក់ក៏យក មួយរយនាក់ក៏យក មួយពាន់នាក់ក៏យក រហូត

ដល់ដណ្តើមប្រជាជនពីភ្នំពេញទៀត”។ មាគ៌ាពង្រឹងប្រជាជនពីខ្មាំងមកបក្ស គឺត្រឹមត្រូវណាស់ក្នុងសាកលលោកគ្មានយ៉ាងនេះទេ។ ឧទាហរណ៍៖ វាយខាងបាណាមនៅឆ្នាំ១៩៧៣ យកទាំងអស់ក្នុងក្រុងបាណាម បញ្ចេញទាំងអាណិកជនវៀតណាម អាណិកជនចិន ទាំងទាហាន ទាំងប៉ូលីសយកទាំងអស់។ ពង្រឹងប្រជាជនពីខ្មាំង។ លោក ស្ទីវហ្វិន ហេដឌ័រ ធ្លាប់បានរស់នៅក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៣ ដល់ដើមខែមេសា ឆ្នាំ១៩៧៥ គាត់បានបញ្ជាក់ក្នុងសក្ខីកម្មរបស់គាត់ ហើយថាពាក្យ “ពង្រឹងប្រជាជនពីខ្មាំងត្រូវបានប្រើប្រាស់ជាញឹកញយនៅក្នុងការផ្សាយវិទ្យុខ្មែរក្រហមមុនបែកភ្នំពេញ”។

[១១:០០:៥៩]

មានចំណុចសំខាន់ដូចគ្នាមួយរវាងព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ និងការជម្លៀសទីក្រុងនានានៅក្នុងខែមេសា ឆ្នាំ១៩៧៥ ការជម្លៀសត្រូវបានធ្វើឡើងដោយបង្ខំ និងមិនគិតពីការឈឺចាប់មកលើជនរងគ្រោះ។ គណៈមជ្ឈិមបក្សបានទទួលស្គាល់នូវការពិតនេះក្នុងលេខបោះពុម្ពផ្សាយក្នុងខែកក្កដា ឆ្នាំ១៩៧៣ នៃទង់បដិវត្តដែលសរសេរថា៖ “ក្នុងការជម្លៀសប្រជាជនពីតំបន់ខ្មាំងមកតំបន់រំដោះបើយើងគ្មានទស្សនៈមហាជនរឹងប៉ឹងទេ នោះមុខជាមិនប៉ានដកប្រជាជនមកទេ ដោយខ្លាចប្រជាជនទ្រាំទ្រការលំបាក ខ្វះខាតសព្វមិនបាន នេះម៉្យាង ហើយម៉្យាងទៀតខ្លាចប្រជាជនក្នុងតំបន់រំដោះនានារ៉ាប់រងជួបប្រជាជនជម្លៀសមិនបាន។ តែដោយយើងមានទស្សនៈមហាជនរឹងប៉ឹង ជឿជាក់លើមហាជន ប្រជាជនថា គេអាចធ្វើអ្វីៗបានទាំងអស់ ដូច្នេះទោះក្នុងសភាពដែលយើងកំពុងខ្វះខាតស្រូវ អង្ករដូចសព្វថ្ងៃនេះក៏ដោយក៏យើងប៉ានដកប្រជាជនមកច្រើនថែមទៀត”។

អង្គជំនុំជម្រះជាទីគោរព! ក្នុងន័យនេះបក្សបានទទួលស្គាល់ថា ការឈឺចាប់ខ្លោចផ្សាបានកើតឡើងដោយជៀសមិនរួច ដែលបណ្តាលមកពីការជម្លៀសដោយបង្ខំទាំងនេះ ហើយបក្សពុំបានចាត់វិធានការបន្ថយការឈឺចាប់ខ្លោចផ្សានោះក្នុងកម្រិតអប្បបរមាឡើយ។ ការឈឺចាប់ខ្លោចផ្សាលើមនុស្សពុំដែលត្រូវបានគេយកទៅពិចារណា គិតគូរម្តងណាឡើយ។ ហើយមេដឹកនាំបក្សក៏ពុំដែលពិនិត្យ ឬពិចារណាលើការអនុវត្តទាំងនោះឡើងវិញទេ។ បើទោះជាបណ្តាលឲ្យមានការឈឺចាប់នេះក៏ដោយ។

[១១:០៣:០៥]

ការឈឺចាប់ធ្ងន់ធ្ងរដែលកើតមានមកលើប្រជាជនស៊ីវិលនៅក្នុងអំឡុងពេលជម្លៀសមុនឆ្នាំ១៩៧៥ បានបង្ហាញតាមរយៈសក្ខីកម្មរបស់សាក្សី នូ ម៉ៅ។ ខ្ញុំដូចបានបញ្ជាក់ជូនខាងលើ លោក នូ ម៉ៅ សមាជិកគណៈឃុំមួយរូបក្នុងស្រុកឧដុង្គក្នុងឆ្នាំ១៩៧៤ គាត់បានជម្រាបនៅក្នុងសក្ខីកម្មរបស់គាត់ដូចខា

ងក្រោម៖ "អង្កាល់ហ្នឹងខ្ញុំនៅខាងឃុំជើងរាស់ ស្រុកឧដុង្គជាមួយគ្នា។ គេថ្នាក់លើ គេលើកឡើងថា យើងត្រូវទទួលប្រជាជនពីឧដុង្គ ចាប់បានពីឈ្លើយសឹកមួយចំនួន ប្រមូលជម្លៀសប្រជាជនថា ប្រជាជនទៅលើបញ្ជូនទៅតាមផ្លូវអមលាំងហ្នឹង កន្លែងហ្នឹងជាកន្លែងដុះសុទ្ធព្រៃទេ មានតែព្រៃទេ រកស៊ីដីកតែក្តិបដំឡូង ប្រជាជនអង្កាល់នុំងជម្លៀសទៅអត់មានបាយមានទឹកទេ អ៊ីចឹងងាប់ពីព្រោះអត់បាយ ស្លាប់ដោយអត់បាយហូរហែ ព្រោះពួកគេពុំមានថ្នាំសង្កូវ"។ រៀបរាប់ពីការជម្លៀសជាទូទៅនៅមុនឆ្នាំ១៩៧៥ នូ ម៉ៅ បានផ្តល់សក្ខីកម្មទៀតថា "អង្កាល់ណោះវាអត់ទាន់ជម្លៀសមែន ប៉ុន្តែគ្រាន់តែវាវ៉ៃៗកន្លែងណាក៏ជម្លៀសប្រជាជនទៅកន្លែងនុំង ទាំងកងឈ្លើយសឹកក៏ចាប់យកទៅ ទាំងប្រជាជនក៏វាយកទៅដែរទៅៗខាងលើ។ ទី១ វាមិនមែនគិតគូរពីរឿងស្បៀងអាហារឲ្យប្រជាជនស៊ីទេ វាទៅចង់បង្អត់បាយ ដល់អត់បាយស៊ីស្អីស៊ីទៅ ស៊ីក្តួច ស៊ីគល់ប្រង់ក៏ស៊ីទៅ។ រឿងអង្ករ អារឿងស្លឹកគ្រៃអីអត់មានទេ វាត្រូវតែងាប់មិនវ៉ៃចោលមែន ប៉ុន្តែវាត្រូវតែងាប់ ខ្លះរស់ដែរ ខ្លះក៏បាត់ទៅ"។

ការធ្វើបាបលើប្រជាជនទីក្រុងដោយបក្សកុម្មុយនីស្តកម្ពុជាមានលក្ខណៈហិង្សា និងរើសអើងដោយឯងៗតែម្តង។ នួន ជា និង ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតសម្រេចថាទីក្រុងគឺជាមូលដ្ឋានសំខាន់របស់ពួកខ្មាំងបដិវត្តន៍។

[១១:០៥:៣៦]

នៅក្នុងបទសម្ភាសន៍មួយជាមួយប្រតិភូដាណឺម៉ាកក្នុងឆ្នាំ១៩៧៨ នួន ជា បាននិយាយដូចខាងក្រោម៖ "ស្ថានភាពនៅក្នុងទីក្រុង និងជនបទមិនដូចគ្នាទេ។ នៅជនបទស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនមានការលំបាក ប៉ុន្តែមិនសូវមានសត្រូវទេ។ នៅទីក្រុងវិញស្ថានភាពជីវភាពរស់នៅល្អប្រសើរជាង ប៉ុន្តែមានសត្រូវច្រើន"។

នៅក្នុងក្រសែភ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជននៅក្នុងក្រុងបានក្លាយខ្មាំងសាមញ្ញដោយសារនយោបាយ។ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ បានផ្តល់សក្ខីកម្មដូចខាងក្រោម៖ "តាមការឲ្យនិយមន័យរបស់ពួកគេ ប្រជាជននៅក្នុងទីក្រុងគឺជាខ្មាំង។ នៅក្នុងក្រសែភ្នែករបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ទីក្រុងជាកន្លែងពួកសក្តិភូមិ និងពួកចក្រពត្តិនិយមរស់នៅ។ ទីក្រុងជាកន្លែងដែលមានរឿងអាក្រក់ៗជាច្រើនកើតឡើង"។ សាក្សី ឈូក រីន មេបញ្ជាការខ្មែរក្រហមប្រចាំភូមិភាគនិរតី ដែលខ្ញុំបានលើកឡើងខាងបានបញ្ជាក់ថា គាត់ក្នុងនាមជាយោធាម្នាក់បានដឹងច្បាស់តាំងពីមុនឆ្នាំ១៩៧៥មកម្ល៉េះថាអ្នករស់នៅទីក្រុងគឺសុទ្ធតែជាខ្មាំង។

[១១:០៧:០០]

បក្សកុម្មុយនីស្តកម្ពុជាបានបំពាក់មនោគមន៍វិជ្ជាដល់កម្មាភិបាល និងសមាជិកយោធារបស់ខ្លួនថា ទីក្រុងពោរពេញទៅដោយអំពើអនាចារ អសីលធម៍ និងអំពើថោកទាបអាក្រក់ ហើយខ្មាំងតាំងទីលំនៅនៅក្នុងទីក្រុង។ រៀបរាប់ពីមនោគមន៍វិជ្ជាបែងចែក និងរើសអើងនេះលោក ហ្វីលីព ស្ប្រូត បានសរសេរថា៖ "ទាហានត្រូវបានគេជំរុញឲ្យកាត់ចិត្តឲ្យដាច់ចំពោះខ្មាំង ខ្មាំងដែលរួមបញ្ចូលទាំងអ្នកទីក្រុងដែលត្រូវជម្លៀសចេញផង"។ គាត់បានពន្យល់បន្ថែមទៅលើចំណុចនេះ នៅក្នុងការធ្វើសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះដោយបញ្ជាក់ថា "វាមានភាពស៊ីសង្វាក់គ្នានៅក្នុងរឿងទាំងអស់នេះ យើងបាននាំគ្នានិយាយអំពីហេតុផលដែលគេត្រូវតែធ្វើបែបនេះ ដើម្បីសម្រេចគោលដៅរបស់គេ។ ការធ្វើការញែកឲ្យដាច់ស្រឡះរវាងខ្មាំងនិងខ្លួនយើង និងអំពីអ្នកដែលជ្រើសរើសដើរចេញ និងបន្តនៅក្នុងទីក្រុងជាជាងចូលបដិវត្តន៍ តែគេមិនទុកចិត្ត"។

ការធ្វើបាបដោយរើសអើងលើប្រជាជនទីក្រុង គឺជាប្រធានបទដែលខ្ញុំនឹងត្រឡប់មកលើកឡើងសាជាថ្មីនៅក្នុងផ្នែកដែលនៅសល់ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ វាមានសារសំខាន់ដែលយើងត្រូវស្វែងយល់អំពីចេតនាឧក្រិដ្ឋនៅពីក្រោយការជម្លៀសចេញពីទីក្រុង និងទីប្រជុំជនដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា និងជាពិសេសការជម្លៀសនាខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងខែកញ្ញា ក្នុងឆ្នាំ១៩៧៣ កងកម្លាំងខ្មែរក្រហមបានចាប់យកទីរួមខេត្តកំពង់ចាមមួយផ្នែក ហើយភ្លាមនោះបានឈានទៅរកការបញ្ជូនដោយបង្ខំនូវប្រជាជនប្រមាណ១៥.០០០នាក់ ទៅតាមតំបន់ដែលគ្រប់គ្រងដោយពួកគេ។

[១១:០៩:០៣]

លោក ស៊្វីរិន ហេដឌ័រ បានចុះទៅដល់ខេត្តកំពង់ចាម ដើម្បីសម្ភាសប្រជាជននៅទីនោះក្រោយកងកម្លាំងសាធារណរដ្ឋខ្មែរបានគ្រប់គ្រងខេត្តនោះសាជាថ្មី។ អ្នកដែលត្រូវបានលោកសម្ភាសរាយការណ៍ថា៖ "ប្រជាជនបានត្រូវជម្លៀសដោយខ្មែរក្រហមទៅប៉ែកបស្ចិមប្រទេស ហើយអ្នកខ្លះត្រូវបានគេសម្លាប់នៅទីនោះតែម្តង"។ លោក ហេដឌ័រ ក៏បានផ្តល់សក្ខីកម្មថា លោកបានដឹងពីអ្នកដែលត្រូវបានលោកសម្ភាសថា៖ "អ្នកដែលត្រូវបានសម្លាប់គឺជាអ្នកសាធារណរដ្ឋខ្មែរ អ្នករដ្ឋការ និងជាពិសេសបុគ្គលិកយោធា។

កែ ពក អនុសេនាភូមិភាគឧត្តរបានបញ្ជាក់នៅក្នុងប្រវត្តិរូបរបស់លោក ដែលត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ថាលោកនិងមេរបស់លោក កុយ ធួន បានជួយសម្រួលដល់ការវាយប្រហារលើ

ខេត្តកំពង់ចាម ក្រោមបញ្ជារបស់មជ្ឈិមបក្ស។

លោក ហ្វ្រង់ស្វ័រ ប៉ុងស្វង់ ដែលបានរស់នៅក្នុងប្រទេសកម្ពុជារហូតដល់ខែមេសា ឆ្នាំ១៩៧៥ បានបញ្ជាក់នៅក្នុងចម្លើយផ្ដល់ជូនសហចៅក្រមស៊ើបអង្កេតថា ពិតជាមានការជម្លៀសខេត្តកំពង់ចាម ដោយបង្ខំនៅក្នុងឆ្នាំ១៩៧៣មែន។ លោកក៏បានផ្ដល់សក្ខីកម្មអំពីការជម្លៀសប្រជាជនបុសខ្នុរដោយបង្ខំ ពីសំណាក់ខ្មែរក្រហមផងដែរ ដែលស្រុកនេះនៅក្នុងខេត្តកំពង់ចាម។ លោកបានរៀបរាប់ដូចខាងក្រោម៖

"យើងដឹងច្បាស់ថា នៅពេលទាហានខ្មែរក្រហមចាប់យកភូមិមួយ មានផ្ទះសម្បែងនៅក្នុងភូមិ នោះត្រូវបានដុតចោល ប្រធានភូមិត្រូវបានសម្លាប់ចោល ហើយប្រជាជនត្រូវបានគេជម្លៀសនៅក្នុងព្រៃ ប្រជាជនត្រូវបានជម្លៀស ចំណែកប្រធានក្រុមត្រូវបានសម្លាប់ចោល"។ ហើយរឿងនេះគ្មានអ្វីថ្មីឡើយ ហេតុការណ៍នេះបានកើតឡើងរួចហើយ ហើយតាំងពីឆ្នាំ១៩៧៣ ហើយនរណាៗក៏បានដឹងច្បាស់ដែរ។

[១១:១១:១៤]

លោក លោកស្រីចៅក្រម ក៏បានបើកសវនាការស្ដាប់ភស្តុតាងរៀបរាប់ដោយសាក្សីជំនាញ និង សាក្សីផ្ទាល់អំពីការជម្លៀសក្រុងឧដុង្គ ដោយបង្ខំក្នុងទ្រុងទ្រាយធំ ក្នុងខែមីនា ឆ្នាំ១៩៧៤។ ការជម្លៀស ដោយបង្ខំនេះ គឺជាហេតុការណ៍សំខាន់ ព្រោះវាបានកើតឡើងចំពោះដែលកងកម្លាំងបក្សកុម្មុយនីស្ត កម្ពុជាកំពុងសម្រុកចូលមកកៀកក្រុងភ្នំពេញ ហើយការដួលរលំរបស់សាធារណរដ្ឋខ្មែរនឹងកើតឡើងក្នុង ពេលមួយពព្រិចភ្នែកទៀតតែប៉ុណ្ណោះនាពេលនោះ។ ការជម្លៀសក្រុងឧដុង្គដោយបង្ខំ ក្លាយជាគំរូដែល មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចថានឹងធ្វើដូចគ្នាសម្រាប់ក្រុងភ្នំពេញ។

នៅពេលសួរដេញដោលអំពីសារៈសំខាន់នៃការជម្លៀសនៅក្នុងឧដុង្គដោយបង្ខំ សាស្ត្រាចារ្យ ឆេនដ័ល័រ បានផ្ដល់សក្ខីកម្មថា៖ "នៅក្នុងឆ្នាំ១៩៧៥ វាហាក់ដូចជាបង្ហាញឲ្យយើងអ្នកសង្កេតការណ៍ លើប្រទេសកម្ពុជាឃើញថា វាគឺជាការបោះជំហានទៅមុខមួយដែលពុំដែលធ្លាប់មានពីមុនមក។ យើង នៅពេលនេះ មើលឃើញពីអ្វីៗដែលលេចចេញឲ្យយើងមើលពីក្រោយឆ្នាំ១៩៧៥ រួមមានតាមរយៈ ឯកសារជាដើម។ល។ ថាប្រសិនបើអ្នកមើលទៅនោះ និន្នាការនេះត្រូវបានទាយទុករួចជាស្រេចថា វាមិនត្រឹមតែកើតឡើងក្នុងខេត្តតាកែវ និងក្រុងឧដុង្គប៉ុណ្ណោះទេ ប៉ុន្តែវាក៏កើតឡើងនៅក្នុងទីរួមខេត្ត ក្រចេះដែលត្រូវបានជម្លៀសផងដែរ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច និងនៅប៉ែកខាង ជើងៗនៃខេត្តស្ទឹងត្រែង"។

[១១:១៣:០៥]

កងកម្លាំងខ្មែរក្រហមពីភូមិភាគនិរតី និងឧត្តរបានមកកាន់កាន់ឧដុង្គដោយជោគជ័យនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៤។ ការវាយប្រហារដែលត្រូវបានសម្របសម្រួលដោយ សុន សេន ដែលជានាយអគ្គសេនាធិការ និងជាសមាជិកមជ្ឈិមបក្ស គណៈកម្មការមជ្ឈិម ចំពោះខេត្តកំពង់ចាម កែ ពក គឺជាអ្នកចូលរួមផ្ទាល់ក្នុងការវាយប្រហារទៅលើក្រុងឧដុង្គ។

ក្រោយពីក្រុងឧដុង្គបែកភ្លាម ក្រុងនេះត្រូវបានជម្លៀសដោយបង្ខំ ដោយពួកខ្មែរក្រហមដែលបានបណ្ដេញប្រជាជនប្រមាណ២០.០០០នាក់ ចេញពីទីក្រុងដូចហ្វូងគោ។ ចំណែកទាហានសាធារណរដ្ឋខ្មែរត្រូវគេសម្លាប់ចោល។ នៅក្នុងសក្ខីកម្មរបស់លោក ហ្វីលីព ស្បូត បានបញ្ជាក់នៅការរៀបរាប់ដូចនៅថ្មីៗ និងគួរឲ្យជឿជាក់អំពីហេតុការណ៍នេះ ដោយផ្អែកលើកិច្ចសម្ភាសន៍ដែលលោកបានធ្វើឡើងជាមួយនឹងសាក្សីផ្ទាល់ភ្នែកៈ ទាហានរដ្ឋាភិបាល និងជនអៀសខ្លួនស៊ីវិលរាប់សិបពាន់នាក់ត្រូវបានសម្លាប់រង្គាល។ ក្រោយមកគេបាននិយាយថា ទាហានទាំងនេះជាច្រើននាក់បានបង្វែរចុងកាំភ្លើងរបស់ពួកគេមករកគ្រួសាររបស់ពួកគេវិញ។ មុនពេលសម្លាប់ខ្លួនឯងដើម្បីជៀសវាងការចាប់ខ្លួន និងការធ្វើទារុណកម្ម។ ប្រជាជននៅកន្លែងនោះ ប្រហែល២០.០០០នាក់ ត្រូវបានឡោមព័ទ្ធ និងបណ្ដើរទៅព្រៃប៉ាល់ហាល មុនពេលត្រូវបានគេយកទៅដាក់នៅសហករណ៍នៅភូមិភាគពិសេសនិងភូមិភាគនិរតី។ មន្ត្រីទាហាននៅក្នុងឯកសណ្ឋានត្រូវបានគេបំបែកចេញពីអ្នកផ្សេងទៀត ហើយត្រូវបានគេបណ្ដើរចេញទៅដើម្បីយកទៅសម្លាប់ចោល។

[១១:១៥:០១]

ផលវិបាកដែលកើតចេញដោយផ្ទាល់ពីការវាយប្រហារនេះត្រូវបានលោក ស្ទីវហ្វិន ហេដឌ័រ មើលឃើញដោយផ្ទាល់ភ្នែក ដែលលោកបានធ្វើដំណើរទៅឧដុង្គបន្ទាប់ពីពេលនោះបន្តិចមក។ លោកបានរៀបរាប់ថា ក្រុងនោះជាក់ស្ដែងទៅគ្មានមនុស្សសោះ។ នៅថ្ងៃនោះសក្ខីកម្មរបស់លោក ស្ទីវហ្វិន ហេដឌ័រ ជម្រាបជូនលោក លោកស្រីចៅក្រមថា កងកម្លាំងខ្មែរក្រហមដែលបានចូលដល់ឧដុង្គបានសម្លាប់មនុស្សមួយចំនួន និងនាំយកប្រជាជនដែលនៅសល់ស្ទើរតែទាំងអស់ចេញពី ទៅកាន់ទីជនបទ។ លោកហេដឌ័រ ក៏បានផ្ដល់សក្ខីកម្មថា “ប្រភេទមនុស្សដែលរងទទួលទុក្ខនេះគឺជាអ្នកសាធារណរដ្ឋខ្មែរ អ្នករដ្ឋការ និងជាពិសេសបុគ្គលិកយោធា”។

យោងតាម ហ្វីលីព ស្បូត ការកាន់កាប់សម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនៅឧដុង្គ “គឺស៊ីសង្វាក់គ្នានឹងអ្វីដែលបានកើតឡើងនៅមុន និងអ្វីដែលបានកើតឡើងក្រោយមកទៀត”។ ទាំងនេះគឺជាសុទ្ធតែជា

ភស្តុតាងគួរឲ្យជឿជាក់ពាក់ព័ន្ធនឹងគោលនយោបាយដ៏រឹងមាំរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការជម្លៀសដោយបង្ខំព្រមទាំងការកំណត់គោលដៅជាលក្ខណៈប្រព័ន្ធ និងការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរផងដែរ។

ភស្តុតាងនេះបង្ហាញឲ្យឃើញពីភាពផ្ទុយគ្នាស្រឡះទៅអ្វីដែលក្រុមមេធាវីការពារអះអាង។ នៅក្នុងសន្ទរកថាមួយថ្លែងក្នុងប្រទេសកូរ៉េខាងជើង នាដើមខែមេសា ឆ្នាំ១៩៧៤ ខៀវ សំផន បានគាំទ្រយ៉ាងមានមោទនភាពចំពោះការកម្ទេចឧដុង្គ និងបានអួតប្រាប់រឿងនេះដល់សារព័ត៌មានអន្តរជាតិដែលមានវត្តមាននៅទីនោះថា៖ “ថ្ងៃទី១៨ ខែមីនា កន្លងទៅនេះកងទ័ពប្រជាជនរំដោះជាតិកម្ពុជារបស់យើងបានរំដោះទីក្រុងមួយទៀត គឺទីក្រុងឧដុង្គ ដោយកម្ទេចចោលឲ្យអស់នូវកងទ័ពអាយ៉ងទាំងអស់ដែលនៅទីនោះ ហើយនិងកម្លាំងជំនួយពួកវា ដែលនៅក្នុងនោះខ្មាំងចំនួន ៥០០០នាក់ត្រូវបានកម្ទេច ហើយ ១៥០០នាក់ត្រូវចាប់បាន។

[១១:១៧:៣៦]

ភស្តុតាងរបស់លោក នូ ម៉ៅ ក៏បានរៀបរាប់អំពីមូលដ្ឋានឃុំរៀបចំអបអរសាទរជ័យជម្នះមួយនៃការជម្លៀសដោយបង្ខំ និងការបញ្ជូនប្រជាជនចូលព្រៃ។ ការជម្លៀសឧដុង្គក៏ត្រូវបានបញ្ជាក់ដោយភស្តុតាងរបស់សាក្សី វ៉ាចាម តុន ហៅ ភី ភួន ផងដែរ។ លោកគឺជាកងការពាររបស់ ប៉ុល ពត ដែលបានធ្វើដំណើរឆ្លងកាត់តំបន់នោះប្រហែលជាមួយសប្តាហ៍ក្រោយការជម្លៀស។ ហើយបានឃើញថាក្រុងនោះគ្មានមនុស្សនៅឡើយ។ ខាងក្រោមនេះគឺជាភស្តុតាងដែលលោកបានឆ្លើយ៖

“ខ្ញុំចូលទៅស្ងាត់ជ្រាប អត់មានប្រជាជនទេ ស្ងាត់ជ្រាបតែម្តង។ ដល់ឃើញគាត់នែ៎ -- ភាគច្រើនបើខាងលិចទន្លេគឺមកតាមផ្លូវអមលាំងហ្នឹង ផ្លូវអមលាំង ត្រពាំងជោរ ឱរ៉ាល់ហ្នឹង គាត់មកផ្លូវនុ៎ងច្រើន។ ហើយមកក្បែរៗហ្នឹងគឺថា គ្រាន់តែចេញពីទីរួមខេត្ត -- ទីប្រជុំជនហ្នឹង គាត់ទៅចូលតាមភូមិគេនៅក្បែរៗហ្នឹង។ ហើយមួយចំនួនហ្នឹងគឺមកតាមផ្លូវហ្នឹង”។

មិនខុសពីលោក នូ ម៉ៅ និងលោក ភី ភួន ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនានាដែលនៅក្នុងពេលនោះមានការប្រកាសថា ការជម្លៀសក្រុងឧដុង្គ គឺជាឧទាហរណ៍ល្អមួយ។ ជនជាប់ចោទទាំងនេះបានប្រាប់លោកថា ឧទាហរណ៍នេះត្រូវយកគំរូតាមនៅពេលខ្មែរក្រហមគ្រប់គ្រងក្រុងភ្នំពេញ។ បន្ទាប់មកលោក ភី ភួន ត្រូវបានសួរដេញដោលថាតើលោកបានដឹងព័ត៌មាននេះដោយរបៀបណា? លោកបានឆ្លើយថា៖ “ដូចខ្ញុំបានបញ្ជាក់ពីព្រឹកមិញថា គឺខ្ញុំដឹងនោះគឺដឹងតាមរយៈដែលគាត់ឧទ្ទេសនាមប្រាប់ក្នុងអង្គប្រជុំមួយ ឬវគ្គរៀនសូត្រមួយដូច អ៊ំប៉ុល ពត ក៏ដូចជា អ៊ំ នួន ជា ក៏ដូចជា អ៊ំ ខៀវ សំផន ក៏ឧទ្ទេសនាម

ជាបទពិសោធន៍ល្អៗ ដើម្បីយើងឈានទៅរំដោះភ្នំពេញក៏យើងធ្វើយកពិសោធន៍នេះល្អតទៅទៀត។ ខ្ញុំដឹងតាមរយៈអ៊ីចឹង រយៈអប់រំរួមហ្នឹង។

[១១:២០:០៤]

នៅក្នុងសេចក្ដីសន្និដ្ឋានបើកការចោទប្រកាន់របស់ខ្ញុំ ខ្ញុំបានលើកឡើងអំពី កិច្ចប្រជុំមជ្ឈិមបក្សនាខែមិថុនា ឆ្នាំ១៩៧៤ និងខែមេសា ឆ្នាំ១៩៧៥ ដែលនៅក្នុងនោះមេដឹកនាំបាន សម្រេចដាក់ទៅជម្លៀសប្រជាជនចេញពីភ្នំពេញដោយបង្ខំក្រោយថ្ងៃជ័យជម្នះ។ ការជម្លៀសក្រុងខដុង្គ ដោយបង្ខំត្រូវបានលើកយកមកពិភាក្សានៅក្នុងពេលប្រជុំទាំងពីរលើកនេះ។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានវត្តមាននៅក្នុងពេលប្រជុំទាំងពីរលើកនោះ ហើយបានចូលរួមសម្រេចជម្លៀសក្រុង ទីរួមខេត្តនានាផងដែរ។ សហការីរបស់ខ្ញុំនឹងលើកឡើងដោយលម្អិតអំពីកិច្ចប្រជុំទាំងនេះ និងអំពីការទទួលខុសត្រូវរបស់នួនជា និង ខៀវ សំផន លើឧក្រិដ្ឋកម្មទាំងនេះ។

ដូចខ្ញុំបានពិភាក្សានៅក្នុងចំណុចខាងលើ ការជម្លៀសទីប្រជុំជនដោយបង្ខំ ដោយបក្សកុម្មុយនីស្តកម្ពុជក្នុងមុនឆ្នាំ១៩៧៥ គឺជាហេតុការណ៍សំខាន់អាចឲ្យស្វែងយល់អំពីចេតនាឧក្រិដ្ឋអំពីការជម្លៀសក្រុងភ្នំពេញដោយបង្ខំ។ សូម្បីកម្មាភិបាលនៅខាងក្រោម មេដឹកនាំជាច្រើនថ្នាក់នោះបានដឹងអំពីការជម្លៀសទីប្រជុំជនផ្សេងទៀតដោយបង្ខំផងដែរ។ សូម្បីពួកគេក៏បានដឹងថា ក្រុងភ្នំពេញនឹងត្រូវជម្លៀសក្រោយជ័យជម្នះផងដែរ។

[១១:២១:៣៦]

ហេតុការណ៍បានបង្ហាញច្បាស់នៅក្នុងភស្តុតាងចំពោះមុខលោក-លោកស្រីចៅក្រម នៅក្នុងសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ លោក ស្ទីវហ្ស៊ិន ហេដឌ័រ បានបញ្ជាក់អំពីចម្លើយដូចខាងក្រោមដែលលោក បានទទួលពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាម្នាក់ឈ្មោះ ឡាញ ហៅ ឡួន ដែលជាសមាជិកគណៈ កម្មាធិការអចិន្ត្រៃយ៍មួយរូបនៅកំពង់សោម។

[ប្រសិនបើយើងវាយបានភ្នំពេញក្នុងឆ្នាំ១៩៧៤ ក៏នៅតែត្រូវជម្លៀសប្រជាជនដដែល ព្រោះថានេះជាផែនការមានតាំងពីយូរមកហើយ។ ពាក្យស្លោកនិយាយថា "រំដោះប្រជាជនពីដៃខ្មាំង"]។

នៅក្នុងសន្ទរកថារបស់ នួន ជា ថ្លែងនៅក្នុងឆ្នាំ១៩៧៧ នួន ជា បានប្រើឃ្លាមួយនេះថា "រំដោះប្រជាជនពីដៃខ្មាំង"។ សាក្សីមួយរូបទៀតដែលខ្ញុំលើកឡើងខាងលើគឺកម្មាភិបាលតំបន់១៣ ដែលលោក ស្ទីវហ្ស៊ិន ហេដឌ័រ បានសម្ភាស។ សាក្សីរូបនេះបានបញ្ជាក់ថា "ការជម្លៀសទីក្រុង និងទីប្រជុំជនគឺជា

ការអនុវត្តជាហូរហែមកហើយរបស់ខ្មែរក្រហម"។ លោកបានឆ្លើយថា "ខ្ញុំគិតថាផែនការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញគឺជាផែនការមួយនៃគោលនយោបាយរយៈពេលយូរជាទូទៅ ពីព្រោះនោះគឺជាអ្វីដែលយើងតែងតែបានធ្វើពីមុននៅពេលដែលយើងរំដោះបានតំបន់របស់សត្រូវ"។

[១១:២៣:១២]

លោក នូ ម៉ៅ នៅចំពោះមុខអង្គជំនុំជម្រះ លោក នូ ម៉ៅ បានរៀបរាប់អំពីកិច្ចប្រជុំនៅភូមិភាគនីរតី ដែល តាម៉ុក ដែលជាលេខាភូមិភាគនេះ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា និងលោក ជូ ជេត ហៅស៊ី ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានជជែកគ្នាអំពីផែនការជម្លៀសក្រុងភ្នំពេញក្រោយជ័យជម្នះ។ លោក នូ ម៉ៅ បានបញ្ជាក់ថាលោកបានចូលរួមនៅក្នុងកិច្ចប្រជុំមួយទៀតនៅក្នុងឆ្នាំ១៩៧៤ ដែលនៅក្នុងនោះលោក ហ៊ូ យន់ បានតវ៉ាប្រឆាំងនឹងផែនការជម្លៀសនេះ ហើយនៅពេលនោះ លោក នូ ម៉ៅ បានដឹងថា ខៀវ សំផន បានគាំទ្រផែនការជម្លៀស។ នៅក្នុងពេលនោះលោក នូ ម៉ៅ មានឋានៈត្រឹមតែសមាជិកគណៈកម្មាធិការឃុំមួយប៉ុណ្ណោះ។ ក៏ប៉ុន្តែគេបានឲ្យលោកធ្វើជាការវាយតម្លៃអំពីផែនការបក្សក្នុងការជម្លៀសក្រុង និងទីប្រជុំជនទាំងអស់។ លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ បានផ្តល់សក្ខីកម្មការជម្លៀសនេះគឺជាផ្នែកមួយនៃគោលនយោបាយជាលក្ខណៈប្រព័ន្ធរបស់ខ្មែរក្រហម។ នៅក្នុងចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតបាននិយាយថា៖ "សេចក្តីសម្រេច ជម្លៀសប្រជាជនហាក់ដូចជាចំណែកមួយនៃនយោ-បាយជាប្រព័ន្ធរបស់ខ្មែរក្រហមដែលធ្លាប់បានជម្លៀសក្រុង ឬភូមិមួយចំនួន ដែលពួកគេកាន់កាប់ពីមុនមក"។

[១១:២៤:៥១]

លោក លោកស្រីចៅក្រមជាទីគោរព! យើងខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានគ្រាន់តែភស្តុតាងប៉ុណ្ណោះល្មមអាចបញ្ជាក់ថា ខៀវ សំផន អាចភូតភរនៅចំពោះមុខតុលាការនេះ ដែលថាគាត់មិនដឹងអ្វីទាល់តែសោះអំពីផែនការជម្លៀសក្រុងភ្នំពេញ។ ក្នុងន័យនេះ ខ្ញុំនឹងលើកឡើងអំពីហេតុផលជាក់លាក់នៃការជម្លៀសក្រុងភ្នំពេញនៅត្រង់កថាខណ្ឌ១២ នៃសេចក្តីថ្លែងបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា បានលើកឡើងថា ការជម្លៀសមានគោលបំណងដើម្បី "អនុវត្តគោលនយោបាយសេដ្ឋកិច្ចមួយដែលថានៅត្រង់កាលៈទេសៈពិសេសនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ បែបនេះ នួន ជា បានជឿជាក់យ៉ាងស្មោះត្រង់ថា ហេតុផលនោះគឺដើម្បីប្រយោជន៍ប្រជាជនកម្ពុជា"។ ប្រសិនបើជឿថាពិតដូច្នេះមែន ចុះ

ហេតុអ្វីបានជាគាត់សម្រេចចិត្តមិនបំភ្លឺការពិតនោះ? នៅចំពោះមុខតុលាការគាត់បានអះអាងថា "ការជម្លៀសនេះចាំបាច់ត្រូវធ្វើឡើងក្រោយពីមានស្ថានភាពដុនដាបផ្នែកមនុស្សធម៌នៅក្នុងប្រទេសកម្ពុជានាខែមេសា ឆ្នាំ១៩៧៥ ហើយតាមការពិពណ៌នារបស់ជនជាប់ចោទ គឺដោយសារការដកជំនួយមនុស្សធម៌ធ្វើឡើងប៉ុន្មានថ្ងៃក្រោយការរំដោះ"។

[១១:២៦:២០]

លោក លោកស្រីចៅក្រម! តាមថយភាពជាក់ស្តែងការអះអាងទាំងនេះគ្មានមូលដ្ឋានអ្វីបន្តិចទាល់តែសោះ យើងខ្ញុំសូមបកស្រាយសមទៅតាមន័យនៃការអះអាងនេះ គឺជាការអះអាងមិនស្មោះត្រង់បោកបញ្ឆោតបម្រើប្រយោជន៍ខ្លួនឯង និងធ្វើឡើងដើម្បីឲ្យអង្គជំនុំជម្រះមានការយល់ច្រឡំ ព្រមទាំងបញ្ជាក់នូវភាពត្រឹមត្រូវនៃឧក្រិដ្ឋកម្មដ៏ធំធេងទាំងនេះ ហើយនិងដើម្បីបិទបាំងការទទួលខុសត្រូវរបស់ នួន ជា, ខៀវ សំផន តែប៉ុណ្ណោះ។

សេចក្តីសម្រេចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការជម្លៀសក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាពុំជាប់ពាក់ព័ន្ធអ្វីទាល់តែសោះនឹងការដោះស្រាយវិបត្តិមនុស្សធម៌ជាក់ស្តែងនោះ។ តាមលក្ខណៈរបស់វាគឺជាអំពើដាក់ទុក្ខទោសលើប្រជាជន ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ប្រជាជនទាំងនេះគឺជាខ្មាំង ឬអាចជាខ្មាំង។ ការជម្លៀសបានធ្វើឡើងដើម្បីសង្កត់សង្កិន បង្ក្រាប និងដាក់ទណ្ឌកម្មលើប្រជាជនរស់នៅទីក្រុង ដើម្បីកំណត់អ្នកដែលអាចយកទៅសម្លាប់ចោលបានភ្លាមៗនៅក្នុងចំណោមប្រជាជន។ និងដើម្បីដាក់អ្នកដែលរស់នៅទៅជាទាសករ ក្នុងគោលបំណងដកហូតសិទ្ធិទាំងអស់របស់ពួកគេ។--

**ប្រធានអង្គជំនុំ៖**

លោកជំទាវផ្អាកតិច មានបញ្ហាអស់ឌីស។ សម្រាកសិន ដើម្បីផ្លាស់ប្តូរបន្តឌីវីឌីថ្មី។

*(សម្រាករយៈពេលខ្លី)*

[១១:២៨:៣០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តទៀតលោកជំទាវ។

**លោកស្រី ជា លាង៖**

ចាស អរគុណ។ សូមអនុញ្ញាតបន្តទៀត។

--ការជម្លៀសទាំងនេះគឺដើម្បីពង្រឹងអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា និងការការពារមេដឹកនាំក្នុងនោះរួមមាន ជនជាប់ចោទទាំងនេះពីខ្មាំង ឬអ្នកដែលត្រូវបានគេចាប់ទុកថាជាខ្មាំង។ ដូច្នេះ ការជម្លៀសធ្វើឡើងគ្មានចង់បានអ្វីក្រៅតែពីអំណាចដើម្បីដាក់ទណ្ឌកម្ម។ ការជម្លៀសគឺដើម្បី នួន ជា, ខៀវ សំផន និងសមាជិកមជ្ឈិមបក្សដទៃទៀត អាចកំណត់ឲ្យអស់ពួកមនុស្សដែលពួកគេចាត់ទុកថាខ្មាំង។ ពួកគេបាននិយាយទទួលស្គាល់យ៉ាងដូច្នេះរួចទៅហើយ។

[១១:២៩:២២]

នៅក្នុងសុន្ទរកថានៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុល ពត បានថ្លែងអំពីជ័យជម្នះដែលបានមកដោយសារការកម្ទេចខ្មាំងរបស់អង្គការគ្រប់ប្រភេទ។ នួន ជា បានទទួលស្គាល់នៅក្នុងកិច្ចសម្ភាសន៍ក្នុងឆ្នាំ១៩៧៨ ទាក់ទងផែនការរបស់ ក.ហ្សេ.បេ, សេ.អ៊ី.អា ថាយើងបានកម្ទេចផែនការ។ គ្រាន់តែរំដោះភ្លាមៗ យើងបានជម្លៀសទីក្រុង។

នៅក្នុងកិច្ចសម្ភាសន៍ថ្មីមួយ ខៀវ សំផន ក៏បានព្យាយាមពន្យល់ហេតុផលថាការជម្លៀសចាំបាច់ត្រូវធ្វើឡើងដើម្បីបញ្ចៀសការគំរាមកំហែងពីកាបះបោរដោយ សេ.អ៊ី.អា និង ភ្នាក់ងារសាធារណរដ្ឋខ្មែរដែលទំនងជាអ្នកអាចបើកលទ្ធភាពឲ្យវៀតណាមចូលរួមឈ្លានពាន។ ខ្ញុំសូមដកស្រង់ដូចតទៅនេះ៖ “ហើយបើមានថែម សេ.អ៊ី.អា មកទៀតអ្នកបំបះបំបោរទៀតណា ហើយសំណល់កងទ័ព លន់ នល់ដែលនៅសល់នៅពាសពេញភ្នំពេញ ជនបទបំផុសទៀត”។

[១១:៣០:៤១]

ទស្សនាវដ្តីយុវជនយុវនារីបដិវត្ត ចុះថ្ងៃខែ ចុះខែកក្កដា ឆ្នាំ១៩៧៥ បញ្ជាក់ថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានធ្វើការជម្លៀសដោយបង្ខំ ដើម្បីដោះស្រាយជាមួយនឹងខ្មាំង ដែលអាចវាយមកលើបក្ស។ ស្រដៀងគ្នានេះដែរលោក ហ្វីលីព ស្សូត បានផ្តល់សក្ខីកម្មថា “គោលនយោបាយនៃការជម្លៀសរួមមានហេតុផលដូចជា បំបែកបណ្តាញនៅក្នុងចំណោមអ្នកក្រុងដើម្បីឲ្យពួកគេលែងមានលទ្ធភាពទប់ទល់ជាមួយនឹងរបបនេះ”។

ការជម្លៀសនាខែមេសា ឆ្នាំ១៩៧៥ បានធ្វើឡើងក៏ដើម្បីកម្ទេច និងបោសសម្អាតខ្មាំងវណ្ណៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឯកសារបក្សកុម្មុយនីស្តកម្ពុជាចំណងជើងថា “ខួបលើកទី៣ នៃការរៀបចំសហករណ៍ កសិករ” អះអាងស្រដៀងគ្នានេះដែរថា៖ “ការជម្លៀសវាយរំលំសក្តិភូមិ ម្ចាស់ដី បក្សវាយទាំងវណ្ណៈនាយទុននៅទីក្រុង”។

[១១:៣២:០១]

សមាជិកនៃអតីតរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់មុខសញ្ញាសម្រាប់កម្ទេចភ្លាមៗ។ ប្រជាជនដែលនៅសល់ត្រូវបានសង្កត់សង្កិន និងដាក់ឃុំឃាំងនៅក្នុងសហករណ៍របស់បក្សកុម្មុយនីស្តកម្ពុជា។ ពួកគេជាច្រើនត្រូវបានសម្លាប់ចោល អ្នកដែលនៅសល់ត្រូវទទួលរងការបំពាន ធ្វើបាបលើរូបរាងកាយ និងផ្លូវចិត្ត រួមមានដូចជា ការបង្ខំឲ្យសរសេរប្រវត្តិរូប ដើម្បីអាចឲ្យកំណត់អត្តសញ្ញាណ និងកម្ទេចចោលអ្នកដែលនៅសល់ពីរបបសាធារណរដ្ឋ, ការបំបែកចេញពីគ្រួសាររបស់ពួកគេដោយបង្ខំ ឲ្យធ្វើការងារដោយប្រើកម្លាំងធ្ងន់ៗ, ការទទួលរងនូវរបបអាហារមិនគ្រប់គ្រាន់ និងការបដិសេធសិទ្ធិចិញ្ចឹមជីវិត ឬស្វែងរកអាហារបរិភោគ, ការទទួលរងនូវការគំរាមកំហែង ទារុណកម្ម ការជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ និងនៅទីបំផុត ការសម្លាប់ចោលដោយសារបានបង្ហាញពីនិន្នាការចក្រពត្តិនិយម។ ដោយសារការខកខានមិនបានគោរពតាមបញ្ជា ដោយសារការទទួលរងនូវការធ្វើបាប គាបសង្កត់ ដោយសារការធ្លាក់ខ្លួនឈឺ។ ជាសរុបមកអ្នកទីក្រុងទាំងអស់ដែលត្រូវបានជម្លៀស ហើយរស់ផុតពីសេចក្តីស្លាប់នៅក្នុងចលនាដំបូងបំផុតនៃការកំណត់អត្តសញ្ញាណ និងការកម្ទេចខ្មាំង ក៏ក្រោយក៏រស់នៅក្រោមរបបនៃការធ្វើទុក្ខបុកម្នេញ និងភាពតក់ស្លុតផងដែរ។

[១១:៣៣:៥០]

ប្រព័ន្ធធ្វើទុក្ខបុកម្នេញលើអ្នកទីក្រុងដែលត្រូវបានជម្លៀស បានត្រូវឆ្លុះបញ្ចាំងតាមរយៈការពាក់ស្លាកថាជាអ្នកប្រជាជនថ្មី ឬអ្នក១៧មេសា។ នៅក្នុងរបបគ្រប់គ្រងថ្មី ដែលបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនថ្មីទាំងអស់ត្រូវបានគេចាត់ទុកថាជា "ពួកបញ្ញើ ឬពួកប៉ារ៉ាស៊ីត"។ លោកស្រី ដេនីស អាហ្វុងសូ មានសញ្ជាតិបារាំងបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះថា នៅក្នុងខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីលោកស្រីត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញទៅកោះទឹកវិល លោកស្រីនិងក្រុមគ្រួសារ និងអ្នកជម្លៀសផ្សេងទៀតនៅលើកោះនោះបានទៅចូលរួមក្នុងកិច្ចប្រជុំមួយ ដែលគេធ្វើឡើងនៅក្នុងវត្ត ហើយដែលមានខ្មែរក្រហមនៅទីនោះ អ្នកស្រីបានសម្ភាសថា "ឥឡូវនេះអ្នកទាំងអស់គ្នា គឺជាអ្នកទោស យើងនឹងមិនយកកាំភ្លើងភ្ជង់ និងបាញ់អ្នកទាំងអស់គ្នាទេ។ ប៉ុន្តែយើងនឹងឲ្យអ្នកទាំងអស់គ្នាធ្វើការឲ្យយើង បើអ្នកណាជំទាស់យើងនឹងសម្លាប់ចោល។ ទាំងនេះជាពាក្យគ្រប់ម៉ាត់ដែលពួកគេប្រាប់យើង ខ្ញុំនៅចាំមិនភ្លេចទេ"។ លោកស្រី ដេនីស អាហ្វុងសូ ក៏បានបញ្ជាក់ផងដែរថា នៅថ្ងៃជម្លៀសនោះ ពួកខ្មែរក្រហមធ្វើឲ្យយើងមើលឃើញយ៉ាងច្បាស់ក្រឡែតថា

ប្រជាជនជម្លៀសគឺជាទ្រព្យសម្បត្តិរបស់អង្គការ។ នេះគឺជាការបង្កើតឲ្យមានការធ្វើទុក្ខបុកម្នេញទៅលើប្រជាជន និងធ្វើយ៉ាងណាបែងចែកអ្នកទាំងនោះឲ្យនៅដាច់ចេញពីមនុស្សដែលបក្សកុម្មុយនីស្តកម្ពុជា ចាត់ទុកថាស្មោះស្ម័គ្រ និងបុព្វហេតុរបស់ពួកគេ។ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ត្រូវបានស្នើសុំឲ្យបំភ្លឺបន្ថែមអំពីមូលហេតុក្នុងការបង្កើតក្រុមប្រជាជនបញ្ញើនេះ គាត់បានមានប្រសាសន៍ថា៖ "ខ្ញុំគិតថាគោលបំណងនោះមានលក្ខណៈច្បាស់លាស់រួចហើយ។ គេធ្វើដូច្នេះ ដើម្បីញែកឲ្យដាច់ពីគ្នារវាងប្រជាជនខ្មែរដែលស្អាតស្អំ និងប្រជាជនដែលមិនស្អាតស្អំអ្នកដែលមិនស្អាតស្អំគឺត្រូវពួកគេចាត់ទុកថាជាប្រជាជនផ្ញើ"។

[១១:៣៦:៣៤]

នៅក្នុងសក្ខីកម្មរបស់ ស្ទីវហ្វិន ហេដឌ័រ បានបញ្ជាក់លើអត្ថបទខាងក្រោម ដែលដកស្រង់ចេញពីក្នុងសៀវភៅរបស់លោកចំណងជើងថា "បេក្ខជនប្រាំពីររូបសម្រាប់ការចោទប្រកាន់"។ នៅក្នុងសៀវ-ភៅនោះ លោកបានវិភាគអំពីការបែងចែកប្រជាជនជាបីថ្នាក់នៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានបញ្ជាក់ថា ពួកប្រជាជនផ្ញើត្រូវបានគេដាក់នៅបាតបញ្ជីអ្នកដែលត្រូវយកទៅសម្លាប់ចោលមុនគេ និងគ្មានសិទ្ធិនយោបាយអ្វីទាំងអស់។ លោក ហ្វីលីព ស្សត បានបញ្ជាក់អំពីការប្រព្រឹត្តិមកលើប្រជាជននៅទីក្រុងនាខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំផ្សេងៗគ្នា ដែលមានមនោគមន៍វិជ្ជាខុសៗគ្នាមែន ប៉ុន្តែអាចទំនងជ្រើសរើសគោលនយោបាយផ្សះផ្សាជាតិ។ ប៉ុល ពត សម្រេចផ្សេងពីនេះ។ ចំពោះគាត់ អ្នកក្រុង និងអ្នកស្រែដែលបានរត់គេចមកចូលរួមជាមួយនឹងពួកគេនៅក្នុងអំឡុងខែ -- ស្លាប់រស់ក្នុងសង្គ្រាម គឺជាអ្នកចូលដៃសហការទៅតាមការពិតជាក់ស្តែង ហើយត្រូវទទួលបានការសម្របសម្រួលទៅតាមនោះដែរ។ គាត់បាននិយាយនៅក្នុងសក្ខីកម្មរបស់គាត់ផងដែរ "ខ្ញុំគ្រាន់តែនិយាយ វាពាក់ព័ន្ធនឹងស៊ីសង្វាក់គ្នាទៅនឹងអ្វីៗទាំងអស់ យើងកំពុងរៀបរាប់អំពីចុងបញ្ចប់ដែលជាមូលហេតុបញ្ជាក់ពីមធ្យោបាយ អំពីការកំណត់មាគ៌ាច្បាស់លាស់រវាងសត្រូវនិងយើង។ អំពីអ្នកដែលជ្រើសរើសឈរខាងយើង ហើយនិយាយថា នៅក្នុងទីក្រុងប្រសើរជាងចូលរួមជាមួយបដិវត្តន៍ គឺគ្មានន័យ"។

[១១:៣៨:២៨]

នៅក្នុងសៀវភៅមួយរបស់គាត់ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ រៀបរាប់ថាសេចក្តីសម្រេចជម្លៀសនេះគឺជាបញ្ហាយ៉ាងឃោរឃៅ ហើយលោកបានសង្កត់ធ្ងន់ធ្ងរទៅលើចេតនាធ្វើទុក្ខបុកម្នេញរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ បញ្ហាដ៏ឃោរឃៅនេះពុំដែលត្រូវបានពន្យល់លម្អិតឡើយ ហើយវាបាន

ធ្វើឲ្យមនុស្សស្លាប់ជាច្រើនពាន់នាក់បន្ថែមទៅលើចំនួនប្រហែល ៥០០.០០០នាក់ នៅក្នុងសង្គ្រាមស៊ីវិល។ ទោះបីជាយ៉ាងនេះក្តី ហេតុផលនោះ គឺបំណងចង់ឲ្យបក្សកុម្មុយនីស្តកម្ពុជាបានជ័យជម្នះ ចង់ឲ្យជនបទមានអានុភាពលើក្រុង និងអានុភាពឋានៈអាទិភាពលើជនក្រីក្រ។ សាឡុត ស និងសហការីរបស់គាត់មិនចំណាយពេលប្រាំពីរឆ្នាំនៅក្នុងព្រៃ និងប្រាំឆ្នាំវាយប្រយុទ្ធសង្គ្រាមស៊ីវិលដើម្បីចាប់យកតួនាទីជាអ្នកគ្រប់គ្រងក្រុងឡើយ។

[១១:៣៩:៣៤]

ដើម្បីបង្ហាញឲ្យឃើញចេតនារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសង្កត់សង្កិន និងគាបសង្កត់ប្រជាជននៅតាមក្រុង និងនៅទីប្រជុំជន ខ្ញុំនឹងអានចេញនៅឯកសារបោះពុម្ពផ្សាយមួយរបស់បក្សនេះ។ ខាងក្រោមនេះគឺជាអត្ថបទមួយដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយនាខែសីហា ឆ្នាំ១៩៧៥ ដែលដូច នួន ជា បានដឹងទស្សនាវដ្តីនេះជាឯកសារមួយដែលបោះពុម្ពផ្សាយដោយមជ្ឈិមបក្ស។

"ឥឡូវនេះ អាណានិគមចក្រពត្តិក៏ត្រូវរលំ ម្ចាស់ដី សក្តិភូមិក៏ត្រូវរលំ នាយទុន ក៏ត្រូវរលំ។ អនុធនវាគ្មានទីពឹង។ ដូច្នេះវាត្រូវរណបរដ្ឋអំណាចកម្មករ កសិករ។ វណ្ណៈវាត្រូវរលំហើយ។ មូលដ្ឋានសេដ្ឋកិច្ចវាត្រូវរលំហើយ តែទស្សនៈវានៅ សេចក្តីប៉ងប្រាថ្នាវានៅ។ ដូច្នេះវាទំនាស់ជាមួយបដិវត្តន៍តទៅទៀត។ សូម្បីក្រោយពួកវណ្ណៈនៅក្នុងក្រុង និងនៅតាមទីប្រជុំជនត្រូវបានដួលរលំ និងដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាហើយនោះ នៅក្នុងក្រសែភ្នែករបស់មេដឹកនាំ វណ្ណៈទាំងនេះបានបន្តប្រឆាំងនឹងបដិវត្តន៍។ ដូច្នេះពួកគេសមនឹងទទួលរងនូវទុក្ខទោស"។

[១១:៤១:០៤]

ឥឡូវនេះខ្ញុំសូមបង្ហាញឡើងវិញនូវភស្តុតាងដែលបញ្ជាក់អំពីស្ថានភាពនៅក្នុងក្រុងភ្នំពេញនៅក្នុងរយៈពេលប៉ុន្មានខែមុនពេលជម្លៀស។ ភស្តុតាងនេះពាក់ព័ន្ធពីព្រោះ វាច្រានចោលទឡ្ហីករណ៍អះអាងរបស់ក្រុមមេធាវីការពារក្តីដែលលើកឡើងថាការជម្លៀសត្រូវបានបញ្ជាឲ្យធ្វើឡើងដើម្បីផ្តល់ម្ហូបអាហារ និងដើម្បីឆ្លើយតបទៅនឹងវិបត្តិមនុស្សធម៌។ ភស្តុតាងបានបង្ហាញថា នៅក្នុងប៉ុន្មានខែមុនពេលបែកភ្នំពេញថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបង្កឡើងមានវិបត្តិមនុស្សធម៌នៅក្នុងក្រុងភ្នំពេញដោយចេតនា ដោយពួកគេឡោមព័ទ្ធក្រុងនេះ បិទផ្លូវផ្គត់ផ្គង់ម្ហូបអាហារ និងបរិក្ខាពេទ្យ កាប់សម្លាប់ជនស៊ីវិល នៅពេលបាញ់ប្លោងវាយសម្រុកចូលតំបន់ប្រជាជនរស់នៅ និងបំភិតបំភ័យប្រជាជនស៊ីវិលនៅក្នុងក្រុងទាំងមូល។ សកម្មភាពទាំងនេះ គឺធ្វើឡើងផ្ទុយពីចេតនារបស់ជនជាប់ចោទដែលលើកឡើងថា ចង់ជៀសវាង ឬកាត់

បន្ថយការឈឺចាប់ខ្លោចផ្សានោះ។ ក៏ប៉ុន្តែវាបែរជាបង្ហាញឲ្យឃើញថាតាមពិតជនជាប់ចោទមានចេតនាខុសពីនេះស្រឡះទៅវិញទេ។

[១១:៤២:៣៣]

ការវាយសម្រុកទីកចុងក្រោយមកលើទីក្រុងភ្នំពេញត្រូវបានប្រកាសដោយ ខៀវ សំផន នៅក្នុងសេចក្តីថ្លែងការណ៍ដែលប្រកាសតាមវិទ្យុខ្មែរក្រហមនៅវេលាម៉ោងដប់មួយព្រឹក នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤។ នៅក្នុងសេចក្តីថ្លែងការនោះ ខៀវ សំផន បានគូសបញ្ជាក់ថា តំបន់នៅជុំវិញទីក្រុងភ្នំពេញដែលស្ថិតក្រោមការត្រួតត្រារបស់ពួកសាធារណរដ្ឋខ្មែរត្រូវបានកាត់បន្ថយឲ្យមកនៅត្រឹម១០គីឡូម៉ែត្រក្រឡា និងត្រូវបានកងកម្លាំងខ្មែរក្រហមឡោមព័ទ្ធជាប់ជាប្រចាំ។ ខៀវ សំផន សង្កត់ធ្ងន់ថា ការផ្គត់ផ្គង់ស្បៀងអាហារនៅក្នុងទីក្រុងកាន់តែខ្សត់ ហើយទីក្រុងសង្ឃឹមទទួលបានការផ្គត់ផ្គង់ជំនួយតែមួយច្រកគត់ គឺតាមទន្លេមេគង្គ។ គាត់អួតអំពីការត្រៀមលក្ខណៈជាស្រេចរបស់កងកម្លាំងខ្មែរក្រហមដើម្បីបើកការវាយប្រយុទ្ធទ្រង់ទ្រាយធំទៅលើទីតាំងផ្សេងៗរបស់ខ្មាំងនៅតាមផ្លូវទឹក ដែលបង្កការលំបាកឲ្យកាន់តែខ្លាំងដល់ការដឹកជញ្ជូនជំនួយរបស់ពួកចក្រពត្តិអាមេរិកមកកាន់ទីក្រុងភ្នំពេញ។ បន្ទាប់មក គាត់បានបញ្ជាឲ្យកងកម្លាំងទាំងនោះបើកការវាយប្រហារដ៏ខ្លាំងក្លា និងទ្រង់ទ្រាយធំបំផុតមួយទៅលើពួកខ្មាំង។ នៅជុំវិញទីក្រុងភ្នំពេញ និងនៅក្នុងទីក្រុងភ្នំពេញ និងនៅតាមទីរួមខេត្តផ្សេងៗទៀត។

[១១:៤៤:១៣]

ការវាយប្រហារនេះចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៥ ដោយកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមបាញ់កាំជ្រួច រ៉ុក្កែតដាក់ចូលទីក្រុងភ្នំពេញ។ ភស្តុតាងបង្ហាញឲ្យឃើញនៅក្នុងរយៈពេលចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី១៧ មេសា កងកម្លាំងខ្មែរក្រហមបានសម្រុកឡោមព័ទ្ធទីក្រុងក្នុងគោលបំណងធ្វើឲ្យស្ថានភាពរស់នៅរបស់មនុស្សមានភាពលំបាកលំបិនក្រៃលែង។ ការផ្សាយតាមវិទ្យុរបស់ពួកខ្មែរក្រហម និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរបានផ្សាយព្រឹត្តិការណ៍តានតឹងពីមួយថ្ងៃទៅមួយថ្ងៃ និងស្ថានការណ៍ដែលកាន់តែរឹករវនៅក្នុងក្រុងភ្នំពេញ។ ការផ្សាយនេះគឺត្រូវស្រង់ប្រតិចារឹកដោយភ្នាក់ងារសេវាផ្សព្វផ្សាយព័ត៌មានបរទេសហៅកាត់ថា អេហ្វ.ប៊ី.អាយ.អេស (FBIS)។

ដូចបានពិពណ៌នាខាងលើនៅក្នុងការផ្សព្វផ្សាយទាំងនោះ និងនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃនិងសកម្មរបស់លោក ឆេនប៊ើក*(Schanberg)* ពួកខ្មែរក្រហមវាយប្រហារលើក្បួនរថយន្តដែលកំពុងដឹកជញ្ជូនម្ហូបអាហារ និងប្រេងឥន្ធនៈពីប្រទេសវៀតណាមខាងត្បូងមកកាន់ទន្លេមេគង្គលើដើម្បីចែក

ចាយដល់ទីក្រុងភ្នំពេញ។ ការវាយប្រហារទាំងនេះ គឺដើម្បីឱ្យទីក្រុងភ្នំពេញដាច់ខ្យល់ស្លាប់។ នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានដាក់ពង្រាយ គ្រាប់មីននៅក្នុងទឹកតាមដងទន្លេមេគង្គដើម្បីទប់ស្កាត់កុំឱ្យគេជំនួយទៅដល់ទីក្រុង។ នៅក្នុងអត្ថបទសារព័ត៌មានចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ១៩៧៥ លោក ស៊ីដនី ឆេនប៊ើក*(Sydney Schanberg)* បានរាយការណ៍ថាការបាញ់ប្រហារ និងគ្រាប់មីនរបស់ពួកខ្មែរក្រហមបានបំផ្លាញកប៉ាល់ដឹកស្បៀងចំនួន១៩គ្រឿងដែលសុទ្ធតែជាកប៉ាល់ កំពុងដឹកជញ្ជូនជំនួយឧបត្ថម្ភទៅកាន់ទីក្រុងភ្នំពេញ។ នៅក្នុងពេលធ្វើសក្ខីកម្មរបស់លោក ឆេនប៊ើក បានបញ្ជាក់ថាព្រឹត្តិការណ៍ទាំងនេះពិតជាបានកើតឡើងមានដូច្នេះមែន។ នៅដើមខែកុម្ភៈ ផ្លូវទឹកនៅតាមដងទន្លេមេគង្គត្រូវបានបិទទាំងស្រុង។ ទីក្រុងភ្នំពេញទាំងមូលត្រូវពឹងអាស្រ័យទៅលើជំនួយតាមដែនអាកាសតែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ពួកខ្មែរក្រហមនៅតែបន្តបាញ់ប្លោងដាក់ព្រលានយន្តហោះពោធិចិនតុង និងបាញ់ដាក់យន្តហោះស៊ីវិលដែលដឹកជញ្ជូនជំនួយចាំបាច់បំផុតសម្រាប់ទីក្រុងភ្នំពេញ។ អង្គហេតុមួយនេះក៏ត្រូវបានកត់ត្រាទុកដោយទីភ្នាក់ងារសេវាផ្សព្វផ្សាយព័ត៌មានបរទេស អេហ្វ.ប៊ី.អាយ.អេស ក្នុងអត្ថបទផ្សាយព័ត៌មានភ្លាមៗរបស់លោក ស៊ីដនី ឆេនប៊ើក ក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ និងក្នុងសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះផងដែរ។

[១១:៤៧:៣១]

នៅដើមខែកុម្ភៈ ផ្លូវទឹកទន្លេមេគង្គ លោក ឆេនប៊ើក បានពិពណ៌នាអំពីផលប៉ះពាល់នៃការបាញ់ផ្លោងដាក់យន្តហោះនៅក្នុងសក្ខីកម្មរបស់គាត់ដូច្នេះថា “សម្ភារៈផ្គត់ផ្គង់ត្រូវបានកាត់បន្ថយ និងនៅពេលដែលពួកឧទ្ទាមខ្មែរក្រហមចេះតែបន្តវាយប្រហារដូច្នេះ ម្ហូបអាហារ និងរបស់ដែលត្រូវការចាំបាច់ដទៃទៀត និងប្រេងឥន្ធនៈចេះតែខ្សត់ទៅៗ។ នោះហើយគឺជាអ្វីដែលកើតឡើង វាមិនខុសអ្វីពីខ្ទប់ច្រមុះមិនឱ្យទីក្រុងមានខ្យល់ដកដង្ហើមនោះឡើយ។ ការប្រព្រឹត្តដូចគ្នានេះ ពោលគឺការធ្វើឱ្យខ្សោះខ្យល់តាមរយៈការវាយប្រហារ ការផ្លោងគ្រាប់ដាក់ និងការបំបាក់ស្មារតីប្រជាជនស៊ីវិលបានរីករាលដាលដល់ប្រជាជននៅតំបន់ក្រុងអ្នកលឿងដែលស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ។ ពួកខ្មែរក្រហមវាយដណ្តើមបានតំបន់អ្នកលឿងនៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងខែទាំងនេះមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាដាច់ខាតមិនអនុញ្ញាតឱ្យនាំចូលស្បៀងអាហារ និងជំនួយផ្នែកសុខាភិបាលដើម្បីជួយដល់ប្រជាជនស៊ីវិល ទោះបីប្រជាជនទាំងនេះមិនពាក់ព័ន្ធនៅក្នុងភាពប្រទូសរ៉ាយណាមួយក៏ដោយ។ ស្ថានភាពរស់នៅរបស់មនុស្សមានភាពលំបាកលំបិនខ្លាំងដោយសារការវាយប្រហារ។ ស្ថានភាពនេះរឹតតែយ៉ាប់យ៉ឺនខ្លាំងថែម

ទៀតនៅពេលពួកខ្មែរក្រហមបាញ់គ្រាប់ប្លោងដាក់តំបន់ដែលមានលំនៅដ្ឋានប្រជាជនរស់នៅក្នុងទីក្រុង។ ចាប់តាំងពីខែមករា -- ដល់ថ្ងៃទី១៧ ខែមេសា កងកម្លាំងនៃបក្សកុម្មុយនីស្តកម្ពុជាបានបាញ់គ្រាប់រ៉ុក្កែតរាល់ថ្ងៃ និងបាញ់មិនរើសទីកន្លែង។ ពួកគេបានបាញ់ដាក់តំបន់ដែលមានលំនៅដ្ឋានប្រជាជនរស់នៅក្នុងទីក្រុងភ្នំពេញដែលធ្វើឲ្យស្លាប់ ឬរបួសប្រជាជនស៊ីវិលរាប់រយនាក់ និងបង្កភាពភិតភ័យដល់ប្រជាជននៅទូទាំងទីក្រុង។ ការវាយប្រហារនេះត្រូវបានទីភ្នាក់ងារសេវាផ្សព្វផ្សាយព័ត៌មានបរទេស អេហ្វ.ប៊ី.អាយ.អេស រាយការណ៍ថា ជាបន្តបន្ទាប់នៅក្នុងខែមករា កុម្ភៈ មីនា និងមេសា ឆ្នាំ១៩៧៥ ពួកគេបានរាយការណ៍នៅក្នុងសក្ខីកម្មរបស់សាក្សី និងកំណត់ហេតុនៃចម្លើយសាក្សីដទៃទៀតផងដែរ។ ឧទាហរណ៍ទាំងទីភ្នាក់ងារសេវាផ្សព្វផ្សាយមានបរទេស និងកំណត់ហេតុប្រចាំថ្ងៃរបស់ ស៊ីដនី ឆេនប៊ើកសុទ្ធតែបានពិពណ៌នាអំពីព្រឹត្តិការណ៍នៃការបាញ់ប្លោងគ្រាប់រ៉ុក្កែតរបស់ពួកខ្មែរក្រហម ដែលធ្លាក់ត្រូវចំសាលាបឋមសិក្សាមួយនៅក្នុងក្រុងភ្នំពេញធ្វើឲ្យស្លាប់ និងរបួសក្មេងសិស្សសាលាជាច្រើននាក់នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ១៩៧៥។ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរស្វែងរកការចរចាជាមួយខ្មែរក្រហម ដើម្បីបញ្ឈប់សង្គ្រាមដោយសន្តិវិធី។ ការចរចានោះត្រូវបានបដិសេធដោយបក្សកុម្មុយនីស្តកម្ពុជាជាច្រើនលើកច្រើនសា។ ឧទាហរណ៍នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៥ សេចក្តីថ្លែងការណ៍មួយរបស់ ខៀវ សំផន ឆ្លើយតបទៅនឹងរបាយការណ៍នៃការចរចាដែលគ្មានប្រភពរវាងខ្មែរក្រហម និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។

[១១:៥១:៣៥]

យោងតាមប្រភពពីលោកខាងលិចមួយចំនួន "កាលពីប៉ុន្មានថ្ងៃមុន អាឡុង បូរ៉េត បានថ្លែងថាខ្លួនបានទំនាក់ទំនងស្វែងរកការចរចាជាមួយភាគីផ្សេងទៀតរួចហើយ ក្នុងនាមប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងមូលកងទ័ពរំដោះជាតិប្រជាជនកម្ពុជា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាសូមចេញផ្សាយសេចក្តីថ្លែងការណ៍ដើម្បីជំទាស់ទៅនឹងឧបាយកលបោកបញ្ឆោតនេះ"។ ដូចដែលពួកគេបានបង្កើតឧបាយកលនេះឡើងក្នុងឱកាសមួយចំនួននាពេលកន្លងមក រណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា សូមបញ្ជាក់ឲ្យច្បាស់សាជាថ្មីជូនដល់មតិជាតិនិងអន្តរជាតិថា "យើងខ្ញុំពិតជាមិនធ្លាប់បានចរចាជាមួយពួកគេនោះទេ ហើយយើងក៏មិនធ្លាប់ទទួលការចរចាជាមួយក្រុមពួកក្បត់នោះដែរ"។ ឧទាហរណ៍យ៉ាងច្បាស់មួយទៀត អំពីការបំភិតបំភ័យរបស់កងកម្លាំងខ្មែរក្រហមដែលបានធ្វើមកលើប្រជាជនស៊ីវិលនៅទីក្រុងភ្នំពេញ ត្រូវបានកត់ត្រាក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់លោក ឆេនប៊ើក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៧៥ ដូចតទៅ៖ "គ្រាប់ប្លោងមួយ

បានធ្លាក់លើវិថីដ៏មមាញឹកមួយក្នុងរដ្ឋធានីនៅចំពីមុខសណ្ឋាគារមនោរម្យ មនុស្សប្រាំនាក់ស្លាប់ភ្លាមៗនៅនឹងកន្លែង ហើយប្រាំបីនាក់ផ្សេងទៀតរងរបួស។ នៅលើវិថីនោះមានសាកសពរដូករណែលនិងបំបែកសាកសពរាយប៉ាយពាសពេញផ្លូវ ការឃើញការសម្លាប់មនុស្សស្រស់ៗនឹងភ្នែកបែបនេះបានក្លាយជារឿងកើតឡើងជារៀងរាល់ថ្ងៃទៅហើយនៅទីនេះ"។ ពីរថ្ងៃក្រោយមក ស៊ីដនី ឆេនប៊ើក បានកត់សម្គាល់ទៀតថា៖ "ក្នុងរយៈពេលប្រាំបួនសប្ដាហ៍ចាប់តាំងពីមានការវាយប្រហារគ្រាប់រ៉ុក្កែតប្រហែល ១000គ្រាប់ ត្រូវបានគេប្លោងដាក់រដ្ឋធានី និងបានសម្លាប់ជនស៊ីវិលស្លូតត្រង់មិនតិចជាង១៥0នាក់ និងធ្វើឱ្យរបួស ៦00នាក់ផ្សេងទៀត"។ លោក ស្ទីវហ្វិន ហេដឌ័រ ក៏ដូចជាលោក ស៊ីដនី ឆេនប៊ើក ដែរដែលបានរស់នៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលនោះ បានពិពណ៌នាការបាញ់ប្លោងដាក់រដ្ឋធានីចាប់ពីចុងឆ្នាំ១៩៧៤ ដល់ខែមេសា ឆ្នាំ១៩៧៥។ គាត់ចាំបាច់ត្រូវជីកត្រង់សេមួយនៅក្រោមផ្ទះរបស់គាត់ ហើយពេលនោះគាត់ត្រូវរស់នៅក្នុងត្រង់សេនោះទៀតផង ដោយសារការបាញ់ប្លោងជាប្រចាំរបស់ខ្មែរក្រហមមកលើតំបន់ដែលគាត់រស់នៅ។ លោក ហេដឌ័រ បានផ្ដល់សក្ខីកម្មថា "ការបាញ់គ្រាប់ត្បាល់ និងគ្រាប់រ៉ុក្កែតរបស់បក្សកុម្មុយនីស្ដបានធ្លាក់ចំតំបន់ដែលមានមនុស្សរស់នៅច្រើនតែម្ដង"។ គាត់បានរៀបរាប់ទៀតថា "មានករណីមួយនោះ តំបន់មួយក្នុងសង្កាត់ត្រូវឆេះខ្ទេចទាំងស្រុង"។

[១១:៥៤:៥៤]

ដូចបានបញ្ជាក់ដោយសាក្សីអ្នកជំនាញ ហ្វីលីព ស្ទូត ថា ការបំប្លោងគ្រាប់បែកតំបន់ដែលមានប្រជាជនរស់នៅច្រើននោះ ឆ្លុះបញ្ចាំងពីទស្សនៈរបស់មេដឹកនាំខ្មែរក្រហមថា ការបង្កគ្រោះថ្នាក់ដល់អាយុជីវិតជនស៊ីវិល និងដែលភ័យរត់រកការជ្រកកោនក្នុងទីក្រុងនោះ គឺជាទង្វើដែលពួកគេអាចទទួលយកបាន។ លោក ហ្វីលីព ស្ទូត បានលើកឡើងថា "ការវាយប្រហារដោយគ្រាប់ប្លោង ជាមួយនឹងសង្គ្រាមចិត្តមួយ ដើម្បីបង្ហាញថារដ្ឋការ លន់ នល់ មិនមានសមត្ថភាពការពារអ្នកណាបានទៀតទេ។ ប៉ុន្តែដោយសារការបាញ់ប្លោងនោះមិនរើសមុខ មិនដឹងទិសតំបន់ ហើយដោយសារកម្រិតនៃវិសាលភាពចម្ងាយរបស់កាំភ្លើងត្បាល់នោះ ធ្វើឱ្យគ្រាប់ប្លោងទាំងនោះតែងធ្លាក់នៅតំបន់ជាយក្រុង ដែលងាយរងគ្រោះជាងគេ។ ខ្មែរក្រហមយល់ថា ការប្លោងដាក់ទាំងតំបន់ទាំងនេះមិនមានអ្វីចោទជាបញ្ហាទេ ព្រោះប្រជាជននៅទីនោះបានជ្រើសរើសរស់នៅជាមួយ លន់ នល់ មិនចូលបដិវត្តន៍។ ដូច្នេះហេតុផលទាំងពីរត្រូវគ្នាតែម្ដង"។

សេចក្ដីថ្លែងការណ៍តាមវិទ្យុខ្មែរក្រហមដោយមេដឹកនាំនានាដូចជា ខៀវ សំផន និងភ្នាក់ងារ

ព័ត៌មានដទៃរបស់ខ្មែរក្រហមបានបញ្ជាក់ថា ពិតជាមានការឯកភាពពីថ្នាក់ដឹកនាំចំពោះការបាញ់ប្លោងដាក់ទីក្រុង និងរាំងខ្ទប់ជំនួយមនុស្សធម៌។ ទស្សនាវដ្ដីយុវជន យុវនារីបដិវត្តចុះខែសីហា ខែកញ្ញា ឆ្នាំ១៩៧៤ ក៏បានបញ្ជាក់ថា កងកម្លាំងខ្មែរក្រហមបាននឹងកំពុងបាញ់ប្លោងគ្រាប់រ៉ុក្កែត និងកាំភ្លើងត្បាល់ចូលទីក្រុងភ្នំពេញ។

[១១:៥៧:០៦]

ខ្ញុំនឹងអានសេចក្ដីដកស្រង់ពីរដែលពាក់ព័ន្ធគ្នា។ ទី១ ពាក់ព័ន្ធនឹងការវាយបកតបរបស់កងកម្លាំងសាធារណរដ្ឋខ្មែរ។ ទស្សនាវដ្ដីលេខនោះបានចុះផ្សាយដូចខាងក្រោម៖ "ពួកវាចង់រ៉ើរុញច្រានយើងចេញឲ្យឆ្ងាយពីច្រកចូលទីក្រុងភ្នំពេញ ធ្វើយ៉ាងណាកុំឲ្យយើងអាចបាញ់គ្រាប់រ៉ុក្កែតចូលទីក្រុងភ្នំពេញទៀតបាន"។ នៅទំព័របន្ទាប់ទស្សនាវដ្ដីនោះ ក៏មានការអួតអាងទៀតថា៖ "ផ្ទុយទៅវិញយើងនៅរក្សាទីតាំងឈរជើងរបស់យើងយ៉ាងរឹងមាំនៅជុំវិញទីក្រុងភ្នំពេញ ហើយយើងអាចបាញ់ប្លោងចូលទីក្រុងភ្នំពេញតាមចិត្ត ពេលណាក៏បាន ពីគ្រប់មុខព្រួញទាំងអស់ សូម្បីតែព្រលានយន្តហោះពោធិ៍ចិនតុង"។រយៈពេលក្រោយមកបន្តិចវិទ្យុខ្មែរក្រហមបានផ្សាយនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៥ ដោយអួតអាងពីការបិទផ្លូវទឹកទន្លេមេគង្គថា៖ "ចាប់ដើមតាំងពីខែកុម្ភៈមក គ្មានខ្មាំងណាអាចដឹកជញ្ជូន និងបើកបរកាត់តាមផ្លូវទឹកដែលយើងគ្រប់គ្រងតាមដងទន្លេមេគង្គទៀតទេ។ ដូច្នេះ ផ្លូវទឹកទន្លេមេគង្គដែលបានបិទនៅខែមករា និងដើមខែកុម្ភៈកន្លងមកនេះនឹងត្រូវបានកាត់ផ្ដាច់ជារៀងរហូត។ មានន័យថា សត្រូវអស់ផ្លូវផ្គត់ផ្គង់ស្បៀងអាហារ និងប្រេងឥន្ធនៈទៀតហើយចាប់ពីពេលនេះតទៅ។ ដូច្នេះស្ថានភាពដែលកំពុងតែដុនដាបនៅទីក្រុងភ្នំពេញ និងកាន់តែដុនដាបទៅដុនដាបទៅជាមិនខាន"។

វិទ្យុរបស់ខ្មែរក្រហមកាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៧៥ បានផ្សាយថា៖ "ឥឡូវនេះពួកខ្មាំងកំពុងស្ថិតនៅក្នុងស្ថានភាពឈឺចាប់ ដោយសារទន្លេមេគង្គត្រូវបានកាត់ផ្ដាច់ពីរខែមកហើយ និងផ្លូវអាកាសនិងមធ្យោបាយគមនាគមន៍ដទៃទៀតនឹងត្រូវកាត់ផ្ដាច់ឆាប់ៗខាងមុខនេះ"។

[១១:៥៩:១៧]

នៅក្នុងអំឡុងពេលនោះ ខៀវ សំផន បានធ្វើសេចក្ដីថ្លែងមួយចំនួនតាមវិទ្យុខ្មែរក្រហមទៅកាន់កងទ័ពខ្មែរក្រហម និងប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ ដែលសហការីរបស់ខ្ញុំនឹងលើកឡើងអំពីសេចក្ដីថ្លែងការណ៍ទាំងនេះ។ ខ្ញុំនឹងអានសេចក្ដីថ្លែងការណ៍តែពីរប៉ុណ្ណោះ។ ទី១ សេចក្ដីថ្លែងការណ៍ខៀវ សំផន កាលពីថ្ងៃទី២៤ ខែមករា មានដូចតទៅ៖ "ទីក្រុងភ្នំពេញ គឺជាមុខព្រួញវាយប្រហារដ៏មោះ

មុតបំផុតរបស់កងកម្លាំងយើង។ ការលំបាកនៅជួបប្រទះនៅឡើយសោះនៅនោះ គឺផ្លូវទឹកទន្លេមេគង្គ ដែលជាមធ្យោបាយដឹកជញ្ជូនដ៏សំខាន់តែមួយគត់ ដែលនៅសេសសល់សម្រាប់ការផ្គត់ផ្គង់ការដឹកជញ្ជូនរបស់ខ្មាំង ពេលនេះត្រូវបានកាត់ផ្តាច់ទាំងស្រុងហើយ។ ដូច្នេះការខ្វះខាតស្រូវអង្ករនៅទីក្រុងភ្នំពេញ និងទីរួមខេត្តដទៃទៀត ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្មាំង ហើយដែលតែងតែធ្វើឲ្យមានការភ័យខ្លាចបំផុតនោះ គឺធ្លាក់ទៅក្នុងភាពធ្ងន់ធ្ងរក្នុងពេលអនាគត។

សេចក្តីថ្លែងការណ៍ទី២ គឺបានធ្វើឡើងដោយ ខៀវ សំផន នៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៥ ដែលមានខ្លឹមសារដូចតទៅ៖ "យើងបានកាត់ផ្លូវដឹកជញ្ជូនរបស់ខ្មាំងស្ទើរតែទាំងអស់។ ទន្លេមេគង្គត្រូវបានកាត់ផ្តាច់ គមនាគមន៍ជើងគោកទាំងអស់ត្រូវបានកាត់ផ្តាច់ ហើយមូលដ្ឋានកងទ័ពពោធិ៍ចិនតុងកំពុងតែប្រឈមមុខនឹងការវាយប្រយុទ្ធរបស់យើងជាប្រចាំ"។

[១២:០១:០៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកជំទាវ។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយដប់ប្រាំនាទីរសៀលនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការ។ សូមភាគី និងសាធារណជនជ្រាប។ ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងដប់ប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:១៩ នាទី)*

[១៣:១៩:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ សូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោកស្រី ជា លាង៖**

សូមអរគុណ។ ហើយសូមអនុញ្ញាតបន្តទៀត។

សុន្ទរកថាដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្ដីបដិវត្ត ចុះខែកញ្ញា ឆ្នាំ១៩៧៧, ប៉ុល ពត បាន អះអាងថា បក្សកុម្មុយនីស្តកម្ពុជា មានយុទ្ធសាស្ត្រជាក់លាក់ក្នុងការ "កាត់ផ្ដាច់មធ្យោបាយផ្គត់ផ្គង់ស្បៀងទាំងអស់របស់ខ្មាំង"។

លោក លោកស្រីចៅក្រម! យើងខ្ញុំសូមលើកឡើងថា ភស្តុតាងនៃអំពើ និងសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទទាំងអស់ ក្នុងការដឹកនាំ និងជំរុញឲ្យមានការសម្លាប់រង្គាល មកលើជនស៊ីវិលដែលរស់នៅទីក្រុងភ្នំពេញ បង្ហាញពីចេតនារបស់ពួកគេក្នុងការធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋទាំងនោះ។ ភស្តុតាងដែលបញ្ជាក់អំពីសេចក្ដីឈឺចាប់ដ៏ធំធេងដែលពួកគេបង្កឡើង ដោយបានដឹងជាមុន និងដោយចេតនា ក្នុងរយៈពេលប៉ុន្មានខែ មុនថ្ងៃ១៧ មេសា ១៩៧៥ បានធ្វើឲ្យបាត់បង់ជំនឿទាំងស្រុង ទៅលើការអះអាងរបស់មេធាវីការពារក្ដី ដែលថាជនជាប់ចោទពិតជាមានបំណងជួយប្រជាពលរដ្ឋមែននោះ។ និយាយជាក់ស្ដែងទៅ ភស្តុតាងនេះបង្ហាញលើសពីវិមតិសង្ស័យថា ជនជាប់ចោទពិតជាមានការទទួលខុសត្រូវទាំងស្រុងចំពោះស្ថានភាពមនុស្សធម៌ដ៏ធ្ងន់ធ្ងរនៅទីក្រុងភ្នំពេញ។

[១៣:២១:៥២]

ដូចដែលយើងខ្ញុំបានបង្ហាញពីមុនរួចមកហើយ ពួកគេមានបំណងបង្កការឈឺចាប់បែបនេះ ដោយហេតុថាពួកគេបានចាត់ទុកប្រជាពលរដ្ឋរស់នៅទីក្រុងថាជាខ្មាំងពិតៗ ឬជាខ្មាំងដែលមានសក្ដានុពល។ ហើយនៅចំពោះមុខ លោក លោកស្រីចៅក្រម នៅថ្ងៃនេះ ពួកគេព្យាយាមទាញហេតុផលទៅលើការឈឺចាប់ដ៏ធ្ងន់ធ្ងរទាំងនោះ ដើម្បីប្រឌិតមូលហេតុក្លែងក្លាយចំពោះការជម្លៀសប្រជាជនដោយបង្ខំឲ្យចេញពីទីក្រុងភ្នំពេញ។

ព្រឹត្តិការណ៍ពាក់ព័ន្ធបន្ថែមទៀតនៅក្នុងអំឡុងពេលនោះគឺ សេចក្ដីសម្រេចចិត្តរបស់មេដឹកនាំខ្មែរក្រហមក្នុងការសម្លាប់សមាជិកជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ។ នៅថ្ងៃទី២៤ និង ២៥ ខែកុម្ភៈ ឆ្នាំ ១៩៧៥ ខៀវ សំផន បានធ្វើជាអធិបតីភាពនៅក្នុងសមាជជាតិរបស់រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិលើកទី២ ដែលបានប្រកាសថា "មន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរមានដូចជា លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, និង ស្វស្ដែន ហ្វែណង់ដែស គឺជាមេក្លោងក្បត់ជាតិ ហើយ "ដាច់ខាតត្រូវតែប្រហារជីវិតពួកគេ"។ ក្នុងចំណោម

បុគ្គលទាំងប្រាំពីរនាក់នេះ មានពីរនាក់គឺ នាយករដ្ឋមន្ត្រី ឡុង បូរ៉េត និងទ្រង់ សិរិមតៈ បានស្ថិតនៅក្នុងទីក្រុងភ្នំពេញនៅឡើយ ហើយត្រូវបានចាប់ខ្លួន និងប្រហារជីវិតចោលជាមួយនឹងសមាជិកជាន់ខ្ពស់មួយចំនួនទៀតនៃរបបសាធារណរដ្ឋខ្មែរ។ ភស្តុតាងដែលបញ្ជាក់ថា នៅថ្ងៃទី១៧ មេសា ១៩៧៥ កម្មាភិបាលខ្មែរក្រហមបានដឹងឮយ៉ាងពេញលេញអំពីការបញ្ជានេះ។ សហការីរបស់ខ្ញុំក៏នឹងបង្ហាញភស្តុតាងស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈមួយចំនួនរបស់មេដឹកនាំទាំងនោះ ដែលអះអាងអំពីការអំពាវនាវរបស់ពួកគេឲ្យប្រហារជីវិតមេដឹកនាំកំពូលនៃរបបសាធារណរដ្ឋខ្មែរ។

[១៣:២៤:៣២]

វាក៏សំខាន់ផងដែរ ក្នុងការកត់សម្គាល់អំពីប្រសិទ្ធភាពនៃសេចក្តីសម្រេចចេញពីសមាជលើកទី២ ទៅលើមន្ត្រី ឬតំណាងដទៃទៀតនៃរដ្ឋាភិបាល និងទាហាន លន់ នល់។ សមាជជាតិនេះបានប្រកាសជាឱឡារិកថា “មន្ត្រីជាន់ទាប និងមន្ត្រីជាន់ខ្ពស់ដទៃទៀត នាយទាហាន មន្ត្រីប៉ូលីស” នៃរបបសាធារណរដ្ឋខ្មែរអាចចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជាបាន ប៉ុន្តែ តែក្នុងករណីដែល“ពួកគេត្រូវឈប់បម្រើពួកអាក្បត់ទាំងប្រាំពីរនាក់ និងឈប់សហការជាមួយពួកវាភ្លាម”។ ដូចដែលលោក ហ្វីលីព ស្បូត បានលើកឡើងហើយថា អត្ថន័យនៃសេចក្តីថ្លែងការណ៍នេះគឺ “ប្រសិនបើអ្នកឯង មិនចូលរួមជាមួយបដិវត្តន៍ភ្លាមៗទេ នោះអ្នកឯងនឹងស្ថិតនៅក្នុងប្រភេទដូចគ្នាជាមួយពួកមហាក្បត់ទាំងប្រាំពីរនាក់នេះដែរ។ ដូចដែលយើងបានឃើញហើយ ប៉ុន្មានថ្ងៃបន្ទាប់ពីការដួលរំលំរបបទីក្រុងភ្នំពេញ ទាហាន និងមន្ត្រីស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្លាប់ចោលដោយឃាតករឈាមត្រជាក់របស់កងទ័ពខ្មែរក្រហម នៅក្នុងប្រតិបត្តិការដែលបានរៀបចំទុកជាមុន និងមានលក្ខណៈជាប្រព័ន្ធ។

[១៣:២៦:០៦]

លោក លោកស្រីចៅក្រម! ខ្ញុំនឹងបន្តបង្ហាញជូននូវការចូលមកដល់ទីក្រុងភ្នំពេញ របស់កងកម្លាំងខ្មែរក្រហម និងការចុះចាញ់របស់របបសាធារណរដ្ឋខ្មែរ ការចាប់ខ្លួន និងការសម្លាប់សមាជិកជាន់ខ្ពស់នៃរបបនោះ។ ខ្ញុំនឹងបង្ហាញជូនឲ្យបានពិស្តារជាបន្តបន្ទាប់ អំពីព្រឹត្តិការណ៍នៃការប្រព្រឹត្តបទឧក្រិដ្ឋក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំ។

នៅក្នុងផ្នែកនេះ ខ្ញុំនឹងយោងទៅសៀវភៅកំណត់ហេតុប្រចាំថ្ងៃ និងសក្ខីកម្មរបស់លោក ស៊ីដនី ឆេនបើក និងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់លោក ចន ស្វេន និង សក្ខីកម្មរបស់លោក អាល់ រ៉ុក្កូហ្វ។ កំណត់ហេតុរបស់ពួកគាត់ មានលក្ខណៈពេញលេញគ្រប់គ្រាន់ ដោយសារពួកគាត់បានកត់ត្រាព្រឹត្តិការណ៍

ដែលបានកើតឡើងនៅពាសពេញទីក្រុងភ្នំពេញ ក្នុងអំឡុងពេលរបបសាធារណរដ្ឋកំពុងដួលរលំ និងក្នុងរយៈពេលប៉ុន្មានម៉ោង និងប៉ុន្មានថ្ងៃដំបូងៗនៃការចាប់ផ្ដើមកាន់អំណាចរបស់ពួកខ្មែរក្រហម។ ពួកគាត់ជាអ្នកកាសែត ដូច្នេះពួកគាត់ដឹងព័ត៌មានលម្អិត និងបានស្វះស្វែងកត់ត្រាទុកនូវព្រឹត្តិការណ៍សំខាន់ៗ ដែលកំពុងកើតមានឡើងនៅជុំវិញខ្លួនពួកគាត់។

[១៣:២៧:៣៧]

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានបន្តបាញ់គ្រាប់ប្លោងដាក់ទីក្រុងពេញមួយថ្ងៃនិងមួយយប់។ ឃ្លាំងធំស្តុកគ្រាប់រំសេវរបស់ទាហានសាធារណរដ្ឋខ្មែរត្រូវបានឡោមព័ទ្ធ។ ពួកខ្មែរក្រហមបានប្រកាសតាមវិទ្យុថា ពួកគេដណ្ដើមបានព្រលានយន្តហោះពោធិ៍ចិនតុង។ ជនរងគ្រោះដោយសារការវាយប្រហារ ត្រូវបានសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា ដែលលោក ស៊ីដនី ឆេនប៊ើក បានពិពណ៌នា នៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ថាជាទីពិឃាត។ អ្នកជំងឺ និងអ្នករបួសបានទទួលការព្យាបាលនៅកន្លែងផ្សេងផងដែរ រួមមានកន្លែងវះកាត់បណ្ដោះអាសន្ននៅសណ្ឋាគារ លើភ្នំ ដែលមានទីតាំងនៅសណ្ឋាគាររ៉ាហ្វែលសព្វថ្ងៃ។ កន្លែងនោះត្រូវបានប្រកាសថាជាតំបន់អព្យាក្រឹត្យដែលត្រូវបានការពារ និងមានចងបដាកាកបាទក្រហមធំៗ។ បុគ្គលិកកាកបាទក្រហម បានទទួលជនភៀសខ្លួនរាប់រយនាក់ឲ្យចូលទៅក្នុងសណ្ឋាគារនោះ។ នៅព្រលប់ថ្ងៃទី១៦ ខែមេសា កងពលយោធារបស់បក្សកុម្មុនីស្តកម្ពុជាមកពីភូមិភាគឧត្តរ នីរតី បូព៌ា និងភូមិភាគពិសេស បានឡោមព័ទ្ធទីក្រុងភ្នំពេញ។

[១៣:២៨:១៨]

មិនយូរប៉ុន្មាន មុនកណ្ដាលអធ្រាត្រ លោក ស៊ីដនី ឆេនប៊ើក បាននិយាយទូរស័ព្ទជាមួយលោក ឡុង បូរ៉េត ដែលជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ លោក ឡុង បូរ៉េត គឺជាមនុស្សម្នាក់ក្នុងចំណោមជនក្បត់ទាំងប្រាំពីរនាក់ ដែល ខៀវ សំផន ចេញបញ្ជាឲ្យសម្លាប់ចោល។ លោកនាយករដ្ឋមន្ត្រីបានជម្រាបលោក ឆេនប៊ើក ថា “យើងគិតថា ពួកយើងត្រូវគេបោះបង់ចោលហើយ។ យើងអស់មានមធ្យោបាយសម្ភារៈទៀតហើយ”។ គាត់បានបញ្ជាក់ថា រដ្ឋាភិបាលបានជួបគ្នានិងយល់ព្រមទម្លាក់អាវុធចុះ។ ដូច្នេះ ពួកខ្មែរក្រហមនឹងទទួលបានជ័យជម្នះឆាប់ៗ ដូចកាលរំពឹងទុក។ នៅមុនថ្ងៃរះ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ លោកឧត្តមសេនីយ៍ឯក សាក់ ស៊ុតសាខន ប្រធានឧត្តមក្រុមប្រឹក្សារដ្ឋាភិបាលសាធារណខ្មែរ បានបញ្ជូនសារព្រមទម្លាក់អាវុធចុះចាញ់ទៅជូនកងកម្លាំងដែលកំពុងសម្រុកចូលទីក្រុង ដើម្បីប្រញាប់ផ្ទេរអំណាចភ្លាមៗ។ គាត់សុំតែម្យ៉ាង គឺសុំកុំឲ្យមានការសងសឹកគ្នា ប៉ុន្តែបំណងរបស់គាត់

ត្រូវបានបដិសេធ ពុំមានការផ្ទេរអំណាចនោះទេ គឺមានតែភាពភ័យរន្ធត់តែប៉ុណ្ណោះ។

ភស្តុតាងជាច្រើនដែលលោក លោកស្រីចៅក្រម បានស្តាប់ពាក់ព័ន្ធនៅថ្ងៃនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងប្រតិចារឹកនៃការផ្សាយរបស់វិទ្យុដែលធ្វើប្រតិចារឹកដោយសេវាផ្សព្វផ្សាយមានបរទេសហៅកាត់ថា អេហ្វ.ប៊ី.អាយ.អេស របាយការណ៍មួយបានកត់ត្រាការផ្សព្វផ្សាយតាមវិទ្យុខ្មែរក្រហមនៅម៉ោងប្រាំបួនព្រឹក ដែលបានបញ្ជាក់ថា "កងកម្លាំងខ្មែរក្រហមកំពុងតែរុលទៅមុខ និងសម្រុកចូលពាសពេញទីក្រុង ដោយមានការវាយបកតបវិញបន្តិចបន្តួចប៉ុណ្ណោះ"។

[១៣:៣១:៣១]

លោក ចន ស្វេន ដែលស្នាក់នៅសណ្ឋាគារលើភ្នំ សរសេររៀបរាប់អំពីអង្គភាពសាធារណរដ្ឋខ្មែរ និងប្រជាជនស៊ីវិល កំពុងត្រៀមរៀបចំទទួលស្វាគមន៍កងកម្លាំងដែលកំពុងធ្វើដំណើរចូលមកថា "គេបានលើកទង់ជ័យសនៅគ្រប់កន្លែង។ នៅលើរថពាសដែក នៅលើសណ្ឋាគារ នៅតាមផ្ទះ នៅភាគខាងជើងនៃទីក្រុង ដែលពួកខ្មែរក្រហមទើបតែធ្វើដំណើរការកាត់។ ទាហានកម្ពុជាកំពុងត្រៀមរៀបចំបង្វេចបន្ទាប់ពីធ្វើសង្គ្រាមអស់រយៈពេលប្រាំឆ្នាំ។ ទាហានដោះឡុតគ្រាប់កាំភ្លើងចេញពីកាំភ្លើងអឹម១៦ របស់ពួកគេ និងរង់ចាំពួកឧន្ទាមដោយស្ងាត់ស្ងៀមនៅកណ្តាលថ្ងៃក្តៅ"។

ខ្ញុំសូមបង្ហាញនូវភស្តុតាងជាវីដេអូដូចខាងក្រោមនេះ៖

[១៣:៣២:៣៨]

*(ការបង្ហាញរូបភាពជាវីដេអូ)*

[១៣:៣៣:១៥]

ដោយដឹងអំពីភាពចាំបាច់ត្រូវការជៀសវាងការបង្ហូរឈាម។ ឥស្សរជនសាសនាជាន់ខ្ពស់បានប្រកាសតាមវិទ្យុផ្សាយសំឡេងក្រុងភ្នំពេញ អំពាវនាវសុំឲ្យមានភាពស្ងប់ស្ងាត់ និងសន្តិភាព។ ក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ លោក ម៉ី ស៊ីចាន់ នាយសេនាធិការកងសាធារណរដ្ឋខ្មែរបានបញ្ជាឲ្យកងកម្លាំងរបស់លោកបញ្ឈប់ការបាញ់គ្នា។ លោកបានស្នើសុំឲ្យប្រជាជនរក្សាភាពស្ងប់ស្ងាត់ ដោយប្រាប់ពាក្យថា "បងប្អូន" សំដៅលើខ្មែរក្រហម។ លោកបានលើកឡើងថា "ខ្ញុំនឹងគណៈកម្មាការពិសេសនៃមន្ត្រីយោធានឹងរៀបចំជួបជាមួយតំណាងក្រុមបងប្អូនៗប្រជាជនកម្ពុជាយើងម្ខាងទៀត ដើម្បីសម្រេចឲ្យបានសុវត្ថិភាព និងសណ្តាប់ធ្នាប់ និងស្វែងរកសន្តិភាពសម្រាប់បងប្អូនសាច់ឈាមរបស់យើងចាប់ពីខណៈនេះតទៅ"។

[១៣:៣៤:១៩]

ឧត្តមសេនីយ៍ ស៊ីចាន់ បានអញ្ជើញតំណាងភាគីខ្មែរក្រហមចូលទៅទីក្រុងភ្នំពេញ និងទីរួមខេត្តផ្សេងទៀត ដែលបើកចំហដល់ពួកលោក។ ខ្មែរក្រហមពុំបានវាយប្រហារលើទីក្រុង ដើម្បីការអញ្ជើញ ឬដើម្បីធ្វើការចរចានោះទេ។ មន្ត្រីខ្មែរក្រហមបានមកដល់ស្ថានីយវិទ្យុសំឡេងផ្សាយសំឡេង ហើយបានធ្វើការប្រកាសភ្លាមៗ ក្រោយពីការអំពាវនាវរបស់ឧត្តមសេនីយ៍។ សាររបស់ពួកគេលើកឡើងដោយចំៗគ្មានស្រពេចស្រពិល និងកំបុតៗថា "យើងសូមជូនដំណឹងទៅពួកបនអាក្បត់ លន់ នល់ និងមេបញ្ជាការពួកវាទាំងអស់ថា ពួកយើងចូលមកនេះមិនមែនដើម្បីសុំចរចាទេ ពួកយើងចូលរដ្ឋធានីតាមរយៈកងកម្លាំងប្រដាប់អាវុធនៃកងទ័ពរំដោះជាតិប្រជាជនកម្ពុជា"។ នៅក្នុងការផ្សាយសំឡេងដូចគ្នានេះដែរ មន្ត្រីខ្មែរក្រហមបានអញ្ជើញមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជាឲ្យមកជួបប្រជុំគ្នានៅក្រសួងព័ត៌មាន។ លោក ចន ស្វេន បានពិពណ៌នាថា៖ "ទាហានខ្មែរក្រហមមានអាវុធបំពាក់ពេញខ្លួន និងមានវិន័យ"។ អង្គហេតុនេះស៊ីសង្វាក់ជាមួយនឹងការរៀបរាប់របស់លោក ស៊ីដនី ឆេនបើក ដែលបានលើកនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់លោកថា៖ "ទាហានខ្មែរក្រហមដែលលោកបានឃើញគឺជាទាហាន ស៊ូនឹងសមរភូមិ មានវិន័យ និងបំពេញគ្រប់ភារកិច្ច"។

[១៣:៣៦:០៧]

នៅក្នុងអត្ថបទមួយចេញផ្សាយនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៧៥ លោក ស៊ីដនី ឆេនបើក បានសរសេរថា៖"កងទ័ពដែលយើងបានឃើញនៅក្នុងក្រុងភ្នំពេញរួមបញ្ចូលទាំងយុទ្ធនារី និងកងឈ្លបកុមារដែលមានអ្នកខ្លះទំនងជាមានអាយុមិនលើស១០ឆ្នាំ ប៉ុន្តែអ្នកទាំងនេះមានសុខភាពល្អ មានសណ្ដាប់ធ្នាប់ត្រឹមត្រូវ។ ពួកគេមានអាវុធបំពាក់ពេញខ្លួន និងទទួលការហ្វឹកហាត់ត្រឹមត្រូវ"។ លោក អាល់ រ៉ុក្កូហ្វ អតីតយុទ្ធជនអាមេរិកដែលធ្លាប់បានបម្រើជួរកងទ័ពនៅក្នុងប្រទេស នៅសង្គ្រាមវៀតណាមបានបម្រើការងារជាមួយអ្នកថតរូបអាជីពនៅក្នុងក្រុងភ្នំពេញ លោកបានចំណាយពេលជាច្រើនម៉ោងនៅព្រឹកនោះថតរូបនៅចំណុចប្រសព្វវិថីព្រះសីហនុ និងវិថីព្រះមុនីវង្ស។ លោកបានផ្ដល់សក្ខីកម្មថា៖ "ពួកទាហានខ្មែរក្រហមមានបណ្ដាញវិទ្យុយ៉ាងល្អមួយ"។ លោក រ៉ុក្កូហ្វ បានផ្ដល់សក្ខីកម្មថាលោកបានឃើញទាហានសាធារណរដ្ឋខ្មែរដាក់កាំភ្លើងចុះចាញ់ ហើយបន្ទាប់មក ទាហានទាំងនេះជាច្រើនរយនាក់ត្រូវបានគេបណ្ដើរចេញទៅទិសខាងលិចពីចំណុចប្រសព្វវិថីព្រះសីហនុ និងវិថីព្រះមុនីវង្ស។ លោកក៏បានបញ្ជាក់ផងដែរថា រូបថតមួយសន្លឹកដែលថតដោយលោក រ៉ូឡាន់ ណឺវូ ដែលបានបង្ហាញការបណ្ដើរអ្នកទោស

សាធារណរដ្ឋខ្មែរដូចគ្នានឹងអ្នកទោសដែលឃើញនៅថ្ងៃនោះ”។ លោក ឆេនបើក, លោក ស្វេន និង លោក រ៉ុក្ហូ និងលោក ឌិត ប្រន ដែលជាមិត្តភក្តិរបស់លោក ឆេនបើក និងជាអ្នកបកប្រែផងបានទៅមន្ទីរពេទ្យព្រះកេតុមាលា និងបានឃើញអ្នកជំងឺហូរឈាមរហូតដល់ដាច់ខ្យល់ស្លាប់នៅច្រកដើរចូលពេទ្យ”។

[១៣:៣៨:១៨]

ក្នុងពេលពួកគេកំពុងដើរចាកចេញពីមន្ទីរពេទ្យនោះ ជនបរទេសទាំងបីរូបនេះត្រូវបានទាហានខ្មែរក្រហមចាប់ខ្លួន ពួកខ្មែរឃាត់ខ្លួនពួកគេអស់ជាច្រើនម៉ោងមុននឹងដោះលែងពួកគេវិញ។ ដោយសារតែពេលវេលាខ្លី ខ្ញុំនឹងមិនបង្ហាញអំពីហេតុការណ៍នេះឲ្យបានលម្អិតនោះទេ។ ប៉ុន្តែចំណុចសំខាន់មួយដែលពាក់ព័ន្ធនឹងហេតុការណ៍នេះគឺរបៀបដែលពួកយោធាខ្មែរក្រហមអនុវត្តការក្តោបក្តាប់អំណាចរបស់ខ្លួនលើពួកទាហានថ្មើរជើង។ លោក ឆេនបើក និងលោក រ៉ុក្ហូ ជឿជាក់ថា ពួកគាត់ច្បាស់ជាត្រូវពួកខ្មែរក្រហមសម្លាប់ចោល ប៉ុន្តែពួកគាត់បានរួចជីវិតដោយសារបានមិត្ត និងសហការីខ្មែរជួយអង្វរ គឺលោក ឌិត ប្រន។ លោក ឌិត ប្រន បានធ្វើដំណើរទៅបញ្ជាការដ្ឋានរបស់ខ្មែរក្រហមជាមួយនឹងមន្ត្រីខ្មែរក្រហមម្នាក់។ ភស្តុតាងនេះបង្ហាញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទាហានខ្មែរក្រហមមិនមែនបាត់ម្ចាស់ការ ឬគ្មានវិន័យនោះទេ ផ្ទុយទៅវិញពួកគេមានវិន័យ និងមានការចាត់តាំងត្រឹមត្រូវ និងពួកគេធ្វើតាមខ្សែសង្វាក់បញ្ជារបស់ពួកគេ។ ពួកគេសុំ និងទទួលបញ្ជាពីថ្នាក់លើរបស់ខ្លួនពាក់ព័ន្ធនឹងចំណាត់របៀបណាចំពោះជនបរទេស។ លោក ឆេនបើក បានផ្តល់សក្ខីកម្មថា “នៅពេលគេដោះលែង និងជនបរទេសផ្សេងទៀតនោះ ពួកខ្មែរក្រហមមិនបានដោះលែងពួកលោក -- ពួកទាហានសាធារណរដ្ឋខ្មែរមួយចំនួន ដែលពួកខ្មែរក្រហមបានចាប់មុននេះនោះឡើយ។ បន្ទាប់មកលោក ឆេនបើក ជាមួយសហសេវិករបស់គាត់ម្នាក់ទៀតបានបន្ត ដំណើរទៅក្រសួងព័ត៌មាននៅទីនោះ ពួកគាត់បានឃើញមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដែលពួកទាហានទាំងនោះហៅថា “អ្នកទោស”របស់ខ្មែរក្រហម។ យោងតាមកំណត់ហេតុប្រចាំថ្ងៃរបស់លោក ស៊ីដនី ឆេនបើក បានសរសេរថា៖

[១៣:៤០:៤៥]

“យើងបានដើរឆ្ពោះទៅកាន់ក្រសួងព័ត៌មាន ដោយសារមានការផ្សាយតាមវិទ្យុ អំពាវនាវឲ្យមន្ត្រីជាន់ខ្ពស់នៃរបបចាស់ទៅបង្ហាញខ្លួននៅទីនោះ។ នៅពេលយើងទៅដល់ អ្នកទោសប្រមាណ៥០នាក់កំពុងឈរនៅក្រៅអគារមួយដែលមើលទៅហាក់ដូចជាទីបញ្ជាការបណ្តោះអាសន្នរបស់ពួកទាហានខ្មែរ

ក្រហម។ ក្នុងចំណោមអ្នកទោសទាំងនោះរួមមាន ឧត្តមសេនីយ៍ត្រី លន់ នន់ ជាប្អូនប្រុសរបស់សេនាប្រមុខ លន់ នល់, ឧត្តមសេនីយ៍ត្រី ឈឹម ឈួន ដែលជាអ្នកជំនិតនឹងសេនាប្រមុខ។ ឧត្តមសេនីយ៍ និងរដ្ឋមន្ត្រីផ្សេងទៀតរបស់រដ្ឋាភិបាលក៏មានវត្តមាននៅក្នុងចំណោមនោះដែរ។ ពួកគេមើលទៅសុទ្ធតែ ភ័យ និងមិនស្រួលក្នុងចិត្ត ប៉ុន្តែព្យាយាមធ្វើជា នឹងនរ ស្ងប់ស្ងាត់។ យើងក៏បានដឹងដែលថា សម្តេចសង្ឃទាំងពីរគណៈក៏បានមកដល់ទីនេះដែរ តែត្រូវបញ្ជូនឲ្យត្រលប់ទៅវត្តវិញហើយ។ បរិយាកាសពិតជាតឹងតែង។ ក្រុមទាហាន កុមារខ្មែរក្រហមមួយកងអនុសេនាតូចបានរត់ស្ងាត់ៗចូលក្នុងត្រង់សេនៅទីផ្លាស្នៅ សួនច្បារ ខ្លះពួនក្រោយដើមឈើ ខ្លះទៀតក្រោយសរសរ - ហ្វឹកហាត់ប្រើកាំភ្លើងដៃ និងកាំភ្លើងធុនធ្ងន់នៅទីនោះ"។

ការសង្កេតពិស្តាររបស់លោក ចន ស្វេន ត្រូវបានកត់ត្រានៅក្នុងអត្ថបទមួយដែលចុះផ្សាយក្នុងកាសែត ឌឹ ថៃមស៍។ គាត់បានឃើញដោយផ្ទាល់ភ្នែករបស់គាត់ នូវការអនុវត្តគោលនយោបាយរើសអើងបែងចែក និងវែកមុខរក ដែលខ្ញុំនឹងបកស្រាយលម្អិតបន្ថែមជូនអង្គជំនុំជម្រះ នៅពេលខ្ញុំចូលដល់ការសម្លាប់មន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ។ លោក ចន ស្វេន បានសរសេថា៖

[១៣:៤២:៥៤]

"ត្រលប់ទៅក្រសួងព័ត៌មានវិញ មានបុរសម្នាក់វ័យប្រហែល៣៥ឆ្នាំ ពាក់ខោអាវខ្មៅ ហើយមើលទៅច្បាស់ជាមេគេ បានស្រែកជំទាលតាមមីក្រូ បំពងសំឡេងដាក់អ្នកទោសទាំងអស់នោះ ឲ្យចែកគ្នាជាបីក្រុម ទាហាន អ្នកនយោបាយ និងប្រជាជនស៊ីវិល។ ពួកខ្មែរក្រហមដែលកំពុងរៀនប្រើអាវុធទាំងនោះសុទ្ធតែកាចៗ ទឹកមុខមាំៗ សម្រាប់ពួកយើងដែលឈរនៅទីនោះ ពួកខ្មែរក្រហមទាំងនោះប្រៀបដូចជាមនុស្សមកពីភពផ្សេងអញ្ចឹង"។

លោក ស៊ីដនី ឆេនប៊ើក ក៏បានពិពណ៌នាដូចគ្នានឹងការបំបែកគ្នានេះ។ នៅក្នុងសក្ខីកម្មរបស់គាត់ លោក ឆេនប៊ើក បានសរុបសង្ខេបការសង្កេតរបស់គាត់លើមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរនៅឯក្រសួងព័ត៌មានដូចខាងក្រោម៖

"ច្បាស់ណាស់ ពួកគេភ័យ ហើយខ្ញុំគិតថាភាគច្រើនក្នុងចំណោមពួកគេ បានដឹងហើយថាពួកគេនឹងត្រូវគេយកទៅសម្លាប់"។ គាត់ក៏បានបញ្ជាក់ថា វាជាការពិតចំពោះអ្វីដែលគាត់បានសរសេរចូលក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ថា៖ "ខណៈពេលដែលកិច្ចសន្ទនាចេះតែបន្ត លន់ នន់ បានលបដើរទៅមុខបន្តិច និយាយខ្សឹបៗ ជាមួយអ្នកយកព័ត៌មានបារាំងម្នាក់ សុំឲ្យជួយសួរទៅមេទាហានខ្មែរក្រហម

ហ្នឹង ថាតើអ្នកទោសនៅទីនេះថ្ងៃនេះ ឬមន្ត្រីដទៃទៀត អាចចាកចេញពីប្រទេសកម្ពុជាបានទេ ប្រសិនបើពួកគេចង់។ បន្តិចក្រោយមក អ្នកយកព័ត៌មានសញ្ជាតិបារាំងម្នាក់នោះមានឱកាសសួរសំណួរនេះ។ មេទាហាននោះបានឆ្លើយសើចយ៉ាងទន់ភ្លន់ថា វាអាស្រ័យលើរដ្ឋាភិបាលទេ។ គេនឹងធ្វើច្បាប់។ គាត់ថាគាត់គ្រាន់តែជាមេបញ្ជាការយោធាម្នាក់ប៉ុណ្ណោះ ដោយបន្ថែមទៀតថាមេដឹកនាំនយោបាយនិងរដ្ឋាភិបាលនៅមិនឆ្ងាយពីទីក្រុងប៉ុន្មានទេ ប៉ុន្តែពួកគាត់ឲ្យទាហានចូលមកមុនដើម្បីរៀបចំឲ្យរៀបរយឲ្យហើយ"។

លោក អាល់ រ៉ុកូហ្វ បានថតព្រឹត្តិការណ៍បែបនេះមួយសន្លឹកពីក្រៅបរិវេណទីស្តីការក្រសួងព័ត៌មាន នៅម៉ោងប្រមាណបួនរសៀលនៅថ្ងៃនោះ ពេលដែលគាត់កំពុងនៅជាមួយលោក ចន ស្វេន និងលោក ស៊ីដនី ឆេនបើក។ ៣៨ឆ្នាំក្រោយមក គាត់បានផ្តល់សក្ខីកម្មចំពោះមុខ លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះ។ គាត់បានដឹងច្បាស់ថារូបថតមួយសន្លឹកនេះមានសារៈសំខាន់ណាស់ ដោយគាត់បានពន្យល់ថា៖ "នោះជារូបថតរបស់ខ្ញុំ។ ខ្ញុំចាត់ទុកវាជារូបថតប្រវត្តិសាស្ត្រដ៏សំខាន់បំផុតមួយ។ អន្តរកាលមួយ"។

[១៣:៤៦:២១]

ទាក់ទងនឹងអ្វីដែលបានកើតឡើង នៅពេលគាត់ចុចបើកកាមេរ៉ាថតដើម្បីថតរូបមួយសន្លឹកនេះ លោក អាល់ រ៉ុកូហ្វ បានថ្លែងឲ្យដឹងថា៖ "មន្ត្រីរដ្ឋការ លន់ នល់ មួយរូបកំពុងជជែកពិភាក្សា ព្យាយាមវែកញែកចំណុចមួយពីរទៅកាន់ខ្មែរក្រហម។ ពួកខ្មែរក្រហមកំពុងសម្លឹងមើល។ ខ្មែរក្រហមម្នាក់កំពុងថតរូបក្រុមអ្នកកាសែតដែលកំពុងចុះពីឡាន។ ខ្ញុំមានម៉ាស៊ីនថតមួយនៅព្យួរជាប់នឹងក។ ខ្ញុំមិនបានលើកវាដល់ភ្នែកដើម្បីថតទេ។ ម៉ាស៊ីនថតរបស់ខ្ញុំមានកញ្ចក់អេក្រង់ខាងមុខធំ។ ខ្ញុំលួចថតរូបមួយសន្លឹកនោះចំពេលដែលមានមនុស្សម្នាក់ដើរតម្រង់មកកញ្ឆក់យកម៉ាស៊ីនថតពីខ្ញុំ"។ រូបថតនេះពិតជាបានបង្ហាញយ៉ាងច្បាស់ថាខ្មែរក្រហមបានដៅមុខសញ្ញា និងបែងចែកមន្ត្រីសាធារណរដ្ឋខ្មែរ ក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះក្រោយពួកគេចូលមកដល់ទីក្រុងភ្នំពេញ។ ភស្តុតាងនេះបានបង្ហាញយ៉ាងច្បាស់ថា អ្វីដែលក្រុមមេធាវីការពារក្តីតែងខិតខំលើកឡើងខុសពីការពិត ថាមិនដែលមានគោលនយោបាយបែបនេះនៅពេលនោះ លែងមានអ្វីត្រូវសង្ស័យទៀតហើយ។ សាច់រឿងមិនពិតរបស់មេធាវីការពារក្តី ត្រូវបានលាតត្រដាងបន្ថែមទៀត ដោយភស្តុតាងដែលអង្គជំនុំជម្រះបានស្តាប់អំពីឧត្តមសេនីយ៍នានាក្នុងរបបសាធារណរដ្ឋខ្មែរ រួមទាំងឧត្តមសេនីយ៍ ចាច់ សារី។

[១៣:៤៨:១៥]

លោក លោកស្រីចៅក្រម បានស្តាប់រួចមកហើយ សក្ខីកម្មរបស់ប្អូនជីដូនមួយរបស់លោកស្រី លោកស្រី ចាច់ ផាន់ដារាសា ដែលបានពន្យល់ថា ឧត្តមសេនីយ៍រូបនេះបានធ្វើដំណើរទៅក្រសួងព័ត៌មាន តាមការអំពាវនាវតាមវិទ្យុរបស់ខ្មែរក្រហម។ ឧត្តមសេនីយ៍ ចាច់ សារី ត្រូវបានសម្លាប់ជាមួយមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរដទៃទៀត ដែលទៅបង្ហាញខ្លួននៅក្រសួងព័ត៌មាននោះ។ ការស្លាប់របស់គាត់ត្រូវបានបញ្ជាក់ច្បាស់តាមការរាយការណ៍របស់ទីភ្នាក់ងារសារព័ត៌មានបារាំងមួយដែលបានចុះបញ្ជីរាយនាមឧត្តមសេនីយ៍៥៤រូប ដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម។ ឧត្តមសេនីយ៍ត្រី ជឹម ឈុន ដែលជាប់ឃុំនៅក្រសួងព័ត៌មានក្នុងពេលជាមួយគ្នានឹងឧត្តមសេនីយ៍ ចាច់ សារី ដែរនោះ ក៏ត្រូវបានគេរាយ-ការណ៍ថាត្រូវបានគេសម្លាប់ចោលជាមួយបណ្តាឧត្តមសេនីយ៍ផ្សេងទៀត ដែលមានក្នុងបញ្ជីរាយនាមនោះ។

នៅក្រសួងព័ត៌មាននេះដែរ លោក ស៊ីដនី ឆេនប៊ើក ក៏បានឃើញការមកដល់របស់លោក ឡុង បូរ៉េត នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ក្រោយមកលោក ឡុង បូរ៉េត ត្រូវបានគេសម្លាប់ចោល បន្ទាប់ពីមានបញ្ជាសម្លាប់ពី "គណៈដឹកនាំបោសសម្អាតខ្មាំង"។ យោងតាម ហ្វីលីព ស្សូត កាលៈទេសៈពេលនោះគឺ៖ នាយករដ្ឋមន្ត្រី ឡុង បូរ៉េត, លោក លន់ នន់ និងមន្ត្រីជាន់ខ្ពស់របស់សាធារណរដ្ឋខ្មែរដទៃទៀត ត្រូវបានគេយកទៅសម្លាប់ចោលនៅក្នុងបរិវេណមជ្ឈមណ្ឌលកីឡាមួយដែលនៅមិនឆ្ងាយប៉ុន្មានពីទីស្តីការក្រសួងព័ត៌មាន ដែលពួកគេត្រូវបានឃុំឃាំង។

[១៣:៥០:១៨]

លោក ឆេនប៊ើក បានរៀបរាប់អំពីការធ្វើដំណើររបស់គាត់ចាកចេញពីក្រសួងព័ត៌មានដូចតទៅ៖ "គេកំពុងនាំអ្នកទោសចូលទៅក្នុងអគារ នៅពេលដែលយើងចាកចេញពីក្រសួងព័ត៌មាន។ វាជាពេលចុងក្រោយហើយ ដែលយើងបានឃើញពួកគេ"។ ក្រោយពីលោក ស៊ីដនី ឆេនប៊ើក និងសហការីរបស់គាត់បានចាកចេញពីក្រសួងព័ត៌មាន ពួកគាត់បានកត់សម្គាល់ឃើញថា ការជម្លៀសដោយបង្ខំចេញពីទីក្រុងគឺជាការជម្លៀសទ្រង់ទ្រាយធំពេញលេញតែម្តង។ នៅក្នុងបន្ទប់សវនាការនេះ លោក ឆេនប៊ើក បានរៀបរាប់អំពីការជម្លៀសថាជា"ការបណ្តេញចេញពីទីក្រុងភ្នំពេញតែម្តង មិនមែនជាការបណ្តេញចេញដោយជិះក្នុងឡានទេ តែជាការបណ្តេញចេញដូចគោក្របីអឺចឹង" ឲ្យចេញពីទីក្រុងឆ្ពោះទៅកាន់ជនបទ។

នៅក្នុងអំឡុងពេលនោះ លោក ឆេនប៊ើក បានទៅដល់ស្ថានទូតបារាំង ដែលបានក្លាយជាជម្រកសម្រាប់រូបគាត់ និងជនបរទេសផ្សេងទៀតសម្រាប់រយៈពេល១៣ថ្ងៃខាងមុខ។ គាត់បានប្រឈមមុខទៅ

នឹងស្ថានភាពច្របូកច្របល់ ដែលបានកត់ត្រានៅក្នុងសៀវភៅកំណត់ត្រាប្រចាំថ្ងៃរបស់គាត់ថា “នៅឯស្ថានទូតបារាំងវាក្លាយជាឋាននរកទៅហើយ។ ទ្វាររបងត្រូវបានបិទ និងចាក់សោរដើម្បីកុំឲ្យហ្វូងមនុស្សដែលឥតសណ្តាប់ធ្នាប់សម្រុកចូលពពាក់ពពូន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មនុស្សរាប់សិបនាក់ រួមទាំងប្រជាជនកម្ពុជាផងដែលកំពុងតែសម្រុកចូលមក ដោយហុចកូនៗរបស់ពួកគេរំលងរបងចម្រឹងដែកខ្ពស់ដែលមានចុងស្រួច បន្ទាប់មកគ្រវាត់របស់របរខ្លួនរំលងរបង ហើយចុងក្រោយ ពួកគេក៏ឡើងតាមរបងដោយខ្លួនឯងតែម្តង ។

[១៣:៥២:៣៤]

ទ្រង់ សិរិមតៈ ទទួលបានសិទ្ធិចូលទៅក្នុងស្ថានទូតបារាំង បើទោះបីជាគាត់ត្រូវបានថ្កោលទោសប្រហារជីវិតដោយបញ្ជារបស់ ខៀវ សំផន ក៏ដោយ។ ខ្មែរក្រហមមានបំណងស្វែងរកព្រះអង្គ និងធ្វើគុតព្រះអង្គ។ ដូច្នេះបទបញ្ជានេះត្រូវតែអនុវត្ត។ មន្ត្រីរបបសាធារណរដ្ឋខ្មែរមួយចំនួនក៏បានចូលមកក្នុងស្ថានទូតបារាំងដើម្បីសុំសិទ្ធិជ្រកកោន។ ពួកគេទាំងអស់គ្នាបានបញ្ជូនឲ្យខ្មែរក្រហម។

ខ្ញុំសូមបង្ហាញជូននូវភស្តុតាងវីដេអូមួយទៀត។

[១៣:៥៣:៣៤]

*(ការបង្ហាញឯកសារជាវីដេអូ)*

[១៣:៥៤:២៤]

នៅប៉ុន្មានថ្ងៃបន្ទាប់ពីនោះមកទៀត គណៈកម្មាធិការខ្មែរក្រហមដែលបានប្រាស្រ័យទាក់ទងជាមួយស្ថានកុងស៊ុលប្រទេសបារាំង គឺលោក ហ្សង់ ឌីរ៉ាក់ បានទាមទារឲ្យប្រជាជនកម្ពុជាទាំងអស់ចាកចេញពីស្ថានទូតនេះ និងធ្វើដំណើរទៅទិសខាងជើងឆ្ពោះទៅកាន់ទីជនបទ។ យោងតាមលោក ឆេនប៊ើកប្រជាជនកម្ពុជាប្រហែល ៥០០នាក់បានស្នើសុំសិទ្ធិជ្រកកោននៅក្នុងបរិវេណស្ថានទូតនេះ។

សៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់លោក ឆេនប៊ើក ក៏បានកត់ត្រាពីការបំបែកបំបាក់ក្រុមគ្រួសារនៅពេលប្រជាជនកម្ពុជាត្រូវបានគេបង្ខំឲ្យចាកចេញពីក្នុងបរិវេណស្ថានទូត។ សារទូរលេខចុះថ្ងៃទី២១ ខែមេសា ផ្ញើដោយកុងស៊ុលបារាំងទៅកាន់ក្រសួងការបរទេសបារាំងនៅទីក្រុងប៉ារីស រៀបរាប់អំពីការបំបែកក្រុមគ្រួសារ និងការបង្ខំឲ្យប្រជាជនកម្ពុជាចេញពីបរិវេណស្ថានទូត។ សារទូរលេខសរសេរថា ពួកគេទាំងអស់គ្នាកំពុងទទួលរងនូវការឈឺចាប់ដែលមិនអាចទ្រាំបាន។ អ្នកខ្លះត្រូវបែកគ្នាបន្ទាប់ពីបានរួមរស់ជាមួយគ្នាអស់រយៈ១៥ឆ្នាំ ឬ២០ឆ្នាំមកហើយ។ នៅទីនេះសូម្បីតែប្រុសៗក៏យំដែរ។

ម្សិលមិញ ទារកមួយបានកើតនៅស្ថានទូត។ ម្តាយគេត្រូវចាកចេញពីស្ថានទូតថ្ងៃនេះ។ ក្មេងប្រុសនេះក្លាយជាកូនខ្ញុំសព្វថ្ងៃ។ យើងបានយកគេធ្វើជាកូនចិញ្ចឹម" ។ នៅពេលប្រជាជនកម្ពុជាមួយក្រុមធំ បានចាកចេញពីស្ថានទូតនៅថ្ងៃទី២១ ខែមេសា លោក ឆេនប៊េក ក៏បានរៀបរាប់អំពីរបៀបដែលមន្ត្រីខ្មែរក្រហម បានបោសសម្អាតបរិវេណដើម្បីបណ្តេញប្រជាជនកម្ពុជាដែលនៅសេសសល់។ ក្នុងខណៈដែលប្រជាជនកម្ពុជាធម្មតា ត្រូវបានគេបង្ខំឲ្យចាកចេញពីស្ថានទូត នៅក្រោមការបញ្ជារបស់ខ្មែរក្រហមនោះមន្ត្រីរបបសាធារណរដ្ឋខ្មែរដែលមានឋានៈខ្ពង់ខ្ពស់ត្រូវបានប្រគល់ទៅឲ្យកងកម្លាំងខ្មែរក្រហម។ សារទូរលេខនានាមកពីស្ថានទូតបារាំងបានកត់ត្រាអំពីបញ្ហានេះ។ សារទូរលេខមួយច្បាប់ចុះថ្ងៃទី១៨ ខែមេសា ១៩៧៥ មានចំណងជើងថា "ការសុំសិទ្ធិជ្រកកោនខាងនយោបាយ" បញ្ជាក់ថាឥស្សរជនជាន់ខ្ពស់មួយចំនួនមានវត្តមានៅក្នុងបរិវេណនោះ រួមមាន ទ្រង់ សិរិមតៈ, ម្ចាស់ក្សត្រី ម៉ុម ម៉ាណុង, អ៊ុង ប៊ុនហោប្រធានរដ្ឋសភានៃរបបសាធារណរដ្ឋខ្មែរ និងលោក លឿង ណាក់ រដ្ឋមន្ត្រីក្រសួងសុខាភិបាលនៃរបបសាធារណរដ្ឋខ្មែរ។

[១៣:៥៧:៥១]

នៅក្នុងសារទូរលេខនោះ លោក ឌីវ៉ាក់ បានបញ្ជាក់ថា៖ "ដោយមានការបញ្ជា ហាមឃាត់យ៉ាងច្បាស់លាស់ និងជាបន្ទាន់ពីក្រសួងដែលសុំមិនឲ្យខ្ញុំផ្តល់សិទ្ធិជ្រកកោនផ្នែកនយោបាយ នោះខ្ញុំត្រូវបានបង្ខំចិត្តប្រគល់ឈ្មោះទាំងនេះទៅឲ្យពួកគេនៅក្នុងរយៈពេល ២៤ម៉ោង" ។

ដូចបានបញ្ជាក់នៅក្នុងសារទូរលេខចុះថ្ងៃទី២០ ខែមេសា ទ្រង់ សិរិមតៈ និងអ្នកដទៃទៀតដែលបានលើកឡើងនៅក្នុងសារទូរលេខមុនត្រូវបានប្រគល់ឲ្យស្ថិតនៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម។ ភស្តុតាងនេះបង្ហាញពីការរែកមុខរកមន្ត្រីរបបសាធារណរដ្ឋខ្មែរក្នុងគោលបំណងប្រហារជីវិត ដោយមានការរៀបចំទុកជាមុន និងជាប្រព័ន្ធរបស់ខ្មែរក្រហម។ ដូចដែលបានកត់ត្រាទុកដោយអង្គការលើលែងទោសអន្តរជាតិ, អៀង សារី បានអះអាងជាសាធារណៈនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ថា ឡុង បូរ៉េត, សិរិមតៈ និង លន់ នល់ ត្រូវបានប្រហារជីវិត។ ភស្តុតាងនៅចំពោះមុខតុលាការនេះ ក៏បង្ហាញអំពីការប្រហារជីវិតនាយទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ដោយមានការរៀបចំទុកជាមុនភ្លាមៗ និងបន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

[១៣:៥៩:៣៣]

លោក លោកស្រី ចៅក្រម ឥឡូវនេះខ្ញុំនឹងបង្ហាញជូននូវភស្តុតាងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្ត

ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ និងជម្លៀសប្រជាជនដោយបង្ខំទៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យចាប់ផ្ដើមពីខែកញ្ញា ឆ្នាំ១៩៧៥។

ភស្តុតាងនៅចំពោះមុខលោក លោកស្រីចៅក្រម បញ្ជាក់លើសពីវិមតិសង្ស័យ អំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ និងអស្តិរភាពនៃចេតនាឧក្រិដ្ឋរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែលអ្នកទាំងនេះបានប្រព្រឹត្តបទឧក្រិដ្ឋផ្ទាល់ ព្រមទាំងអំពើហិង្សា និងភាពសាហាវយង់ឃ្នង់នៃការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះផងដែរ។

ដូចខ្ញុំបានបញ្ជាក់ជូននៅក្នុងសេចក្ដីថ្លែងបើកសវនាការថា “ផែនការរួមមួយដោយអនុវត្តនៅគ្រប់ព្រឹត្តិការណ៍ទាំងនេះគឺផែនការប្រើអំពើហិង្សាជ្រុលហួសហេតុមកលើប្រជាជនស៊ីវិល នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងនៅថ្ងៃបន្តបន្ទាប់មកទៀត”។ មនុស្សរាប់រយម៉ឺននាក់បានស្លាប់ដោយរងអំពើអមនុស្សធម៌ ក្នុងអំឡុងពេលឲ្យដើរទាំងហ្វូងៗនៅពេលជម្លៀស និងនៅពេលដែលទៅដល់សហករណ៍ និងការដ្ឋានដែលត្រួតត្រាដោយបក្សកុម្មុយនីស្តកម្ពុជាភ្លាមៗ។

[១៤:០១:២០]

មនុស្សជាច្រើនត្រូវបានគេសម្លាប់នៅក្នុងពេលជម្លៀស។ មនុស្សរាប់លាននាក់បានក្លាយទៅជាជនរងគ្រោះ ដោយសារតែការជម្លៀសពីលំនៅដ្ឋានដោយបង្ខំក្នុងស្ថានភាពអមនុស្សធម៌។ ការជម្លៀសអ្នកទីក្រុងភ្នំពេញដោយបង្ខំ គឺជាព្រឹត្តិការណ៍ដ៏គួរឲ្យខ្លោចផ្សាមួយ ប្រជាជនជាច្រើនបានរងទុក្ខវេទនាយ៉ាងក្រៃលែង ដោយសារតែលទ្ធផលដោយផ្ទាល់ និងជាយថាហេតុនៃការចេញបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងដោយឥតមានការលើកលែងនេះ។ សាក្សីជំនាញ គឺលោក ហ្វីលីព ស្សុត បានរៀបរាប់ព្រឹត្តិការណ៍នេះនៅក្នុងសៀវភៅរបស់គាត់ថា៖ “ការជម្លៀសប្រជាជនជាង២,៥លាននាក់ ចេញពីទីក្រុងដែលមានមនុស្សរស់នៅដ៏ច្រើនកុះករ និងចម្រុះជាតិសាសន៍។ ដោយគ្រាន់តែជូនដំណឹងពីរបីម៉ោងមុន និងការគ្មានកន្លែងស្នាក់នៅ គ្មានការព្យាបាលជំងឺ គ្មានមធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ និងគ្មានអ្វីហូបឬមានតែ មានតិចតួចបំផុតបែបនេះ គឺជាការនាំឲ្យប្រជាជនហែលក្នុងមហាសមុទ្រទុក្ខ”។

ខ្ញុំសូមបង្ហាញខ្សែវីដេអូមួយទៀត។

[១៤:០២:៥៥]

*(ការបង្ហាញឯកសាររូបភាពជាវីដេអូ)*

[១៤:០៤:០៦]

លោក ហ្វីលីព ស្ប៊ូត បានធ្វើសក្ខីកម្មផងដែរថា មហាទុក្ខវេទនាដែលប្រជាជនស៊ីវិលត្រូវបានទទួលរង ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ គឺមិនមែនជារឿងចម្លែកនោះទេ។ ផ្ទុយទៅវិញ គឺវាជាចរិតលក្ខណៈនៃការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជាមកលើប្រជាជនស៊ីវិលនៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ពួកគេ។ លោក ស្ប៊ូត បានគូសបញ្ជាក់បន្ថែមថា "អ្នកនឹងឃើញថា គ្រាន់តែចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្លាម អំពើគ្មានធម៌មេត្តា និងគំនិតដាច់ខាត និងការមិនឲ្យតម្លៃមនុស្ស ការមិនខ្វល់អំពីទុក្ខវេទនារបស់មនុស្ស ការមិនគិតគូដល់តម្លៃបុគ្គលម្នាក់ៗ ក៏ចាប់ផ្តើមមានភ្លាមៗដែរ។ ពួកគេអនុវត្តតាមវិធីសាស្ត្រដូចៗគ្នានេះនៅគ្រប់កន្លែង និងលទ្ធផលចុងក្រោយគឺបណ្តាលឲ្យមនុស្សជាច្រើនស្លាប់ជាបន្តបន្ទាប់។ នេះជាកម្មវិធីដែលត្រូវគេកំណត់ហើយ អ្នកនឹងឃើញអ្វីៗទាំងអស់នៅក្នុងជំហានដំបូងគឺការជម្លៀសប្រជាជនចេញពីទីក្រុង"។

[១៤:០៥:៣៣]

ការជម្លៀសត្រូវបានធ្វើឡើងយ៉ាងតក់ក្រហល់។ ដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី ចាន់ សុជាតិ បានធ្វើសក្ខីកម្មចំពោះមុខតុលាការនេះដោយបានពិពណ៌នាអំពីភាពដាច់ខាត និងតក់ក្រហល់របស់ទាហានខ្មែរក្រហម ដែលបង្ខំប្រជាជនស៊ីវិលឲ្យចាកចេញពីលំនៅដ្ឋាន។ លោកស្រីបានគូសបញ្ជាក់ថា៖ "នៅថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំនិងអ្នករស់នៅក្នុងក្រុងភ្នំពេញឯទៀត ត្រូវបានបង្ខំឲ្យចាកពីទីក្រុងភ្នំពេញភ្លាមៗ។ ខ្ញុំមានបងប្អូនប្រុសស្រី១៣នាក់ រួមទាំងឪពុកម្តាយខ្ញុំផង ទាំងអស់១៥នាក់។ ពេលសង្គ្រាមចប់ភ្លាម ខ្ញុំសង្ឃឹមបានសន្តិភាព ប៉ុន្តែមិនដូចអ្វីដែលខ្ញុំសង្ឃឹមទេ។ នៅវេលាម៉ោងប្រាំបួនព្រឹក ទាហានខ្មែរក្រហមដោយមានកាន់កាំភ្លើងផងបានដើរចូលមកផ្ទះរបស់យើង និងបានប្រាប់ពួកយើងឲ្យចេញពីផ្ទះបីថ្ងៃ ត្បិតពួកគេត្រូវការបោសសម្អាតខ្មាំងឲ្យអស់។ នៅពេលពេលនោះឪពុកមដាយខ្ញុំបានចម្អិនអាហាររួចអស់ហើយ ប៉ុន្តែយើងមិនទាន់បានហូបបាយផង ស្រាប់តែទាហានម្នាក់ទៀតចូលមកបង្ខំឲ្យពួកយើងប្រញាប់ចេញ។ ពួកទាហានខ្មែរក្រហមដែលបានបណ្តេញអ្នករស់នៅទីក្រុងឲ្យចេញពីផ្ទះសម្បែងនោះ សុទ្ធតែមានអាវុធកាន់ មានរបៀប និងមានការចាត់តាំងត្រឹមត្រូវ"។ លោក ស៊ីដនី ឆេនប៊ើក បានពិពណ៌នាអំពីសកម្មភាពរបស់ពួកទាំងនេះ នៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ថា "ក្រុមពួកទាហានឧទ្ទាមគ្រវីកាំភ្លើងខ្លី និងកាំភ្លើងវែង អ្នកខ្លះស្រែកគំហក និងអ្នកខ្លះប្រើឧបករណ៍ផ្ទុំបំពងសំឡេង។ ពួកគេបញ្ជាឲ្យប្រជាជនចេញពីលំនៅដ្ឋានជាបន្ទាន់ ពួកឧទ្ទាមបានបាញ់ឡើងកំញើញប្រជាជន"។ លោក ឆេនប៊ើក

បានបញ្ជាក់បន្ថែមនៅក្នុងសក្ខីកម្មរបស់គាត់ថា "យើងមើលឃើញច្បាស់ថា ពួកគេកំពុងព្យាយាមបណ្តេញប្រជាជនឲ្យចេញពីលំនៅដ្ឋាន និងចេញទៅតាមផ្លូវឲ្យបានឆាប់ ពួកគេធ្វើបានសម្រេចមែន"។ លោក ស៊ុំ ជា គឺជាអតីតទាហានខ្មែរក្រហមម្នាក់នៅក្នុងចំណោមពួកឧទ្ទាមនេះ។ សក្ខីកម្មរបស់គាត់នៅចំពោះមុខលោក លោកស្រីចៅក្រមមានលក្ខណៈពិស្តារ និងច្បាស់លាស់។ ដូច្នេះខ្ញុំនឹងលើកវាមកបង្ហាញជូនជាបន្តបន្ទាប់។

តាមសម្តីឥតលាក់លៀមរបស់ទាហានម្នាក់ គាត់បានធ្វើសក្ខីកម្មអំពីការធ្វើការងាររបស់គាត់ "បេសកកម្មរបស់យើងគឺជម្លៀសមនុស្សចេញឲ្យអស់ពីទីក្រុង។ យើងត្រូវធ្វើយ៉ាងម៉េចឲ្យមនុស្សចេញឲ្យអស់ពីក្រុង ធ្វើយ៉ាងម៉េចក៏ដោយ"។ បើតាមសម្តីលោក ស៊ុំ ជា ពួកគេប្រើពេលប្រាំថ្ងៃទម្រាំបណ្តេញប្រជាជនស្ទើរតែអស់គ្មានសល់ពីទីក្រុង។ សូមបង្ហាញខ្សែវីដេអូមួយទៀត។

[១៤:០៩:០៤]

*(ការបង្ហាញឯកសាររូបភាពជាវីដេអូ)*

[១៤:១១:១០]

លោក ស៊ុំ ជា បានគូសបញ្ជាក់ថា ពួកគេត្រូវអនុវត្តបញ្ជាដ៏ឃោរឃៅនេះ ដោយគ្មានករណីលើកលែងអ្វីទាំងអស់។ ត្រូវតែទៅទាំងអស់គ្នា គ្រប់លំនៅដ្ឋានសាលារៀន មន្ទីរពេទ្យកន្លែងធ្វើការគ្រប់ទីកន្លែងទាំងអស់ឲ្យតែមានមនុស្សរស់នៅ ត្រូវតែបណ្តេញចេញឲ្យអស់។ លោកស្រី ដេនីស អាហ្វុងសូ ធ្វើសក្ខីកម្មថា៖ "ប្រសិនបើយើងមិនព្រមចាកចេញ ពួកគេច្បាស់ជាចាត់ទុកពួកយើងថាជាជនក្បត់ជាពួកចក្រពត្តិ និងជាអ្នកបម្រើរបបចាស់ និងច្បាស់ជាយកយើងទៅសម្លាប់ចោលអស់បាត់ទៅហើយ។ លោកស្រី អាហ្វុងសូ បានពិពណ៌នាអំពីសកម្មភាពរបស់កងកម្លាំងខ្មែរក្រហមនៅក្នុងសក្ខីកម្មបន្តបន្ទាប់មកទៀតរបស់គាត់ថា ពួកគេដើរគ្រប់ផ្លូវ ពួកគេស្រែកបញ្ជានៅតាមផ្លូវ និងដើរតាមផ្លូវ និងតាមអគារផ្ទះល្វែងមួយៗ ដើម្បីបញ្ជាឲ្យប្រជាជនចាកចេញពីទីក្រុង។ យើងគ្មានផ្លូវជ្រើសរើសផ្សេងក្រៅពីទីនេះទាល់តែសោះ។

[១៤:១២:៣៣]

ស្របគ្នានឹងសក្ខីកម្មរបស់លោកស្រី អាហ្វុងសូ សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា ពួកគេគ្មានជម្រើសអ្វីក្រៅពីការចាកចេញពីទីក្រុងនោះឡើយ។ តាមការស្តាប់អ្វីដែលទាហានខ្មែរក្រហមប្រាប់ និងតាមរយៈការមើលឃើញសកម្មភាពរបស់ពួកខ្មែរក្រហម ប្រជាជនទីក្រុងទាំងនោះដឹងថា ប្រសិនបើពួក

គាត់មិនព្រមធ្វើតាមបញ្ជានេះ គឺពួកគាត់ច្បាស់ជាត្រូវគេវាយដំ ធ្វើបាប ឬសម្លាប់ចោលអស់ជាមិនខាន។ ពួកគាត់ត្រូវចាកចេញពីលំនៅដ្ឋានរបស់ខ្លួនដោយសារពួកគេខ្លាចស្លាប់។ ខ្ញុំនឹងដកស្រង់សម្ដីខ្លះបន្ថែមទៀតពីសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោម៖

[១៤:១៣:២៤]

អ្នកស្រី ប៉ូឌីណា បានលើកឡើងថា៖ "ពួកគេបានគំរាមយើងថា បើយើងមិនប្រញាប់ចេញទេ ពួកគេនឹងកម្ទេចចោលឲ្យអស់។ ពួកគេគំរាមកំហែងអាយុជីវិតពួកយើងផងដែរ។ លោកស្រី យឹម សុវណ្ណ បានលើកឡើងថា ដោយាសារគេគំរាមកំហែងយើងខ្លាំង យើងត្រូវតែរៀបចំអីវ៉ាន់រួចចាកចេញ។ លោក អួន ផល្លី បានលើកឡើងថា៖ "គ្រប់គ្នាត្រូវតែធ្វើតាមបញ្ជារបស់ពួកខ្មែរក្រហម បើពួកគេចង់ឲ្យទៅណាយើងត្រូវតែទៅកន្លែងនោះ"។ លោកស្រី ឆេង អេងលី ក៏បានបញ្ជាក់ដែរថា៖ "ខ្ញុំអត់មានជម្រើសទេ។ ខ្ញុំត្រូវតែចាកចេញពីផ្ទះ"។ លោកស្រី បេ សុផានី បញ្ជាក់ថា "ខ្ញុំចាកចេញពីផ្ទះដោយគេបង្ខំ"។ លោក ចៅ នី បានលោកលើកឡើងថា៖ "ទាហានខ្មែរក្រហមប្រកាសប្រាប់ប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញ នៅពេលនោះខ្ញុំឮបាញ់កាំភ្លើង។ ខ្ញុំក៏ឮសំឡេងមនុស្សរកបងប្អូន និងមិត្តភក្តិរបស់ពួកគេ។ ពេលពួកគេកំពុងចាកចេញពីទីក្រុងភ្នំពេញ នៅពេលនោះ ពួកខ្មែរក្រហមមានកាន់កាំភ្លើង ពួកគេមកដល់មុខផ្ទះបងប្រុងខ្ញុំ និងស្រែកបញ្ជាឲ្យពួកយើងចាកចេញពីផ្ទះ។

[១៤:១៤:៥៥]

ដូចលោក ចៅ នី បានបញ្ជាក់រួចហើយ ពួកគេប្រើកម្លាំងប្រដាប់អាវុធ ដើម្បីធ្វើយ៉ាងណាឲ្យប្រជាជនអនុវត្តតាមបញ្ជាជម្លៀសនេះឲ្យបាន។ អ្នកស្រី ម៉ុម សំអឿន បានផ្ដល់សក្ខីកម្មច្បាស់អំពីអង្គហេតុនេះ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់កំពុងរស់នៅជាមួយក្រុមគ្រួសារធំមួយនៅភ្នំពេញ។ គាត់ពិពណ៌នាព្រឹត្តិការណ៍ដែលបានកើតឡើងនៅពេលទាហានខ្មែរក្រហមចូលដល់ផ្ទះគាត់ដូចតទៅ៖ "ពេលនោះទាហានខ្មែរក្រហមចូលមកគំរាមខ្ញុំឲ្យចាកចេញពីផ្ទះ។ ភ្លាមនោះខ្ញុំស្ទុះទៅកាន់ទូរដែក ដើម្បីចុចលេខកូដសម្ងាត់បើកវា។ ពេលកំពុងចុចលេខកូដ ស្រាប់តែ ខ្មែរក្រហមភ្ជង់ខ្ញុំនឹងកាំភ្លើង និងបង្ខំឲ្យខ្ញុំចាកចេញពីផ្ទះ។ ប្ដីខ្ញុំត្រូវទៅជាមួយកូនស្រីពៅរបស់ខ្ញុំ ដោយឥវ៉ាន់ខ្លះតាមខ្លួន។ គេបានបង្ខំឲ្យគាត់ចេញដំណើរទៅតាមផ្លូវផ្សេងពីពួកខ្ញុំ"។

[១៤:១៦:០៨]

អ្នកស្រី អោ រី ក៏បានពិពណ៌នាអំពីការគំរាមកំហែងដោយទាហានខ្មែរក្រហមដែលមានកាន់

អាវុធនោះថា "ពួកគេកាន់កាំភ្លើង ហើយពួកគេប្រើកាំភ្លើងដើម្បីបណ្តេញប្រជាជន។ ពួកគេបានគំរាមសម្លាប់អ្នកណាដែលមិនព្រមចាកចេញ និងបង្ខំឲ្យយើងត្រូវតែចាកចេញទាំងអស់គ្នា"។

អ្នកស្រី បេ សុផានី ផ្តល់សក្ខីកម្មថា៖ "ពួកគេបាញ់ឡើងទៅលើ និងបណ្តេញពួកយើងចេញ"។ លោក អួន ផល្លី៖ "ខ្ញុំឃើញគេបាញ់កាំភ្លើង និងភ្ជង់កាំភ្លើងដាក់អ្នកដទៃ។ ខ្ញុំជឿថាគ្រួសារខ្ញុំក៏ឃើញដូច្នេះ និងគ្រួសារឯទៀតក៏ឃើញដូចគ្នានេះដែរ"។

អ្នកស្រី យិន រំដួល បានពិពណ៌នាថា ទាហានខ្មែរក្រហមបាញ់ជាច្រើនគ្រាប់ដាក់ផ្ទះគាត់ ដើម្បីបណ្តេញមនុស្សឲ្យចាកចេញពីផ្ទះ។ "នៅយប់មួយ ជីតារបស់ខ្ញុំ ដែលស្លាប់មួយចំហៀងខ្លួន សម្រាន្តលើគ្រែ។ ពេលនោះ ពួកយើងមិនទាន់ចាកចេញពីទីក្រុងភ្នំពេញនៅឡើយ។ ពួកខ្មែរក្រហមបានបាញ់ដាក់ផ្ទះយើង។ កាំភ្លើងដែលបាញ់នោះអាចជា អឹម-សី ឬ អាកា-៤៧។ ប៉ុន្តែ យើងនៅក្រាបក្នុងផ្ទះ។ មួយសន្ទុះក្រោយមក ជីតាខ្ញុំបានដុតភ្លើងបំភ្លឺ ស្រាប់តែពួកខ្មែរក្រហមបាញ់ដាក់ផ្ទះទៀត។ ក្រោយមក ទាំងអស់គ្នា ទាំងឪពុកម្តាយខ្ញុំ និងពូខ្ញុំ សម្រេចគ្នាថាត្រូវតែចាកចេញ"។

[១៤:១៧:៤២]

អ្នកស្រី ពេជ ស្រីផល ពិពណ៌នាអំពីការគំរាមកំហែង និងការវាយដំដែលគាត់បានឃើញផ្ទាល់ភ្នែក "ពួកខ្មែរក្រហមវាយដំអ្នកដែលប្រកែកមិនព្រមចាកចេញពីទីក្រុងភ្នំពេញ។ ខ្ញុំឃើញពួកគេវាយមនុស្សនឹងស្នាយកាំភ្លើង នៅក្បែរផ្សារឃ្លាំងរំសេវ"។ កងទាហានខ្មែរក្រហមជាច្រើនក្រុម ត្រូវបានដាក់ពង្រាយ ដើម្បីទប់កុំឲ្យមនុស្សវិលត្រលប់មកកាន់លំនៅដ្ឋានរបស់ពួកគេវិញ។ លោក ស៊ុំ ជា រៀបរាប់ថា៖ "មានទាហានជាច្រើនក្រុមដែលដាក់ពង្រាយ ដើម្បីការពារទីក្រុងកុំឲ្យប្រជាជនវិលត្រលប់មកកាន់ទីក្រុងវិញ។ ជាការពិត បន្ទាប់ពីចាកចេញរួចហើយ គ្មានប្រជាជនណាអាចវិលត្រលប់មកទីក្រុងវិញបានទេ"។

សរុបសេចក្តីមក ពួកខ្មែរក្រហមបានបណ្តេញប្រជាជនចេញពីទីក្រុងឲ្យអស់ភ្លាមៗ ទោះជាតាមមធ្យោបាយណាក៏ដោយ។ ប្រជាជនទីក្រុងទាំងអស់ត្រូវតែចាកចេញ ដោយគ្មានការលើកលែង គ្មានក្តីសណ្តោសប្រោសមេត្តា ឬការអាណិតអាសូរអ្វីទាំងអស់។

ខ្ញុំសូមសួរលោក លោកស្រីចៅក្រមថា តើមានប្រជាជនកម្ពុជាណាមួយដែលសុខចិត្តចាកចេញពីគ្រួសារដើម្បីទៅស្លាប់តាមចិញ្ចើមថ្នល់ដូច្នេះ? នេះគឺជាអ្វីដែលពួកខ្មែរក្រហមបង្ខំឲ្យប្រជាជនរបស់យើងធ្វើ។ ភស្តុតាងបង្ហាញថា ទាហានខ្មែរក្រហមសម្លាប់អ្នកទីក្រុងភ្នំពេញណាដែលយឺតយ៉ាវក្នុងការ

អនុវត្តតាមបញ្ជារបស់ពួកគេ។

យើងខ្ញុំសូមលើកឡើងថា រាល់បទឧក្រិដ្ឋដែលបានប្រព្រឹត្តលើប្រជាជនដែលគេជម្លៀស មានជាអាទិ៍ ការប្រព្រឹត្តដោយអមនុស្សធម៌ ការធ្វើទារុណ្ណកម្ម ការសម្លាប់ ការសម្លាប់រង្គាលជាបន្តបន្ទាប់ គឺជាផ្នែកពាក់ព័ន្ធមួយនៃផែនការឧក្រិដ្ឋរួម ដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បទឧក្រិដ្ឋទាំងនេះកើតចេញពីផលដោយផ្ទាល់ និងភ្លាមៗនៃការបញ្ជា ដែលចេញដោយមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។ លោក ស៊ុំ ជា គូសបញ្ជាក់ថា៖ "បើកុំតែធ្វើបាបមនុស្សខ្លះ កុំអីយើងមិនអាចបណ្តេញមនុស្សចេញអស់ពីទីក្រុងបានទេ"។

[១៤:២០:១៧]

បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលជម្លៀស ស៊ីសង្វាក់គ្នាទៅនឹងអ្វីៗគ្រប់យ៉ាង ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមទាំងជនជាប់ចោទទាំងនេះ បាន និងចេញបញ្ជាឲ្យធ្វើនៅមុនព្រឹត្តិការណ៍នេះកើតឡើង។ បទឧក្រិដ្ឋទាំងនេះ ស៊ីសង្វាក់គ្នាទៅនឹងអ្វីៗគ្រប់យ៉ាងដែលពួកគេបានប្រព្រឹត្តនៅពេលបន្តបន្ទាប់ក្រោយមក។ ដូចអ្វីដែលខ្ញុំបានជម្រាបជូនពីខាងលើរួចមកហើយថា ទាហានខ្មែរក្រហមត្រូវបានទទួលការបណ្តុះបណ្តាល និងបញ្ចូលមនោគមន៍វិជ្ជា ដើម្បីគិតថាមនុស្សទីក្រុងគឺសុទ្ធតែជាខ្មាំងរបស់ពួកគេ។ សំខាន់ជាងនេះ អតីតទាហានខ្មែរក្រហម ដែលបានធ្វើសក្ខីកម្មនៅចំពោះមុខលោកលោកស្រីចៅក្រមបានបញ្ជាក់ថា គ្មានច្បាប់ហាមឃាត់ពួកទាហាន មិនឲ្យធ្វើបាប ឬសម្លាប់ប្រជាជនដែលពួកគេជម្លៀសនោះឡើយ។ លោក គង់ គីម បានឆ្លើយថា "គ្មានច្បាប់ ឬ បទបញ្ជាណាមួយហាមយើងមិនឲ្យបាញ់មនុស្សនោះទេ"។ ខៀវ សំផន អះអាងនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ថា ការជម្លៀសដោយបង្ខំមានមូលហេតុត្រឹមត្រូវ ដោយសារតែមានការគំរាមកំហែងពីការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកាំង។ នេះជាការកុហកយ៉ាងច្បាស់ ពាក្យភូតភរបែបនេះ គឺដូចគ្នាទៅនឹងអ្វីដែលកងកម្លាំងខ្មែរក្រហមបោកប្រាស់ប្រជាជនដែលត្រូវគេជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ តាមពិតសេចក្តីថ្លែងការណ៍ដែលថានឹងមានការទម្លាក់គ្រាប់បែកមកលើទីក្រុង គឺមិនមានមូលដ្ឋានពិតប្រាកដនោះទេនៅថ្ងៃ១៧ មេសា ១៩៧៥ និងមិនមានមូលដ្ឋានច្បាស់លាស់រហូតមកដល់នឹងសព្វថ្ងៃនេះ។

[១៤:២២:១៨]

វាជាចេតនាកុហកភូតភរ ដែលមាការគិតទុកជាមុន ដែលពិតជាត្រូវបានរៀបចំឡើងដើម្បីឲ្យប្រជាជនអនុវត្តតាមឲ្យបានកាន់តែទូលំទូលាយ និងបង្កលក្ខណៈកាន់តែងាយស្រួលសម្រាប់កងទ័ពបក្ស

កុម្មុយនីស្តកម្ពុជា ដើម្បីឲ្យពួកគេបញ្ចប់បេសកកម្មរបស់ខ្លួនបាន។ ឥឡូវចេតនាដដែលនេះត្រូវបានគេយកមកប្រើជាមួយនឹងលោក លោក លោកស្រីចៅក្រមម្តងទៀត។

មិនមានការរំពឹងទុកថានឹងមានការទម្លាក់គ្រាប់បែកនោះទេ ហើយលោក លោកស្រីចៅក្រមបានស្តាប់ឮសាក្សីជាច្រើនលើកឡើងអំពីបញ្ហានេះ។ ផ្តើមចេញពីឯកសារភស្តុតាងនៅចំពោះមុខ លោក លោកស្រីចៅក្រម វាក៏ជាការពិតទាំងស្រុងតែម្តង។ ពួកអាមេរិកាំងឈប់ទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ គឺនៅបន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុវត្តច្បាប់មួយពាក់ព័ន្ធនឹងបញ្ហានេះ។ របបសាធារណរដ្ឋខ្មែរត្រូវបានផ្តួលរលំ និងទ័ពអាកាសរបស់របបនេះត្រូវបានបំផ្លាញខ្ទេចគ្មានសល់។ គ្មានការគំរាមកំហែងណាពាក់ព័ន្ធនឹងការទម្លាក់គ្រាប់នោះទៀតទេ គ្មានខ្មាំងឯណានៅលើមេឃនោះទេ។ តាមការពិត តាមការព្រួយបារម្ភរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ខ្មាំងពិតប្រាកដ គឺមានតែអ្នកនៅក្នុងទីក្រុងប៉ុណ្ណោះ។ ហើយមធ្យោបាយដើម្បីដោះស្រាយជាមួយអ្នកទាំងនោះគឺមានតែតាមរយៈការបំបែក ការគាបសង្កត់ និងការបង្ក្រាបពួកគេ តាមរយៈការគ្រប់គ្រងដោយការភ័យខ្លាចរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយការប្រព្រឹត្តយ៉ាងអមនុស្សធម៌មកលើជនស៊ីវិល។ នៅក្នុងអំឡុងពេលនៃការជម្លៀសនេះ គឺមិនមានសញ្ញាណណាមួយបញ្ជាក់ថា ការជម្លៀសនេះត្រូវបានរៀបចំឡើងដើម្បីការពារប្រជាជននោះទេ តែផ្ទុយទៅវិញវាជាការដាក់ទណ្ឌកម្មមកលើប្រជាជនតែប៉ុណ្ណោះ។

[១៤:២៤:៣១]

ដើម្បីវាយតម្លៃការអះអាងរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងការគំរាមគំហែងទម្លាក់គ្រាប់បែកនេះ លោក លោកស្រីសួរខ្លួនឯងបានថានូវសំណួរដូចខាងក្រោម៖

ទី១ ប្រសិនបើពួកគេគិតថា ការទម្លាក់គ្រាប់បែកពិតជាមិនអាចគេចរួច ហេតុអ្វីបានជាមេដឹកនាំទាំងនោះមកជួបជុំគ្នាទាំងអស់នៅភ្នំពេញ?

ទី២ ហេតុអ្វីបានជាពួកគេប្រមូលផ្តុំមេដឹកនាំជាន់ខ្ពស់ទាំងអស់របស់បក្ស ឲ្យមកនៅក្រុងភ្នំពេញបើនៅសល់ តែប៉ុន្មានថ្ងៃទៀតនឹងចាប់ផ្តើមជម្លៀសទីក្រុង?

ទី៣ ប្រសិនបើគេនឹងទម្លាក់គ្រាប់បែកតែនៅលើទីក្រុងភ្នំពេញហេតុអ្វីពួកគេចាំបាច់ជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជនដទៃទៀត និងទី៤ ហេតុអ្វីបានជាពួកគេមិនអនុញ្ញាតឲ្យប្រជាជនស្នាក់នៅជិតៗទីក្រុងដើម្បីងាយស្រួលធ្វើដំណើរត្រឡប់ចូលទីក្រុងវិញនៅប៉ុន្មានថ្ងៃក្រោយថ្ងៃ១៧ ខែមេសា? សូមលោក លោកស្រីចៅក្រមពិចារណាលើចំណុចទាំងអស់នេះ។

សូម្បីតែអ្នកដែលត្រូវគេជម្លៀសខ្លះក៏បានទទួលស្គាល់នៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នោះថាថា ការអះអាងថានឹងមានការទម្លាក់គ្រាប់បែកក្នុងរយៈពេលឆាប់ៗនោះ គឺមិនពិតទេ។ លោក ពិន យ៉ាថៃ បានចែករំលែកគំនិតរបស់គាត់ជាមួយលោក លោកស្រីចៅក្រមថា៖ “រឿងអីបានជាអាមេរិកាំងមកទម្លាក់គ្រាប់នៅភ្នំពេញ បើអាមេរិកាំងរត់ចេញពីទីក្រុង និងរត់ចេញពីប្រទេសនេះអស់ហើយ? ពួកអាមេរិកាំងបានចេញតាំងពីដើមខែមេសាម្ល៉េះ ហើយចម្បាំងវាចប់អស់ទៅហើយ រឿងអីមកទម្លាក់គ្រាប់បែកឱ្យងាប់ប្រជាជនទៀត?” តាមពិត ទាំងអស់គ្នាបានដឹងការពិតនៅពេលក្រោយ។ មនុស្សជាច្រើន រួមទាំងកងទ័ពខ្មែរក្រហមផង មានភាពក្លាហានប៊ានជម្រាបការពិតនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ខ្ញុំនឹងយោងទៅលើការយល់ឃើញមួយចំនួនដូចតទៅ៖

លោក ចៅ នី បានលើកឡើងថា៖ ‘ខ្ញុំមិនដែលឮសម្លេងគ្រាប់បែកដែលទម្លាក់ដោយយន្តហោះអាមេរិកកាំងនោះទេ”។ លោក មាស សារ៉ាន់ ក៏បានបញ្ជាក់ដែរថា៖ “មិនមានទម្លាក់គ្រាប់បែកទេ។ ហើយតាមពិតទៅ ខ្ញុំគិតថាពួកគេបានកុហកយើង”។ លោក ជុំ សុខា បានលើកឡើងថា៖ “ពេលយើងទៅដល់ភូមិរបស់យើង យើងបានដឹងថា ផែនការនោះគឺគេមិនមែនជម្លៀសប្រជាជនដោយសាររឿងទម្លាក់គ្រាប់បែកនោះទេ”។ លោក ស៊ុំ ជា “អតីតកងទ័ពខ្មែរក្រហមបានលើកឡើងដែរ៖ “នោះជាផែនការរបស់ពួកគេដើម្បីបញ្ឆោតប្រជាជន ដោយនិយាយថា ឆាប់ៗនេះនឹងមានការបាញ់គ្នា ហើយគ្រប់គ្នាអាចស្លាប់។ ដោយការនិយាយបញ្ឆោតអញ្ចឹង ពួកគេជឿថា ប្រជាជនអាចចេញពីទីក្រុងយ៉ាងលឿន” ។

[១៤:២៧:៥៥]

ឥឡូវនេះ ខ្ញុំនឹងត្រឡប់ទៅពិនិត្យមើលឱ្យកាន់តែលម្អិតទៅលើភស្តុតាងស្តីពីស្ថានភាពអមនុស្សធម៌ដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា។ នៅពេលអ្នកទីក្រុងភ្នំពេញចេញពីផ្ទះរបស់គេភ្លាម និងបានចាកចេញតាមការធ្វើដំណើរដោយបង្ខំទៅកាន់ទីកន្លែងដែលពួកគាត់មិនស្គាល់ ពួកគាត់ក្លាយជាទាសករ និងអ្នកទោសរបស់កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធដែលមានអមដំណើរពួកគាត់។ អ្នកស្រី ពេជ ស្រីផលបាននិយាយថា៖ “បរិយាកាសមានភាពតឹងតែងណាស់ ហើយទាហានខ្មែរក្រហមមិនឱ្យយើងដើរហើរសេរីទេ។ ទាហានខ្មែរក្រហមប្រដាប់ដោយអាវុធបាន អមដំណើរយើងនៅតាមផ្លូវរហូត” ។

ប្រជាជនដែលគេជម្លៀសបានធ្វើដំណើរណែនពាសពេញផ្លូវ។ ប្រជាជនដែលគេជម្លៀសមានទាំងប្រុស ស្រី កុមារ ចាស់ជរា ជនពិការ អ្នកជិះរទេះ និងអ្នកជំងឺ។ ភាគច្រើនធ្វើដំណើរដោយថ្មើរជើងខ្លះអូសរទេះ បណ្តើរកង់ ឬរទេះកង់ដឹកឥវ៉ាន់របស់ខ្លួន ឬដឹកសមាជិកគ្រួសារដែលឈឺ។ អ្នកខ្លះមាន

ខ្លះអូសរទេះបណ្ដើរកង់ ឬរទេះកង់ដឹកអីវ៉ាន់របស់ខ្លួន ឬដឹកសមាជិកគ្រួសារដែលឈឺ។ អ្នកខ្លះមានរថយន្តដែលអស់សាំង ហើយក៏បានទុកចោល ឬត្រូវខ្មែរក្រហមរឹបអូសយក។ ស្ថានភាពដែលបានប្រព្រឹត្តមកលើអ្នកជម្លៀសបណ្ដាលឲ្យមានការឈឺចាប់យ៉ាងខ្លាំង។ ស្ថានភាពនេះ មានដូចជា ការធ្វើដំណើរយឺតៗទៅកណ្ដាលថ្ងៃក្ដៅដែលនាំឲ្យមានការឈឺចាប់ផ្លូវកាយយ៉ាងខ្លាំង នៅក្នុងអំឡុងខែដែលក្ដៅបំផុតប្រចាំឆ្នាំ ដោយគ្មានជំរក គ្មានទឹក គ្មានចំណីអាហារ គ្មានជំនួយថ្នាំសង្កូវអ្វីឡើយ។ ប្រជាជនដែលត្រូវគេជម្លៀសត្រូវបានគេដកហូតសេរីភាព និងប្រឈមមុខទៅនឹងការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញ។ ការធ្វើដំណើរនេះ បានបន្តដល់អស់ជាច្រើនថ្ងៃ ហើយអ្នកដែលគេចម្លៀសជាច្រើនបានធ្វើដំណើរជាច្រើនសប្ដាហ៍។ សេចក្ដីស្លាប់គេមិនអាចរៀបរាប់ដំណើររឿងនៃការឈឺចាប់នេះឲ្យអស់បានលម្អិត ឲ្យបានលម្អិតបានទេ។ ដូច្នេះ អ្វីដែលខ្ញុំរៀបរាប់នេះ គឺជាផ្នែកតូចមួយនៃទិដ្ឋភាពជាច្រើននៃភាពទុរគត និងសេចក្ដីស្លាប់។ ខណៈដែលមនុស្សម្នាក់ក្នុងចំណោមជនភៀសខ្លួនរាប់លាននាក់ទទួលរងឈឺចាប់ អ្នកដែលទទួលរងការឈឺឆាប់បំផុតនោះ គឺអ្នកជំងឺ អ្នករបួស ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ និងកូនក្មេង។

[១៤:៣១:០១]

សក្ខីកម្មរបស់អ្នកស្រី ឆេង អេងលី បានលើកឡើងពីការប៉ះពាល់គួរឲ្យរន្ធត់នៃការបញ្ជាឲ្យមានការជម្លៀសមនុស្សចាស់ថា៖ "មនុស្សចាស់ជរាភាគច្រើនបំផុត ព្រមទាំងម្ដាយរបស់ខ្ញុំមិនត្រូវបានលើកលែងឡើយ។ ពួកគាត់មានការរន្ធត់យ៉ាងខ្លាំង។ ពួកគាត់គ្មានជម្រើសអ្វីក្រៅពីការចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ដោយសារពួកគាត់ត្រូវបានគេភ្ជង់នឹងកាំភ្លើងបង្ខំឲ្យចាកចេញ"។ លោក ហ្វ្រង់ស្វ័រ ប៉ុងស្ង៉ដែលបានឃើញអ្នករបួស និងអ្នកឈឺនៅលើមហាវិថីព្រះមុនីវង្ស និងដែលត្រូវបានគេបង្ខំឲ្យចាកចេញពីទីក្រុងនៅរដូវក្ដៅហែង បានផ្ដល់សក្ខីកម្មអំពីផលវិបាក និងអាចកើតមាននៅខាងមុខថា "មិនយូរមិនឆាប់ពួកគេនឹងស្លាប់។ នោះគឺផលដែលនឹងកើតមានជាយថាហេតុ។ អ្នកដែលមិនអាចធ្វើដំណើរបានដោយខ្លួនឯង នឹងគ្មានសាច់ញាតិជួយពួកគេត្រូវបានគេទុកឲ្យស្លាប់"។ លោក ស៊ីដនី ឆេនប៊ើក បានផ្ដល់សក្ខីកម្មថា "អ្នកដែលឈឺខ្លាំងមិនអាចធ្វើដំណើរទាល់តែសោះនោះ ត្រូវបានគេទុកចោលនៅក្នុងមន្ទីរពេទ្យរហូតដាច់បាយ និងស្លាប់"។

[១៤:៣២:៣០]

អ្នកស្រី យឹម សុវណ្ណ បានឃើញអ្នកជំងឺដែលគេបានទុកចោលឲ្យស្លាប់នៅក្នុងមន្ទីរពេទ្យ

បុរីកីឡាដោយផ្ទាល់ភ្នែក។ លោក មាស សារ៉ាន់ ដែលធ្វើជាពេទ្យនៅពេលនោះ បានធ្វើសក្ខីកម្មនៅក្នុងតុលាការថា "បុគ្គលិកពេទ្យត្រូវបានបញ្ជាឲ្យចេញ និងទុកអ្នករបួស និងអ្នកជំងឺរាប់រយនាក់ចោល ក្នុងនោះមានកុមារអាយុ៨ឆ្នាំដែលធ្លាយពោះ និងចេញពោះវៀនមកក្រៅ។ កុមារីនោះបានទាញអាវគាត់ និងសុំអង្វរឲ្យជួយបីយកនាងទៅជាមួយផង ប៉ុន្តែគាត់ត្រូវចាកចេញ ដោយទុកនាង និងអ្នកដទៃទៀតចោល។ គាត់បានមានប្រសាសន៍ថា៖ "និយាយឲ្យត្រង់ទៅ ពេលនោះ ខ្ញុំមិនដាច់ចិត្តទុកអ្នកជំងឺចោលទេ ប៉ុន្តែខ្ញុំមិនដឹងធ្វើម៉េច។ នៅក្នុងចិត្តរបស់ខ្ញុំ ម្យ៉ាងប្រសិនបើខ្ញុំទុកពួកគាត់ចោល ពួកគេច្បាស់ជាស្លាប់។ ម្យ៉ាងទៀត ប្រសិនពួកខ្មែរក្រហមមកជួយពួកគេ ពួកគេនឹងរស់"។ ហើយលោក ស៊ុំ ជា បានអះអាងដូចគ្នានូវអ្វីដែលបានកើតឡើងនៅមន្ទីរពេទ្យកាល់ម៉ែតនាពេលនោះ។ លោក ស៊ីដនី ឆេនបើក ក៏បានឃើញអ្នកជំងឺជាច្រើននៅតាមផ្លូវពីទីក្រុង រួមទាំងអ្នកជំងឺដែលអ្នកត្រូវបានគេរុញនៅលើគ្រែ និងអ្វីៗសព្វបែបយ៉ាងដោយមានតាំងសេរ៉ូមព្យួរនៅលើគ្រែ ហើយពួកគាត់ទាំងអស់គ្នាត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង។ ប៉ុន្តែគាត់បានបន្ថែមថា ខ្ញុំមិនបានឃើញមានវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាណាម្នាក់ផ្តល់ការព្យាបាលនោះឡើយ។ លោក នូវ ហ៊ាន់ បានផ្តល់ការរៀបរាប់យ៉ាងច្បាស់លាស់អំពីការឈឺចាប់ និងការស្លាប់ ដែលឡោមព័ទ្ធប្រជាជនដែលគេជម្លៀសចេញដូចតទៅ៖

[១៤:៣៤:៣៦]

"មនុស្សច្រើនកុះករធ្វើដំណើរតាមផ្លូវ។ នៅតាមចំកណ្តាលផ្លូវរដូវប្រាំង -- នៅចំកណ្តាលរដូវប្រាំង ហើយអាកាសធាតុក្តៅខ្លាំងណាស់ បងប្អូនដែលគេជម្លៀសចេញភ័យតក់ស្លុតខ្លាំង។ ពួកគាត់មិនបានយកអីវ៉ាន់ទៅជាមួយខ្លួនច្រើនទេ។ ពួកគាត់ខ្លះមិនមានស្បែកជើងសង្រែក ឬស្បែកជើងឃ្លុបពាក់ទេ។ ដូច្នេះ ពួកគាត់បានយកស្រទបចេកទៅចងនឹងបាតជើង។ អ្នកខ្លះបាត់កូន និងក្រុមគ្រួសារ ហើយស្ថានភាពនេះមានលក្ខណៈច្របូកច្របល់ខ្លាំងណាស់។ យើងមិនដឹងទៅរកស្បៀងនៅទីណាទេ ហើយមានសត្វរុយដូចហ្វូងឃ្មុំ រុយសម្បូរនៅគ្រប់ទីកន្លែង។ មានអ្នកខ្លះស្លាប់ ហើយគេទុកចោលនៅតាមផ្លូវ ហើយអ្នកដែលឈឺមិនអាចរកអ្នកណាម្នាក់ឲ្យជួយបានទេ ហើយអង្គការចេះតែបង្ខំបណ្តេញឲ្យយើងទៅមុខ ដូច្នេះអ្នកខ្លះបានបោះបង់ចោលសមាជិកគ្រួសារដែលឈឺ។ លោក ចៅ នី បានផ្តល់សក្ខីកម្មថា "មានអ្នកឈឺដួល និងអង្គុយនៅតាមដងផ្លូវ មានមនុស្សស្លាប់ និងគ្មានអ្នកណាអាចជួយអ្នកណាបានទេ"។ លោក ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ បានផ្តល់សក្ខីកម្មថា៖ "គាត់បានឃើញជនពិការកំពុងវារដូចជន្លេន"។

[១៤:៣៦:០៩]

អ្នកស្រី ម៉ុម សំអឿន បានឃើញអ្នកជំងឺកំពុងខំប្រឹងដើរទៅតាមផ្លូវ ដោយមានព្យួរសេរ៉ូម។ អ្នកស្រី បេ សុផានី បានឃើញអ្នកជំងឺកំពុងតែបញ្ចូលអុកស៊ីសែន។ អ្នកស្រី ឡាយ បូនី បានឃើញស្ត្រីកំពុងតែសម្រាលកូន និងអ្នកស្រី ម៉ុម សំអឿន បានឃើញស្ត្រីកំពុងតែរលូតកូននៅនៅតាមដងផ្លូវ។ អ្នកស្រី សេង ស៊ីវុត្ថា ដែលកាលណោះមានអាយុ ៩ឆ្នាំបានផ្តល់សក្ខីកម្មថា អ្នកស្រីមិនអាចទប់ទឹកភ្នែកបាននៅពេលសម្រេចដើរកាត់សាកសព និងនៅពេលឃើញភាពកំសត់របស់បុរសម្នាក់ដែលជិតដាច់ខ្យល់នៅលើផ្លូវកំពុងស្រែកយំ ដោយសារសត្វស្រមោចកំពុងតែវារពេញលើខ្លួនប្រាណគាត់។ លោក ពិន យ៉ាថៃ បានឃើញស្ត្រីពីរនាក់ចងកសម្លាប់ខ្លួននៅកន្លែងពីរផ្សេងគ្នា។ អ្នកស្រី ពេជ្រ ស្រីផល ដែលទើបនឹងផ្តល់កំណើតឲ្យទារកបានរៀបរាប់អំពីការឈឺចាប់របស់គាត់ នៅពេលឃើញទារករបស់គាត់ស្លាប់ដោយការស្រេកឃ្លានដូចតទៅ៖ “ខ្ញុំគ្មានទឹកដោះដើម្បីបំបៅកូនរបស់ខ្ញុំទេ ខ្ញុំគ្មានថ្នាំសង្កូវ ហើយក៏គ្មានទឹកដោះគោ។ កូនរបស់ខ្ញុំបានស្លាប់នៅពេលកំពុងតែជម្លៀស ហើយខ្ញុំមិនដឹងថា ត្រូវធ្វើយ៉ាងម៉េចជាមួយសពកូនខ្ញុំទេ។ គេណែនាំឲ្យខ្ញុំយកកូនទៅកប់នៅក្នុងព្រៃ។ វាដូចជាសត្វធាតុអ៊ីចឹង”។ អ្នកស្រីបានរៀបរាប់បន្ថែមអំពីទាហានខ្មែរក្រហមដែលខ្វះការគោរពចំពោះអាយុជីវិតមនុស្សថា៖ “នៅតាមផ្លូវ នៅពេលដែលប្រជាជនព្យាយាមត្រឡប់មកភ្នំពេញ ដើម្បីប្រមូលអីវ៉ាន់ និងរបស់របរពួកគាត់ ខ្មែរក្រហមបានបញ្ឈប់ពួកគាត់ ហើយនៅតាមផ្លូវនេះដែរ នៅពេលសមាជិកគ្រួសារណាម្នាក់ធ្លាក់ខ្លួនឈឺ ហើយចង់ទៅមើលថែអ្នកជំងឺនោះ ទាហានខ្មែរក្រហមបានបង្ខំ និងគំរាមកំហែងពួកគាត់ ហើយពួកគេក៏បានបាញ់ឡើងលើដើម្បីគំរាមកំហែងពួកគាត់ឲ្យចាកចេញ”។ អ្នកស្រី ម៉ុម សំអឿន បានរៀបរាប់បន្ថែមទៀតពីការធ្វើទុក្ខបុកម្នេញដែលទាហានខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនស៊ីវិលថា៖ “ទាហានខ្មែរក្រហមនៅតែបន្តគំរាមកំហែងប្រជាជនឲ្យធ្វើដំណើរឲ្យលឿន ហើយពួកគេតែងតែភ្ជង់កាំភ្លើងដាក់យើង។ ខ្ញុំបានឃើញសាកសព ឃើញស្ត្រីមានផ្ទៃពោះ ដែលជួបការលំបាកទាហានខ្មែរក្រហមបានតាមដានយើងយ៉ាងតឹងរ៉ឹង។

[១៤:៣៩:២៨]

លោក គឹម វ៉ាន់ឌី កាលណោះមានអាយុ១២ឆ្នាំ គាត់ត្រូវគេជម្លៀសដែរ បានធ្វើដំណើរចាកចេញពីភ្នំពេញឆ្ពោះទៅកាន់ស្ពានជ្រោយចង្វា គាត់បានឃើញបុរសម្នាក់ ដែលបានបែកពីកូនៗរបស់គាត់ក៏បានផ្តល់សក្ខីកម្មថា៖ “ខ្ញុំបានឃើញមនុស្សប្រុសម្នាក់ គាត់ស្រែកថា គាត់បាត់កូនៗគាត់ និងនៅពេលនៅពេលគាត់ជួបទាហានខ្មែរក្រហមម្នាក់ដែលកំពុងឈរ គាត់សូមវិលត្រឡប់ទៅរកកូនៗគាត់

វិញ។ ប៉ុន្តែទាហានខ្មែរក្រហមរូបនោះ បានស្រែកគំហកដាក់គាត់ ឲ្យបន្តដំណើរទៅមុខទៀត ហាមបកក្រោយ បើមិនដូច្នេះទេ គេនឹងសម្លាប់គាត់ចោល។ ទាហាននោះប្រើពាក្យ "សម្លាប់ចោល"។ ក្រោយមកបុរសនោះបានលុតជង្គង់អង្វរទាហានខ្មែរក្រហម ប៉ុន្តែទាហានខ្មែរក្រហមនោះបានយកកាំភ្លើងវាយគាត់ពីក្រោយ ធ្វើឲ្យគាត់ដួលផ្កាប់មុខនឹងដី។ នៅពេលមនុស្សច្រើន ធ្វើដំណើរណែនតាន់តាប់តាមផ្លូវ ការបែកគ្នាពីក្រុម គ្រួសារកើតមានឡើងជាញឹកញាប់។ មានមនុស្សច្រើនណាស់ ដែលមិនដឹងគោលដៅធ្វើដំណើរច្បាស់លាស់។ ពួកគេមិនដឹងថា តើពួកគេត្រូវធ្វើដំណើរយូរប៉ុនណា។ ស្ថានភាពបែបនេះរឹតតែធ្វើឲ្យពួកគេកាន់តែភ័យ។ អ្នកស្រី ដេនីស អាហ្វុងសូ បានជម្រាបជូនលោក លោកស្រីចៅក្រមរួចហើយថា៖ "ពួកយើងមិនដឹងត្រូវទៅខាងណាឲ្យច្បាស់ទេ"។ ប្រការនេះរឹតតែធ្វើឲ្យស្ថានភាពកាន់តែយ៉ាប់យ៉ឺន។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលជាអ្នកបានរៀនសូត្រចេះដឹងខ្ពង់ខ្ពស់ និងជាមនុស្សដែលមានគំនិតវែងឆ្ងាយ សុទ្ធតែដឹងថាការជម្លៀសប្រជាជនដែលមានទ្រង់ទ្រាយធំបែបនេះ គឺជៀសមិនផុតពីធ្វើឲ្យប្រជាជនរងទុក្ខវេទនាយ៉ាងក្រៃលែង និងបណ្តាលឲ្យមនុស្សស្លាប់ដោយរង្គាលនោះទេ។ ប៉ុណ្ណឹងហើយពួកគេនៅតែមិនផ្តល់ការឧបត្ថម្ភ និងជំនួយអ្វីដល់ប្រជាជនដែលត្រូវជម្លៀស កុំថាឡើយអ្នកឈឺដែលមើលឃើញផ្ទាល់នឹងភ្នែក ឬអ្នកដែលកំពុងខំប្រឹងប្រវេប្រវាទាំងត្រដរ។

[១៤:៤២:១៧]

លោក ស៊ុំ ជា អតីតទាហានខ្មែរក្រហម ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខ លោក-លោកស្រីចៅក្រម បាននិយាយថា ពួកទាហានខ្មែរក្រហមមិនដឹងត្រូវបញ្ជូនប្រជាជនជម្លៀសដោយរបៀបណាទៅទីណា ឬពេលណាទើបអ្នកទាំងនោះទទួលបានម្ហូបអាហារ និងទឹកបរិភោគនោះឡើយ។ គាត់បាននិយាយថា៖ "ម្នាក់ៗត្រូវប្រឹងដោះស្រាយតាមមធ្យោបាយរៀងៗខ្លួន។ គ្មានគោលនយោបាយផ្តល់ជំនួយអ្វីដល់អ្នកទាំងនោះទេ"។

អ្នកជំនាញបានយល់ស្របតាមអង្គហេតុនេះ។ លោក ដេវីដ ឆេនដ៍ល័រ បានពិពណ៌នាអំពីស្ថានភាពនៃការជម្លៀសដោយបង្ខំនេះថា៖ "មានលក្ខណៈកាចសាហាវជាទូទៅ ចាប់តាំងពីចាប់ផ្តើមដំបូងម្ល៉េះ"។ លោក ហ្វីលីព ស្ហូត បានរៀបរាប់អំពីចំណុចនេះលម្អិតបន្ថែម ដែលធ្វើសក្ខីកម្មនៅចំពោះមុខ លោក-លោកស្រីចៅក្រម។ គាត់បាននិយាយថា៖ ក្នុងកាលៈទេសៈដែលមិនចម្លែកដូចក្នុងករណីនេះ ការជម្លៀសប្រជាជនដូច្នេះ តម្រូវឲ្យមានការត្រៀមរៀបចំល្អិតល្អន់បំផុត។ គេត្រូវបង្កើតឲ្យមានជាស្នាក់ការសុខាភិបាល ឬយ៉ាងហោចណាស់ក៏ត្រូវផ្តល់ត្រឹមជំនួយផ្នែកសុខាភិបាលជាបន្តបន្ទាប់នោះដែរ។

ម្យ៉ាងទៀត គេត្រូវរៀបចំឲ្យមានជាសេវាដឹកជញ្ជូន។ គេត្រូវផ្គត់ផ្គង់ម្ហូបអាហារជាបន្តបន្ទាប់។ ប៉ុន្តែសេវាទាំងអស់នេះ អត់មានទាល់តែសោះ។

[១៤:៤៤:០៥]

**ប្រធានអង្គជំនុំ៖**

បាទ សូម ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

ខ្ញុំសូមអនុញ្ញាតបន្តទៀត។

ទោះបីជាប្រជាជនត្រូវរងទុក្ខវេទនាទូទាំងប្រទេសបែបនេះក្តី ក៏មេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជានៅតែប្រកែកមិនទទួលយកជំនួយពីអន្តរជាតិគ្រប់បែបយ៉ាង និងបានរារាំងមិនឲ្យអង្គការកាកបាទក្រហមចែកចាយជំនួយដល់ប្រជាជនជម្លៀសថែមទៀតផង។ លោក អៀង ផាន អតីតកម្មាភិបាលម្នាក់ បានផ្តល់សក្ខីកម្មក្នុងអង្គជំនុំជម្រះថា៖ “នៅពេលនោះ គេប្រើពាក្យមួយឃ្លាថា ខ្លួនត្រូវតែទីពឹងខ្លួន”។

នៅក្នុងស្ថានភាពនៃទីក្រុងភ្នំពេញ លោក ហ្វែនិន សេល័រ (*Fernand Scheller*) តំណាងអង្គការសហប្រជាជាតិ បានស្នើផ្តល់ជំនួយមនុស្សធម៌ជាក់ស្តែងដល់ពួកខ្មែរក្រហម។ គាត់បាននិយាយប្រាប់លោក ស៊ីដនី ឆេនបើក អំពីរបៀបដែលពួកខ្មែរក្រហមឆ្លើយតបយ៉ាងប្រញាប់ប្រញាល់ និង ប្រកែកមិនព្រមទទួលជំនួយនេះ។ គាត់និយាយថា៖ “ពួកទាំងនេះមិនខុសអ្វីពីមនុស្សមកពីភពផ្សេងនោះឡើយ។ ខ្ញុំប្រាប់ពួកគេថាខ្ញុំត្រៀមចាំជួយលោកជានិច្ច ប្រសិនបើលោកត្រូវការជំនួយ។ ខ្ញុំប្រាប់ថាខ្ញុំមានអ្នកជំនាញ

៤២នាក់ នៅទីក្រុងបាងកក កំពុងរង់ចាំធ្វើដំណើរត្រលប់មកវិញដើម្បីជួយ។ ពួកគេអស់សំណើច។

លោក ឆេនបើក ក៏បានកត់ត្រាផងដែរនៅក្នុងកូនសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់គាត់អំពីកិច្ចសន្ទនាមួយជាមួយលោក មួរ៉េ ខាម៉ាយឃើល គ្រូពេទ្យវះកាត់របស់កាកបាទក្រហម ដែលមិនអាចទប់កំហឹងរបស់គាត់នៅពេលបានឃើញផ្ទាល់ភ្នែកនូវភាពឃោរឃៅអមនុស្សធម៌ដែលកំពុងតែកើតមានឡើង “ពួកវាគ្មានចិត្តមនុស្សធម៌ក្នុងខួរក្បាលបន្តិចណាទេ”។ លោក មួរ៉េ ខាម៉ាយឃើល វេជ្ជបណ្ឌិតម្នាក់ក្នុងក្រុមវេជ្ជបណ្ឌិតវះកាត់របស់កាកបាទក្រហម បានពិពណ៌នាពីការបណ្ដេញអ្នកជំងឺចេញពីមន្ទីរពេទ្យ។ លោកបន្តទៀតថា៖ “ពួកវាបណ្ដេញទាំងអស់គ្នាឱ្យចេញ សូម្បីតែអ្នកឈឺ ដើរមិនរួច អ្នកជំងឺធ្ងន់ និងអ្នកកំពុងបញ្ចូលឈាម។ អ្នកជំងឺជាច្រើនប្រាកដជាស្លាប់។ ស្ថានភាពពិតជាគួរឱ្យសោកសង្វេគខ្លាំងណាស់” ពួកទាហានបះបោរទាំងនេះបានបង្ខំ ខាម៉ាយឃើល ឱ្យបោះបង់ចោលអ្នកជំងឺម្នាក់ដែលកំពុងទទួលការវះកាត់នៅសាលវះកាត់កាកបាទក្រហមក្នុងសណ្ឋាគារឡឺភ្នំ។

[១៥:០៥:៥១]

នៅក្នុងស្ថានភាពទាំងនេះ ការព្រងើយកន្ដើយមិនអើពើនឹងការឈឺចាប់ គឺគ្មានអ្វីក្រៅតែពីការធ្វើបាបប្រជាជនដោយចេតនានោះទេ។ នៅក្នុងកាលៈទេសៈបែបនេះ ការស្លាប់របស់ប្រជាជនរាប់ពាន់នាក់មិនត្រឹមតែអាចប្រមើលមើលដឹងមុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនអាចជៀសផុតទៀត។ ហើយដូចដែលខ្ញុំបានលើកឡើងខាងលើ វិនាសកម្មទាំងនេះ គឺបណ្ដាលមកពីសេចក្ដីសម្រេចរបស់មជ្ឈិមបក្ស ឱ្យជម្លៀសប្រជាជនចេញពីទីក្រុង។ លើសពីនេះទៀត ខៀវ សំផន បានវាយតម្លៃខ្ពស់ និងកោតសរសើរកងកម្លាំងទទួលជ័យជម្នះនោះថា ជាអ្នករំដោះប្រជាជន នៅក្នុងសុន្ទរកថាជ័យជម្នះរបស់គាត់ ដែលផ្សាយតាមរលកធាតុអាកាសនៅព្រឹកព្រហាមថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងពាក្យសម្ដីរបស់គាត់ថា “ខ្មាំងត្រដរខ្យល់ស្លាប់”។

ខ្ញុំបានលើកឡើងនូវភស្តុតាងមួយចំនួនរួចហើយ នៅចំពោះមុខលោក លោកស្រីចៅក្រម ដែលបង្ហាញយ៉ាងច្បាស់ពីការស្លាប់របស់ប្រជាជនក្នុងចំនួនយ៉ាងច្រើន ដែលបណ្ដាលមកពីស្ថានភាពជីវិតដ៏សែនលំបាក ដែលប្រជាជនជម្លៀសត្រូវស៊ូទ្រាំ។ ពេលនេះ ខ្ញុំនឹងលើកភស្តុតាងពីការស្លាប់ទាំងនោះឱ្យកាន់តែលម្អិតបន្ថែមទៀត។

[១៥:០៧:៣៩]

គ្រាន់តែការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញតែមួយ បានបណ្ដាលឱ្យប្រជាជន

ស្ងួតត្រង់សរុបប្រមាណ ២០.០០០នាក់ស្លាប់បាត់បង់ជីវិត។ ក្នុងការស្រាវជ្រាវផ្ទាល់ជាក់ស្ដែងរបស់លោក ប៉ែន យៀរនិន គាត់បានសន្និដ្ឋានថា ប្រជាជនជាង ១០.៦០០នាក់ ទំនងជាត្រូវបានស្លាប់ តាមផ្លូវពីភ្នំពេញទៅកាន់គោលដៅជម្លៀសដំបូងរបស់ពួកគេ។ គាត់បានប៉ាន់ប្រមាណថា ប្រជាជន ១០.០០០នាក់ផ្សេងទៀតបានស្លាប់ក្នុងអំឡុងពេលជម្លៀស។

លោក លោកស្រីចៅក្រម បានស្ដាប់រួចមកហើយនូវភស្តុតាងពីការកាប់សម្លាប់ជាច្រើនករណីរាប់មិនអស់ដោយក្រុមទាហានខ្មែរក្រហម។ ប្រជាជនត្រូវបានសម្លាប់ដោយសារតែមិនព្រមចាកចោលផ្ទះសម្បែងរបស់ខ្លួន ឬស្វាមីតែចេញមិនទាន់ ឬយកទៅជាមួយនូវរបស់របរផ្ទាល់ខ្លួនច្រើនពេក ឬស្វាមីគ្រាន់តែមិនស្ដាប់បញ្ជារបស់ទាហានខ្មែរក្រហម។ អ្នកស្រី យឹម សុវណ្ណ បានរៀបរាប់ពីព្រឹត្តិការណ៍មួយយ៉ាងដូច្នេះថា៖ "មានស្រី មានប្រុសលីកាំភ្លើង ពាក់អាវខ្មៅ បង់កក្រមាក្រហម មានកាំភ្លើងគ្រប់ដៃគេថាអង្គការលើឲ្យចេញ។ គេទុកពេលជាងជា១៥នាទីទេ បើយើងចេញ ចេញបាន បើយើងមិនចេញគេមានផែនការ។ តែខ្ញុំឃើញនៅផ្សារអូរឫស្សី ខ្ញុំឃើញផ្ទះមួយហ្នឹងបិទទ្វារ ដល់ពេលខ្ញុំត្រឡប់ពីផ្សារវិញ គោះទ្វារអត់បើកៗ ខ្ញុំឃើញបាញ់សោផាំងៗ! អូសចេញមកបាញ់ចោលនៅនឹងមាត់ទ្វារ។ ខ្ញុំរត់ចេញពីទីកន្លែងនោះភ្លាម"។

[១៥:០៩:៥៣]

លោក ពិន យ៉ាថៃ ដែលខ្ញុំបានលើកឡើងខាងលើ ក៏បានបញ្ជាក់ជម្រាបជូន អង្គជំនុំជម្រះបន្ថែមនូវការរៀបរាប់នៅក្នុងសៀវភៅរបស់គាត់ថា៖ "យើងដើរបានប្រហែលជា មួយគីឡូ ខ្ញុំបានឮស្នូរកាំភ្លើងបាញ់។ ដើរទៅបន្តិចទៀតនៅលើផ្លូវឃើញសាកសពក្មេងប្រុសម្នាក់អាយុប្រហែល ១៨ឆ្នាំ ប្រហែល ៥០ម៉ែត្រពីសាកសពក្មេងប្រុសនេះមានទាហានខ្មែរក្រហមម្នាក់ឈរកាន់អាវុធ កា-៤៧ ចុងកាណុងនៅហុយផ្សែងឡើងលើនៅឡើយ។ ប្រហែលមួយនាទីក្រោយមក យើងឮថាក្មេងប្រុសហ្នឹងវាភ្លេចរបស់ស្អីមួយនៅផ្ទះ។ គាត់ត្រឡប់ទៅយកវិញ មិនស្ដាប់ការបញ្ជារបស់ទាហាននោះ ហើយគាត់រៀបនឹងចូលដល់ក្នុងផ្ទះហើយ ទាហាននោះក៏បាញ់សម្លាប់គាត់ទៅ។ ទាហាននោះបានស្រែកប្រកាសថា "អាហ្នឹងហើយរឹងរូស"។ ពួកខ្មែរក្រហមក៏សម្លាប់ផងដែរអ្នកដែលរឹងរូស មិនព្រមឲ្យរបស់របរដែលពួកវាលួចប្លន់ពីប្រជាជនជម្លៀសដែលយកទៅតាមខ្លួន។ អ្នកស្រី ធុច ផាន់ដារា-ស បានរៀបរាប់ហេតុការណ៍នេះនៅក្នុងសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះថា៖ "យើងទៅដល់ យើងឮសំឡេងមួយស្រែកថាឲ្យនាឡិកាមក! ហើយសំឡេងហ្នឹងគឺថាសំឡេងកាចមែនទែន។ ដោយសារខ្លាចបាត់កូន ខ្លាចបាត់បង់

ក្មេងៗ ខ្ញុំភ័យ ហើយបន្ទាប់មក ឃើញមានឮស្នូរកាំភ្លើង ក្រោយមកខ្ញុំឃើញដូចជាមនុស្សម្នាក់ដែលទើបតែស្លាប់ថ្មីៗ"។ ពួកទាហានខ្មែរក្រហមសម្លាប់សូម្បីតែទារកទើបនឹងកើត ដែលយំដោយសារឃ្លានបៅ។ អ្នកស្រី ឆេង អេងលី បានរៀបរាប់ប្រាប់អង្គជំនុំជម្រះនូវអ្វីដែលគាត់បានឃើញផ្ទាល់ភ្នែកថា៖ "ពេលចេញពីភ្នំពេញ ការធ្វើដំណើរពីភ្នំពេញទៅតាមផ្លូវជាតិលេខ១ ឆ្លងស្ពានមុនីវង្ស ខ្ញុំឃើញទារកម្នាក់យំ ហើយវារនៅលើទ្រូងម្ដាយដែលស្លាប់ពីអង្កាល់ ខ្ញុំមិនដឹង។ ខ្ញុំមានចិត្តចង់ទៅលើកព្រោះអាណិតក្មេង ចិត្តចង់ទៅហើយ ប៉ុន្តែរយៈពេលដែលចិត្តចង់ និងពេលខ្ញុំឃើញទាហានទៅលើកក្មេងហ្នឹង វាឃើតពេលពេក។ ខ្ញុំឃើញទាហានម្នាក់លើកក្មេងហ្នឹងឡើង ចាប់ហែកជាពីរហើយបោះ ខ្លោចផ្សាណាស់ គ្មានអាណិតក្មេង។ ខ្ញុំមិនអាចស្រមៃបានទេថា គេហ៊ានធ្វើអំពើបែបនេះ"។

[១៥:១៣:០០]

ការប្រមាថ ការធ្វើបាបអ្នកទីក្រុង និងជីវិតមនុស្សត្រូវបានបំពាក់ក្នុងចិត្តរបស់ទាហានខ្មែរក្រហម។ ទាហានត្រូវបានផ្ដល់សិទ្ធិអំណាច និងអនុញ្ញាតឲ្យសម្លាប់តាមចិត្តរបស់ពួកគេ។ ពីខាងដើម ខ្ញុំបានលើកឡើងពីភស្តុតាងរបស់លោក គង់ គីម អតីតទាហានខ្មែរក្រហមម្នាក់ដែលបានប្រាប់ថាទាហានខ្មែរក្រហមមិនទទួលទោសទណ្ឌទេចំពោះការសម្លាប់ជនស៊ីវិល។ ខាងក្រោមនេះគឺជាការដកស្រង់ច្បាស់មួយទៀតនូវចម្លើយរបស់គាត់ ដែលបានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា៖ "ពេលយើងមកដល់ទីក្រុង ប្រសិនបើយើងចង់បាញ់នរណាចោល យើងអាចបាញ់ចោលភ្លាម... យើងនឹងមិនត្រូវបានគេដាក់ទោសទេ ព្រោះអ្នកទាំងនោះជាខ្មាំង"។ លោក គង់ គីម ក៏បានបង្ហាញប្រាប់នៅចំពោះមុខអង្គជំនុំជម្រះផងដែរអំពីរបៀបដែលកងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជាកំណត់ថា ប្រជាជនណាជាខ្មាំងបន្ទាប់ពីពួកគេត្រូវបានសម្លាប់ ថា៖ "ប្រជាជនសាមញ្ញជាច្រើនក៏ត្រូវបានសម្លាប់ដែរ ពីព្រោះនិយាយរួមទៅយុទ្ធជនដែលមិនខ្វល់ពីជីវិតមនុស្សទាំងនោះ អាចសម្លាប់នរណាក៏បាន តាមតែពួកវាចង់ លើកលែងតែពួកជនរួមអាវុធរបស់ពួកវា ហើយគ្មានអាចដាក់ទោសអីទេចំពោះការសម្លាប់ប្រជាជនសាមញ្ញទាំងនោះ។ ពេលគេបាញ់ចោល គេចោទទម្លាក់ថាជាខ្មាំង។

[១៥:១៥:០៣]

ខ្ញុំក៏បានលើកឡើងផងដែរពីការស្លាប់ជាច្រើនរបស់ប្រជាជន ដែលងាយរងគ្រោះបំផុតនៅក្នុងអំឡុងពេលជម្លៀស។ សាក្សីឃើញផ្ទាល់ភ្នែកជាច្រើនបានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះថា កាណ៍ទាំងនេះសុទ្ធតែវាជាការពិត។ ប្រជាជនដែលងាយរងគ្រោះបំផុត មានទារក កុមារតូច មនុស្សចាស់

ជនពិការ អ្នកជំងឺ ស្ត្រីមានផ្ទៃពោះ ត្រូវបានស្លាប់ដោយអត់អាហារក្នុងអំឡុងពេលជម្លៀស។ លោក ប៉េជុយ ជីបសែ បានឆ្លើយបំភ្លឺថា៖ “ចំពោះអ្នកដែលជម្លៀសមកស្លាប់តាមផ្លូវ គឺដោយសារ ទី១ គឺអត់បាយ។ ទី២ ជួនកាល គាត់មានជំងឺតាមផ្លូវមិនដឹងជាទៅពឹងពីណាទេ គឺត្រូវតែតាមយថាកម្ម គឺត្រូវស្លាប់តាមផ្លូវ។ ក្មេងគ្មានទឹកដោះគោឲ្យផឹកអីទេ គឺមានន័យថាស្លាប់ហ្នឹង គឺវាអណោចអាធ័មណាស់។ ខ្ញុំរៀបរាប់ទៅ វាមិនអាចរៀបរាប់អស់ទេ”។

[១៥:១៦:១៤]

វេជ្ជបណ្ឌិត វ៉ាន់ ហាយ បានរៀបរាប់អ្វីដែលគាត់បានឃើញផ្ទាល់ភ្នែក ពេលគាត់ត្រូវគេជម្លៀសចេញពីភ្នំពេញ។ គាត់បានឃើញសាកសពក្មេងៗ ចម្ងាយពីមួយទៅមួយ ប្រមាណ២០០ម៉ែត្រ។ អ្នកស្រី បេ សុផានី ក៏បានឃើញសាកសពរដូករណែលតាមផ្លូវ សាកសពប្រជាជន សាកសពទាហានលន់នល់ សាកសពមនុស្សចាស់ សាកសពក្មេង និងស្ត្រីមានផ្ទៃពោះ។ លោក ពិន យ៉ាថៃ ដែលខ្ញុំបានលើកឡើងគឺជាការរៀបរាប់គាត់ពីខាងលើ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ៖ “ពេលដើរទៅឆ្ងាយទៅឆ្ងាយទៅពីរាជធានី អ្នកជំងឺ អ្នករបួស អ្នកឈឺជើងដើរលែងរួច និងមនុស្សចាស់កាន់តែដុនដាបខ្លាំងឡើងៗ ចេះតែដើរទៅមុខទៀត យើងចាប់ផ្តើមឃើញសាកសព រដូករណែលតាមផ្លូវ រហូតដល់យើងលែងភ័យរន្ធត់នឹងហេតុការណ៍ទាំងនេះទៀត”។

ប្រជាជនជម្លៀសជាច្រើន ក៏ត្រូវបានគេសម្លាប់បន្ទាប់ពីមកដល់គោលដៅ នៅជនបទ ឬស្លាប់ដោយសារលក្ខខណ្ឌដ៏សែនវេទនានៃការធ្វើដំណើរ រួមផ្សំនឹងស្ថានភាពអមនុស្សធម៌ដែលពួកគេត្រូវទទួលរងបន្ទាប់ពីមកដល់គោលដៅភ្លាម។ លោក អ៊ូន ផល្លី បានផ្តល់សក្ខីកម្មថា ឪពុកមារបស់គាត់ត្រូវបានគេបញ្ជូនឲ្យទៅរៀនក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីគាត់បានមកដល់ ហើយតាំងពីនោះមកគាត់បាត់ខ្លួនរហូត។

[១៥:១៨:១០]

សហព្រះរាជអាជ្ញាសូមសន្និដ្ឋានថា មានអង្គហេតុពិតត្រូវបានរកឃើញហួសពីវិមតិសង្ស័យ។ ការស្លាប់របស់ប្រជាជននៅក្នុងហេតុការណ៍នីមួយៗ សុទ្ធសឹងតែស្តែងចេញពីលទ្ធផលដោយផ្ទាល់ និងមិនអាចជៀសផុតបាននៃសេចក្តីសម្រេចរបស់មជ្ឈិមបក្ស ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង និងស្រាវជ្រាវរែកមុខរក និងកម្ទេចខ្មាំង ក្នុងអំឡុងពេលជម្លៀស និងក្រោយពេលជម្លៀស។ ភស្តុតាងនៃសកម្មភាពទាំងឡាយរបស់ជនជាប់ចោទទាំងពីរនេះ ទាំងនៅមុន និងនៅអំឡុងពេល ព្រមទាំងក្រោយព្រឹត្តិការណ៍នេះ បង្ហាញយ៉ាងច្បាស់ថា ជននេះមានចេតនាចង់ឲ្យប្រជាជនទាំងនេះស្លាប់។ វាក៏បង្ហាញ

យ៉ាងច្បាស់ផងដែរថា ជននេះបានដឹងរួចទៅហើយថា ការស្លាប់របស់ប្រជាជនច្បាស់ជានឹងកើតឡើង។

ឥឡូវនេះខ្ញុំសូមបង្ហាញជូនលោក លោកស្រីចៅក្រម អំពីការជម្លៀសដោយបង្ខំដំណាក់កាលទី២។ នៅអំឡុងពេលនៃការជំនុំជម្រះក្ដីនេះ យើងទាំងអស់គ្នាបានយោងទៅលើការជម្លៀសថាជា "ការជម្លៀសដំណាក់កាលទី១ និងការជម្លៀសដំណាក់កាលទី២"។ ការណ៍នេះអាចឲ្យមានការចាប់អារម្មណ៍ បក្សកុម្មុយនីស្ដកម្ពុជាជម្លៀសប្រជាជនដោយបង្ខំមានតែពីរលើកប៉ុណ្ណោះ។ ប៉ុន្តែតាមការពិតគោលនយោបាយជម្លៀសដោយបង្ខំនេះ គឺជាគោលនយោបាយដែលត្រូវអនុវត្តជាបន្តបន្ទាប់មួយរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយប្រជាជនដែលស្ថិតនៅក្រោមការត្រួតត្រារបស់បក្សកុម្មុយនីស្ដកម្ពុជាត្រូវបានជម្លៀសជាបន្តបន្ទាប់ចាប់តាំងពីដើមទសវត្សរ៍១៩៧០តរៀងមក។ សូម្បីតែនៅក្នុងឆ្នាំ១៩៧៥ ប្រជាជនត្រូវបានជម្លៀសជាបន្តបន្ទាប់នៅប៉ុន្មានខែបន្ទាប់ពីជ័យជម្នះ។ បទឧក្រិដ្ឋជាច្រើនបានកើតឡើងជាបន្តបន្ទាប់នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២។ ប្រជាជនថ្មីមិនត្រឹមតែក្លាយជាជនរងគ្រោះនៃបទឧក្រិដ្ឋប្រព្រឹត្តឡើងដោយមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជានៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ និងក្រោយៗមកទៀតតែប៉ុណ្ណោះនោះទេ ប្រជាជនថ្មីទាំងនោះបានក្លាយជាក្រុមគោលដៅនៃការរើសអើង និងការធ្វើបាបជាប្រព័ន្ធថែមទៀតផង។ ពួកគាត់បានរងទុក្ខវេទនាពីការកេងប្រវ័ញ្ចកម្លាំងពលកម្មតាមរយៈការបង្ខំឲ្យធ្វើការក្នុងស្ថានភាពដ៏អមនុស្សធម៌។ ពួកគាត់បានរងទុក្ខវេទនាដោយសារការដាក់ឲ្យទៅជាទាសករ។ ពួកគាត់ជាច្រើននាក់ត្រូវបានសម្លាប់ចោលតាមវិធីសម្លាប់ក្រៅប្រព័ន្ធតុលាការទូទាំងប្រទេស។ មនុស្សរាប់ពាន់នាក់បានស្លាប់ដោយសារធ្វើការហួសកម្លាំង ដាច់បាយ និងដោយសារជំងឺ។ ពួកគាត់ត្រូវបានបំបែកជាក្រុម ដើម្បីងាយស្រួលគ្រប់គ្រង និងកៀបសង្កត់ និងដាក់ទណ្ឌកម្ម។ ប្រជាជនថ្មីគឺគ្រាន់តែជាធនធានសម្រាប់បម្រើផែនការឧក្រិដ្ឋរបស់ ខៀវ សំផន និង នួន ជា និងបក្ខពួករបស់គេតែប៉ុណ្ណោះ។ ពួកគាត់មិនមែនជាមនុស្សសំខាន់។ ពួកគាត់គឺជាផ្នែកនៃផលិតកម្មដែលត្រូវគេកេងប្រវ័ញ្ចជាប្រព័ន្ធ។

លោកសាស្ត្រាចារ្យ ឆេនល័រ ផ្ដល់សក្ខីកម្មថា៖ "គេមិនបានចាត់ទុកថា ប្រជាជនទាំងនេះមានតម្លៃជាមនុស្សអ្វីទាំងអស់ អ្នកទាំងនេះមិនមែនជាមនុស្សដែលពួកអ្នកឈ្លះគោរពនោះឡើយ។ ប្រជាជនទាំងនេះគឺជាមនុស្សដែលពួកគេមិនជ្រើសរើសឲ្យចូលបម្រើក្នុងជួរបក្សរបស់ពួកគេ"។

[១៥:២២:៣៩]

លោក លោកស្រី ចៅក្រមបានស្ដាប់សក្ខីកម្មពីមនុស្សប្រុសម្នាក់ឈ្មោះលោក ពិន យ៉ាថៃ ដែល

បានសរសេរសៀវភៅមួយក្បាលអំពីបទពិសោធន៍របស់គាត់។ សៀវភៅនេះមានចំណងជើងថា “ជីវិតកូនថ្លៃ កូនត្រូវតែរស់”។ គាត់ជាប្រជាជនថ្មីម្នាក់។ ខ្ញុំនឹងដកស្រង់សក្ខីកម្មរបស់គាត់នៅពេលក្រោយៗមកទៀត។ ត្បិតគាត់ជាសាក្សីសំខាន់មួយរូប។ គាត់ជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំពីសមរភូមិលារ ទៅចូលព្រៃនៅ វាលវង់ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥។ គាត់បានពិពណ៌នាថា អំពីការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២នេះថា “ជាដំណាក់កាលបន្ថែមមួយទៀតក្នុងការបំផ្លិចបំផ្លាញប្រជាជនថ្មី”។

ដូច្នេះ មជ្ឈិមបក្សរួមទាំង នួន ជា និង ខៀវ សំផន បានកំណត់យកការធ្វើបាបជាប្រព័ន្ធដែលមានអង្គការចាត់តាំងមួយ។ សេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនថ្មីជាលើកទី២ ពុំមានមូលហេតុត្រឹមត្រូវទាំងផ្នែកមនុស្សធម៌ ឬសេដ្ឋកិច្ចនោះឡើយ។ ការជម្លៀសដំណាក់កាលទី២ ត្រូវបានធ្វើឡើងក្នុងចេតនាប្រព្រឹត្តបទឧក្រិដ្ឋបន្ថែមលើបទឧក្រិដ្ឋដែលមានតាំងពីមុនមកស្រាប់។ ការធ្វើដូច្នេះគឺពុំបានបញ្ចប់ទុក្ខវេទនារបស់ប្រជាជននោះទេ ប៉ុន្តែវាកាន់តែធ្វើឲ្យការឈឺចាប់នេះមានសភាពខ្លាំងក្លា និងធំជាងមុន។ ការប្រព្រឹត្តបទឧក្រិដ្ឋនេះមានទ្រង់ទ្រាយធំ។ ដើម្បីអនុវត្តមាគ៌ារបស់បក្ស ក្នុងការផលិតស្រូវឲ្យបានចាប់ពីបីតោនក្នុងមួយហិកតា មជ្ឈិមបក្សមិនអល់អែក និងប្ដេជ្ញាក្នុងការសម្រេចឲ្យបានតាមផែនការទោះជាត្រូវចំណាយអ្វីក៏ដោយ។

[១៥:២៤:៥២]

ខៀវ សំផន និង នួន ជា និងសមាជិកមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាបានចេញបញ្ជេញបញ្ជាឲ្យបុគ្គលិកថ្នាក់ទាបរបស់ខ្លួនអនុវត្តផែនការ “កសាងប្រទេស” នេះឲ្យបានសម្រេច ទោះជាត្រូវចំណាយអ្វីក៏ដោយ។ ផែនការនេះត្រូវអនុវត្តរួមគ្នាជាមួយនឹងផែនការ“ការពារប្រទេស”។ បក្សកុម្មុយនីស្តកម្ពុជាពូកែខាងរៀបភាសារបស់ពួកគេ ដើម្បីបំភ័ន្តកុំឲ្យគេដឹងអំពីចេតនា និង គោលបំណងពិតរបស់ខ្លួន។ ការកសាងប្រទេសមិនមែនបានន័យថា ជាការបង្កើតឲ្យមានការងារធ្វើដោយស្ម័គ្រចិត្ត និងមានប្រាក់បៀវត្សរ៍ ការលើកស្ទួយជីវិតរស់នៅ ការទាក់ទាញការវិនិយោគ និងការស្វែងរកទីផ្សារលក់ផលិតផលក្នុងតំបន់នោះទេ។ ការកសាងប្រទេសនេះ ក៏មិនមែនជាការពង្រឹងសាមគ្គីភាពនៅក្នុងសង្គមសហគមន៍ល្អ ឬការធ្វើឲ្យប្រសើរឡើងដល់ជីវភាពផ្នែកសម្ភារៈ និងស្មារតីរបស់ជាតិនោះដែរ។ ការសាងប្រទេស មានន័យថាជាការបន្តការដាក់ឲ្យទៅជាទាសករ ការធ្វើពលកម្មដោយបង្ខំ និងការសម្លាប់មនុស្ស។ មជ្ឈិមបក្សចាត់ទុកការឈានចូលដំណាក់កាល“បដិវត្តន៍សង្គមនិយម” ថាជាដំណាក់កាលនៃការអនុវត្តកម្មវិធីធ្វើឲ្យមនុស្សមានភាពស្មើគ្នាមួយ ក្នុងគោលបំណងកាត់បន្ថយសេចក្ដីរងទុក្ខវេទនា។

ក្រុមមេធាវីការពារក្តី ខៀវ សំផន អះអាងថា ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២ គឺជាកម្មវិធីសេដ្ឋកិច្ចមួយ ដើម្បីគ្រប់គ្រងវិបត្តិស្បៀងអាហារ។ ប៉ុន្តែ ការពិតមិនមែនដូច្នេះនោះទេ។

[១៥:២៦:៥២]

ដូចគ្នានឹង "បដិវត្តន៍ប្រជាធិបតេយ្យថ្មី"ដែរ អ្វីដែលមជ្ឈិមបក្សចង់បានតាំងពីមុនមកពេលឡើងកាន់អំណាច គឺមិនមែនចង់បានលទ្ធិប្រជាធិបតេយ្យនោះទេ។ មជ្ឈិមបក្សចង់បានការបង្ខិតបង្ខំ ការគ្រប់គ្រង និងការសម្លាប់មនុស្ស។ យើងត្រូវមើលអំពីតថភាពជាក់ស្តែងនៃអ្វីដែលបានកើតឡើងមកលើជនរងគ្រោះ មិនមែនមើលតែការឃោសនានយោបាយ ដែលមជ្ឈិមបក្សប្រើដើម្បីគ្រាន់តែបិទបាំងបេសកម្មពិតរបស់ខ្លួនតែប៉ុណ្ណោះនោះទេ។ ដូចគ្នានេះដែរ ផែនការ"ការពារប្រទេស" របស់មជ្ឈិមបក្សបានក្លាយទៅជាមូលហេតុរួមមួយសម្រាប់ប្រហារជីវិតជនរងគ្រោះស្លូតត្រង់រាប់ពាន់នាក់ ដែលត្រូវបានសម្លាប់ចោល ដោយសារត្រូវគេចោទថាជាខ្សែអ្នកនេះអ្នកនោះ។

ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២ ត្រូវបានធ្វើឡើងក្រោយពីមានកិច្ចប្រជុំជាច្រើន។ មាគ៌ារបស់បក្សក្នុងការកសាងប្រទេសបានក្លាយជាចំណុចអាទិភាពមួយបន្ទាប់ពីខ្លួនដណ្តើមបានអំណាច។ នៅក្នុងកិច្ចប្រជុំទាំងនេះ មជ្ឈិមបក្សបានពន្យល់អំពីគោលនយោបាយនេះ និងបានចេញបញ្ជាឲ្យគោរព និងអនុវត្តនៅទូទាំងប្រទេស។ ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២ ចាប់ផ្តើមភ្លាមនៅបន្ទាប់ពីមានគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះទៅធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យ ក្នុងខែសីហា ឆ្នាំ១៩៧៥។ ឯកសារបក្សកុម្មុយនីស្តកម្ពុជា ជាដំបូងពិភាក្សាអំពីការប្រមូលទិន្នផលស្រូវទៅតាមផែនការកំណត់ ហើយថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាបានចេញបញ្ជាឲ្យចាប់ផ្តើមជម្លៀសប្រជាជន។

[១៥:២៩:០៣]

គោលបំណងនៃការបង្កើនទិន្នផលស្រូវឲ្យបានលឿនបំផុត មិនមែនជារបៀបវារៈតូចតាចនៅក្នុងកិច្ចប្រជុំនោះទេ។ ផែនការនេះ និង ផែនការសម្លាប់ខ្មាំង គឺជាគោលដៅអាទិភាពមួយរបស់ពួកគេ។ កិច្ចប្រជុំទាំងនេះនិងការចុះទៅធ្វើទស្សនកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មានសារៈសំខាន់ដោយសារវាបង្ហាញអំពីរបៀបដែលថ្នាក់ដឹកនាំបក្សរៀបចំ សម្រេច និងអនុវត្តផែនការឧក្រិដ្ឋរបស់ពួកគេ។ វាបង្ហាញឲ្យឃើញថា ជនជាប់ចោទសុទ្ធតែជាអ្នកចូលរួមយ៉ាងសកម្ម និងបានដឹងអំពីអ្វីដែលបានកើតឡើង។

ក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើងថា៖ "នួន ជា នៅតែរក្សាជំហររបស់គាត់ថា សេចក្តីសម្រេចក្នុងការអនុវត្តផែនការជម្លៀសប្រជាជនដំណាក់កាលទី២ គឺត្រូវបានធ្វើឡើងដោយមេ

ភូមិភាគ មិនមែនធ្វើឡើងដោយមជ្ឈិមបក្សនោះទេ"។ ជាដំបូងនេះ គ្រាន់តែជាការអះអាងមួយប៉ុណ្ណោះ។ ការអះអាងបែបនេះ ពុំមានភស្តុតាងគាំទ្រពិតប្រាកដពី នួន ជា នោះទេ។ គាត់អាចបន្តធ្វើសក្ខីកម្ម និងពន្យល់អំពីជំហររបស់គាត់ទៀតបាន ប៉ុន្តែគាត់សម្រេចមិនធ្វើ។ យើងខ្ញុំសូមស្នើឲ្យ លោក លោកស្រីចៅក្រម ពិចារណាលើភស្តុតាងនៃការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី២ និងសូមឲ្យពិចារណាលើការអះអាងដែលគ្មានភស្តុតាងគាំទ្រ ដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយនេះ។

[១៥:៣០:៥៤]

នៅពេលដែលលោក លោកស្រីចៅក្រមវាយតម្លៃលើភស្តុតាង និងត្រូវបានអនុវត្តដោយមជ្ឈិមបក្ស តាមរយៈឋានានុក្រមនៃអំណាចប្រមូលផ្តុំដ៏តឹងរ៉ឹង និងមានក្រឹត្យក្រមមួយ មិនមែនធ្វើអ្វីស្រេចតែនឹងចិត្តទៅតាមចរិតរបស់លេខាភូមិភាគម្នាក់ៗនោះឡើយ។

នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបានជួបប្រជុំគ្នា ១០ថ្ងៃ នៅវិហារព្រះកែវមរកត ដើម្បីពិភាក្សាអំពី "ស្ថានការណ៍នៅក្រោយពេលរំដោះ" និងធ្វើផែនការដើម្បីសម្រេចគោលដៅ "បដិវត្តន៍សង្គមនិយម" ដែលជាគោលដៅបន្ទាប់របស់បក្ស។ ប៉ុល ពត និង នួន ជា ធ្វើជាអធិបតីក្នុងកិច្ចប្រជុំនេះ។ ប៉ុល ពត បង្ហាញឯកសាររបស់បក្ស និង នួន ជា ដឹកនាំកិច្ចពិភាក្សា។ ខៀវ សំផន និង អៀង សារី បានចូលរួមក្នុងកិច្ចប្រជុំ ដែលមានអ្នកចូលរួមពីភូមិភាគ។ គណៈកម្មាធិការមជ្ឈិមបានពិភាក្សាគ្នាអំពីការជម្លៀសទីក្រុងភ្នំពេញ ការកសាង និងការពារប្រទេស ការកសាងសហករណ៍ចម្រើន និងការពន្លឿនដំណើរការសាងសង់ទំនប់ និងប្រឡាយ។ ខៀវ សំផន បានផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះក្តីនេះថា របៀបវារៈនៅក្នុងកិច្ចប្រជុំនៅខែ ឧសភា ឆ្នាំ១៩៧៥ គឺពាក់ព័ន្ធនឹងការកសាងប្រទេសជាបន្ទាន់តាមរយៈបដិវត្តន៍សង្គមនិយម និងការស្តារឡើងវិញ ដែលមានន័យថាដីធ្លីទាំងអស់នឹងត្រូវដាក់ឲ្យសហករណ៍គ្រប់គ្រង។ គណៈកម្មាធិការមជ្ឈិមបានសម្រេចថា "យើងត្រូវកសាងប្រទេស និងត្រូវកសាងសង្គមនិយម ឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន"។ នេះមិនមែនជាការកសាងកសិកម្មដែលឈរលើមូលដ្ឋាននៃសេរីភាព និងសិទ្ធិក្នុងការជ្រើសរើសនោះទេ។ វាមិនមែនជាការរៀបចំកម្លាំងពលកម្ម ដែលពោរពេញទៅដោយឆន្ទៈ និងថាមពល មានហូបគ្រប់គ្រាន់ និងមានការយកចិត្តទុកដាក់ត្រឹមត្រូវ ដើម្បីផ្លាស់ប្តូរសង្គមមួយនោះទេ។ វាជាផែនការឃោរឃៅ កម្រោល និងឧក្រិដ្ឋ។ វាជាផែនការកសាងកសិកម្ម តាមរយៈការជម្លៀសដោយបង្ខំ ការធ្វើបាប ការបន្តដាក់ឲ្យទៅជាទាសករ ការសម្លាប់មនុស្ស។

[១៥:៣៣:៤៩]

បន្ទាប់ពីគណៈកម្មាធិការមជ្ឈិមបានទទួល បានសម្រេចដាក់ចេញផែនការរបស់ខ្លួនរួច ខ្លួនបានផ្សព្វផ្សាយវាទៅដល់តំណាង រហូតដល់អ្នកនៅកម្រិតថ្នាក់ស្រុក ដើម្បីធានាសម្រេចឲ្យបានផែនការទាំងនេះ។ ដូច្នេះចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រៀបចំសន្និបាតធំមួយនៅទីក្រុងភ្នំពេញ។ អ្នកដែលបានចូលរួមក្នុងសន្និបាតនេះ មានលេខាមកពីគ្រប់ស្រុក តំបន់ និងភូមិភាគ និងតំណាងមកពីគ្រប់អង្គភាពយោធា។ ប៉ុន្តែសន្និបាតនេះ គឺជាសន្និបាតធំអស្ចារ្យមួយ។ សន្និបាតនេះប្រារព្ធអស់រយៈពេលប្រាំថ្ងៃ និងមានមេដឹកនាំជាច្រើនរូប មកពីគ្រប់កម្រិតនៃបក្សកុម្មុយនីស្តកម្ពុជា និងនៅទូទាំងប្រទេសបានមកចូលរួម។ កិច្ចប្រជុំនេះ គឺជាទីកន្លែងដែលមជ្ឈិមបក្សចេញបញ្ជាឲ្យអនុវត្តមាគ៌ារបស់បក្សសម្រាប់ក្រោយថ្ងៃជ័យជម្នះ។ អ្នកឧទ្ទេសនាមនៅអង្គសន្និបាតមាន ប៉ុល ពត និង នួន ជា។ ពួកគេទាំងពីរបានណែនាំកម្មាភិបាលបក្សកុម្មុនីស្តកម្ពុជាឲ្យបានជ្រាបអំពីមាគ៌ារបស់បក្ស និងគោលនយោបាយដែលត្រូវអនុវត្តនៅទូទាំងប្រទេស។

កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាម្នាក់ដែលមានវត្តមាននៅក្នុងសន្និបាតនៅគឺសាក្សី សៅ សារុន ដែលកាលនោះគាត់ធ្វើជាលេខាស្រុកមួយនៅក្នុងខេត្តមណ្ឌលគីរី គាត់បានផ្តល់សក្ខីកម្មថា ប្រធានបទដែល ប៉ុល ពត និង នួន ជា ពិភាក្សានៅពេលនោះរួមមាន ការរៀបចំសហករណ៍ ការហាមមិនឲ្យចាយលុយ បិទទីផ្សារ និងវត្តអារ៉ាម។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានទទួលការណែនាំជាពិសេសឲ្យរៀបចំសហករណ៍នៅក្នុងតំបន់របស់ពួកគេ ដោយក្នុងមួយសហករណ៍ត្រូវរៀបចំឲ្យមានមនុស្សចាប់ពី ៣០ ទៅ៤០គ្រួសារ។ ពួកគេទទួលដំណឹងថា មជ្ឈិមបក្សបាន ប្រកាសលុបបំបាត់ចោលកម្មសិទ្ធិឯកជនឲ្យអស់។ ប៉ុល ពត បាននិយាយអំពីការបណ្តេញយួនចេញឲ្យអស់ពីកម្ពុជា។ នៅក្នុងខែសីហា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍ បានធ្វើទស្សនកិច្ចរយៈពេលប្រាំថ្ងៃ នៅភូមិភាគពាយ័ព្យ។ កំណត់ហេតុនៃទស្សនកិច្ចនេះបង្ហាញថា មេដឹកនាំបក្សបានទទួលរបាយការណ៍ស្តីពីសភាពការណ៍ប្រជាជន សភាពការណ៍ខ្មាំង (សកម្មភាពនៅព្រំដែន និងសកម្មភាពនៅខាងក្នុង) សភាពការណ៍យោធាយើង និងសភាពការណ៍ដំណាំស្រូវ និងឧស្សាហកម្មផ្សេងទៀត។ ឯកសារនេះឆ្លុះបញ្ចាំងអំពីវិធីដែលមេដឹកនាំបក្សតាមដានមើលការអនុវត្ត គោលនយោបាយកម្ទេចខ្មាំង។ ក្នុងកំណត់ហេតុនេះបានរៀបរាប់ថា៖ “ខាងក្នុងជួរយើង ដែលសម្រិតសម្រាំងមិនទាន់អស់ក៏នៅមាន។ វាប្រើប្រាស់ពួកនេះ ឲ្យនាំប្រជាជនរត់។ យើងចាប់វាបានជាបន្តបន្ទាប់ ហើយកំពុងបន្តរាវរកវាទៀត” ។

[១៥:៣៧:៣៦]

គណៈកម្មាធិការអចិន្ត្រៃយ៍ បានសិក្សាបទពិសោធន៍ ពីដំណើរទស្សនកិច្ចនេះថា "ប្រជាជនថ្មី" នៅភូមិភាគពាយ័ព្យ "មានការខ្វះខាត ខ្វះស្បៀងផង ខ្វះថ្នាំសង្កូវផង"។ ចំណុចនេះសំខាន់ដោយសារនៅក្នុងនេះ លោក និង លោកស្រីចៅក្រម ពិនិត្យមើល គណៈកម្មាធិការអចិន្ត្រៃយ៍ បានបញ្ជាក់នៅក្នុងរបាយការណ៍របស់ខ្លួនថា ប្រជាជននៅភូមិភាគពាយ័ព្យពុំមានអាហារគ្រប់គ្រាន់សម្រាប់ហូបនោះទេ។ ក្រុមមេធាវីការពារក្តី ចង់ឲ្យលោក លោកស្រីចៅក្រមជឿជាក់ថា ថ្នូរដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានទទួលការបោកបញ្ឆោតពីថ្នាក់ក្រោមៗរបស់ខ្លួន នៅតាមសហករណ៍អំពីសភាពការណ៍ពិតប្រាកដនៅតាមកន្លែងទាំងនោះ។ ប៉ុន្តែរបាយការណ៍នេះ បានបង្ហាញឲ្យយើងឃើញផ្សេងពីការលើកឡើងនេះ។ របាយការណ៍នេះក៏បានបង្ហាញអំពីការដឹងឮរបស់មជ្ឈិមបក្ស ដែលមាន ដែលបានបញ្ជូនប្រជាជនកន្លះលាននាក់ដោយបង្ខំទៅកន្លែងដែលកំពុងខ្វះខាតអាហារ។ របាយការណ៍បង្ហាញឲ្យឃើញថា ទោះបីជាប្រជាជនថ្មីនៅភូមិភាគពាយ័ព្យកំពុងរងទុក្ខយ៉ាងខ្លាំងក៏ដោយ ក៏ប្រជាជនមូលដ្ឋាន បើធៀបគ្នា ឃើញថាមានស្ថានភាពប្រសើរជាង។ ចំពោះប្រជាជនមូលដ្ឋាន "ជីវភាពរស់នៅពុំទាន់មានការខ្វះខាតនៅឡើយទេ" ដោយសារមជ្ឈិមបក្សបានចេញសេចក្តីណែនាំថា ប្រជាជនមូលដ្ឋានបន្តផ្គត់ផ្គង់ជយភណ្ឌ សង្គ្រាម ដែលបានមកពីទីក្រុងនិងទីប្រជុំជន ដែលពីមុនក្រុង និងទីរួមខេត្តទាំងនេះត្រូវបានគ្រប់គ្រងដោយប្រជាជនថ្មី។

[១៥:៣៩:៣៤]

ក្រោយពីទស្សនកិច្ចរបស់ខ្លួននៅភូមិភាគពាយ័ព្យ គណៈកម្មាធិការអចិន្ត្រៃយ៍បានចេញសេចក្តីសម្រេច និងផ្តល់ការណែនាំជាច្រើន ក្នុងនោះសេចក្តីសម្រេចសំខាន់បំផុត គឺជម្លៀសប្រជាជនថ្មីយ៉ាងច្រើនទៅភូមិភាគឧត្តរ និងពាយ័ព្យ។ ត្រូវចែកកម្លាំងដែលមានដីទំនេរឲ្យបង្កបង្កើនផលផង ការពារប្រទេសផង។ ម្យ៉ាងទៀត ត្រូវប្រមូលកម្លាំងនៅកន្លែងណា ទៅកន្លែងណា ដែលមានលទ្ធភាពជាងគេ។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចត្រូវតែបង្កើតកម្លាំងពលកម្មនៅក្នុងតំបន់នោះ ដោយបានបញ្ជាក់ថា៖ "៣ ឬ ៤០០.០០០ទៀតក៏មិនគ្រប់។ កម្លាំង១លាននាក់បច្ចុប្បន្ន ធ្វើបានត្រឹមតែ ៥០ ភាគរយទេ។ ត្រូវថែម ៤ ឬ ៥០០.០០០ទៀត"។

នៅក្នុងឯកសារនេះ ជាថ្មីម្តងទៀត មជ្ឈិមបក្សធ្វើជាអត្ថិភាពផែនការរបស់ខ្លួនក្នុងការបន្តធ្វើទុក្ខបុកម្នេញដល់ប្រជាជនថ្មី ដើម្បីដាក់ទណ្ឌកម្មលើសមាសភាពមិនល្អក្នុងចំណោមពួកខ្លួន។ ពាក្យពេចន៍

របស់គណៈកម្មាការនោះមានលក្ខណៈច្បាស់លាស់និងគួរឲ្យព្រឺផ្អឹងខ្នង។

"តួនាទីក្រោយពេលរំដោះទាំងស្រុង៖ សហករណ៍ស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់ ពិសេសក្រុងភ្នំពេញភ្នំពេញ ហើយនៅពាយ័ព្យគឺបាត់ដំបង។ ប្រជាជនថ្មីរាបសែននាក់នៅបាត់ដំបងមានសភាពអាក្រក់គ្រប់យ៉ាង តែសហករណ៍ស្រូបយកអស់។ ប្រជាជនចាស់មិនអីទេ តែប្រយ័ត្នសមាសភាពមិនល្អក្នុងប្រជាជនថ្មី វាឆ្លៀតឱកាស ព្រោះពួកអាក្បត់នេះ បើទុកវាយើងឲ្យវាគ្រប់គ្រាន់(ពីរកំប៉ុង) ក៏វាមិននៅដែរ"។

[១៥:៤១:៤៨]

លោក លោកស្រីចៅក្រម! ភស្តុតាងបង្ហាញច្បាស់ថា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គឺដើម្បីជម្លៀសប្រជាជនពី៤ ទៅ៥០០.០០០នាក់។ ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា "ខ្លឹមសារនៃភស្តុតាងនេះ មានបញ្ជាក់អ្វីក្រៅពីសេចក្តីប្រាថ្នាបែបស្រពេចស្រពិលមួយតែប៉ុណ្ណោះ"។ ប៉ុន្តែដូចលោក លោកស្រីចៅក្រមបានឃើញភស្តុតាងនានានៅក្នុងការជំនុំជម្រះក្តីនេះរួចហើយ គឺគណៈកម្មាធិការអចិន្ត្រៃយ៍មិនមែនជាស្ថាប័នមួយដែលចាប់អារម្មណ៍នឹងការបញ្ចេញទ្រឹស្តីនោះឡើយ។ កាលណាគណៈកម្មាការអចិន្ត្រៃយ៍ ឬមជ្ឈិមបក្សចេញបញ្ជាឲ្យដាក់វិធានការដាច់ខាតអ្វីមួយ វិធានការនោះត្រូវតែអនុវត្តនៅទូទាំងរចនាសម្ព័ន្ធរបស់បក្ស។

ជាការពិតណាស់ ភស្តុតាងដែលរឹងមាំងបំផុតពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី២នេះ គឺព្រឹត្តិការណ៍ដែលបានកើតឡើងនោះឯង។ ពួកគេបានបញ្ជាឲ្យមានការជម្លៀស បន្ទាប់មកការជម្លៀសក៏កើតមានឡើង។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ដែរមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចែកចាយឯកសារគោលនយោបាយមួយដែលពិភាក្សាអំពីការអនុវត្តនូវមាគ៌ាកសិកម្មរបស់បក្សដើម្បីជំរុញកសិកម្មនេះ ឲ្យបានចម្រើនលោតផ្លោះជាអតិបរមាតាមទិសណែនាំរបស់បក្ស។ ហើយដែលបានវាយសភាពការណ៍ក្នុងរយៈ ពេលបួនទៅប្រាំខែកន្លងមកនេះ។ ក្រោយពីបក្សផ្សាយមាគ៌ានេះ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ឯកសារនេះគូសបញ្ជាក់ថា "អំពីសារៈសំខាន់នៃការលើកទំនប់ភ្លឺស្រែនិងជីកប្រឡាយសម្រាប់ប្រែជនបទ ដោយលើកឡើងថា ភ្លឺធ្វើ "គ្នាច្រើន" និង "ដោយដៃ"។ ការនេះ ធ្វើឲ្យសេចក្តីសម្រេចរបស់គណៈកម្មាការអចិន្ត្រៃយ៍អនុវត្តបានប្រសិទ្ធភាព។ ក្នុងការជម្លៀសប្រជាជនកន្លះលាននាក់ទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។ ក្នុងឯកសារនេះ មជ្ឈិមបក្សបានពិភាក្សាអំពីផែនការកំណត់នៃទិន្នផលស្រូវឲ្យបានបីតោនក្នុងមួយហិកតា។ ហើយចាំបាច់ត្រូវនាំចេញអង្ករដើម្បីបង្កើនទុន។

[១៥:៤៤:៣៥]

ឯកសារចុះខែកញ្ញា ឆ្នាំ១៩៧៥ បង្ហាញថាមេដឹកនាំបក្សដឹងឮអំពីការខ្វះខាត់ខាងជីវភាពសព្វគ្រប់រួមមាន កង្វះខាតទាំងសម្ភារៈបង្កបង្កើនផល ការខ្វះខាតថ្នាំសង្កូវ នាំឲ្យឈឺថ្កាត់ស្គមស្គាំង និងជំងឺគ្រុនចាញ់។ ឯកសារទទួលស្គាល់ផងដែរថា ប្រជាជនខាតខ្លាំងណាស់ -- ខ្វះខាតខ្លាំងណាស់ គឺពួកដែលជម្លៀសចេញពីទីក្រុង និងទៅនៅជុំវិញភ្នំពេញ។ ឯកសារនេះក៏បានកត់ត្រាទុកការដឹងឮរបស់មេដឹកនាំថា "ប្រជាជនធ្វើការងារ១៥ម៉ោងក្នុងមួយថ្ងៃ ដោយសារពុំមានគ្រឿងម៉ាស៊ីនគ្រប់គ្រាន់ នាំឲ្យប៉ះពាល់ដល់សុខភាពប្រជាជនយើង"។

លោក លោកស្រីចៅក្រម! យើងសូមបង្ហាញថា កំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ខែសីហា ឆ្នាំ១៩៧៥ និងឯកសារគោលនយោបាយចុះខែកញ្ញា ឆ្នាំ១៩៧៥ ដោយអានរួមគ្នា។ ឯកសារទាំងពីរនេះបញ្ជាក់អំពីសេចក្ដីសម្រេចមានខ្លឹមសារ ហើយទទួលស្គាល់អំពីកង្វះខាតធ្ងន់ធ្ងរដែលធ្វើឲ្យប្រជាជនថ្មីរងគ្រោះ។ ឯកសារទាំងពីរនេះក៏ទទួលស្គាល់ផងដែរថា មេដឹកនាំបក្សបានដឹងច្បាស់អំពីស្ថានភាពបែបនេះ និងបានកត់ទុកថាការដឹកនាំរបស់គណៈកម្មាធិការមជ្ឈិមបក្សបានកំណត់ការជម្លៀសដោយបង្ខំលើកទី២។ ឯកសារនេះបញ្ជាក់ថា៖ "នៅពាយ័ព្យត្រូវការបន្ថែមកម្លាំង ៥០០.០០០នាក់ទៀត ខេត្តព្រះវិហារស្នើ៥០.០០០ ចំពោះមុខសិន។ នៅព្រះវិហារមានលទ្ធភាពដោះស្រាយស្បៀងបាន ព្រះវិហារមានប្រជាជនចាស់ ៧០.០០០នាក់ហើយ ដូច្នេះបណ្ដើរៗជូន ២០.០០០សិន។ នៅឧត្តរក៏ត្រូវការប្រជាជនផ្ដល់ឲ្យខេត្តកំពង់ធំ។ បូព៌ាក៏ត្រូវការកម្លាំងសម្រាប់ផ្ដល់ឲ្យតំបន់ដែលខ្វះខាតប្រជាជន។ ដូច្នេះភូមិភាគនីមួយៗត្រូវរៀបចំឲ្យសមស្រប កុំឲ្យឃ្លោងម្ខាងៗ លៃលកប៉ុន្មានខាងលើ និងដកយកទៅចែកកន្លែងផ្សេងៗទៀត"។

[១៥:៤៧:១៦]

លោក លោកស្រីចៅក្រមជាទីគោរព! អត្ថបទដែលខ្ញុំលើក ដកស្រង់មកអានអម្បាញ់មិញនេះសំដៅពិសេសទៅលើភូមិភាគឧត្តរ ភូមិភាគបូព៌ា ដែលត្រៀមទទួល និងបញ្ជូនមនុស្ស។ នៅក្នុងពេលសមស្របនេះ ខ្ញុំ និងសារទូរលេខដែលបានបញ្ជូននៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ បាននិយាយពីការលំបាកដែលភូមិភាគទាំងពីរនេះបានជួបប្រទះក្នុងការបញ្ជូនប្រជាជនជាច្រើន និងនិយាយអំពីភូមិភាគទាំងពីរនេះក្រោមការដឹកនាំរបស់មជ្ឈិមបក្ស។

ឯកសារភស្តុតាងសហការបញ្ជាក់អំពីចំណាត់ការរបស់មជ្ឈិមបក្ស ដើម្បីបង្កើនផលស្រូវឲ្យបាន

លឿនតាមរយៈការប្រើកម្លាំងពលកម្មដោយបង្ខំ។ ចំណាត់ការនេះ គឺជាប់ពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់បក្សក្នុងការអនុវត្តផែនការជម្លៀសប្រជាជនដំណាក់កាលទី២។ ទស្សនាវដ្ដីទង់បដិវត្តចុះខែតុលា ខែវិច្ឆិកា ១៩៧៥ បញ្ជាក់ថា ផែនការផលិតស្រូវរបស់បក្សបីតោនក្នុងមួយហិកតាត្រូវបានសម្រេចនៅក្នុងសន្និបាទសេដ្ឋកិច្ចរបស់បក្សទូទាំងប្រទេសលើកទី១ នៅដើមខែវិច្ឆិកា ឆ្នាំ១៩៧៥។ ភាសាដែលយើងប្រើប្រាស់នៅក្នុងនោះបានបង្ហាញយ៉ាច្បាស់ថា ផែនការបីតោនក្នុងមួយហិកតាគឺ “ជាសេចក្ដីសម្រេចធម្មតារបស់បក្សទាំងមូល របស់ប្រជាជនទាំងមូល និងកងទ័ពបដិវត្តន៍ទាំងមូល”។

ភស្តុតាងទាំងឡាយដែលបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា សេចក្ដីសម្រេច និងបទបញ្ជាទាំងនេះត្រូវបានបញ្ជូនតាមឋានានុក្រមអំណាចក្នុងអង្គការលេខរបស់បក្សកុម្មុយនីស្តកម្ពុជារហូតដល់ថ្នាក់ក្រោមបំផុតរបស់បក្ស។ ភស្តុតាងទាំងនេះត្រូវបានបញ្ជាក់បន្ថែមដោយសក្ខីកម្មរបស់ជនរងគ្រោះដែលបានពិពណ៌នាអំពីរបៀបដែលកម្មាភិបាលខ្មែរក្រហមបានពន្យល់អំពីអ្វីដែលជនរងគ្រោះបានដឹងតាមរយៈកម្មាភិបាលរបស់ខ្មែរក្រហម។

លោក លោកស្រីចៅក្រម ប្រាកដជាអាចកត់សម្គាល់ឃើញច្បាស់ថា មូលហេតុទាំងនោះដូចគ្នាបេះបិទនឹងបញ្ជាពីមជ្ឈិមបក្ស។ នៅខេត្តកណ្ដាល នៅក្នុងភូមិភាគនិរតី ខ្មែរក្រហមបានប្រាប់លោកស្រី TCCP-45ថា “គេយកយើងទៅខេត្តបាត់ដំបង ព្រោះដីនៅទីនោះមានជីវជាតិជាង និងមានដីសល់ទំនេរច្រើនសម្រាប់បង្កបង្កើនផល”។ នៅខេត្តស្វាយរៀង ក្នុងភូមិភាគបូព៌ា កម្មាភិបាលខ្មែរក្រហមបានប្រាប់សាក្សីដែលបានសម្ភាសនៅក្នុងឯកសារ E3/5258 នៅឯកិច្ចប្រជុំថ្នាក់ភូមិមួយសម្រាប់ប្រជាជនថ្មីថា “ផ្អែកតាមមាគ៌ា មហាលោតផ្លោះ មហាអស្ចារ្យ” មិត្តបងប្រជាជនថ្មីទាំងអស់ត្រូវតែទៅរស់នៅក្នុងខេត្តពោធិសាត់។ តាមរយៈភស្តុតាងទាំងនេះ លោក-លោកស្រីចៅក្រម វាមិនមែនដូចអ្វីដែល នួន ជា បានអះអាងក្នុងសេចក្ដីសន្និដ្ឋានបិទការដេញដោលរបស់ខ្លួនដែលថា បទបញ្ជាឲ្យជម្លៀសប្រជាជនចេញដោយបង្ខំនោះ មិនមែនចេញមកពីមជ្ឈិមបក្សទេ។ ជាការពិត ភូមិភាគជាអ្នកធ្វើ ប៉ុន្តែធ្វើជាឧបករណ៍ដើម្បីអនុវត្តផែនការបក្សនោះឯង។

[១៥:៥១:១៣]

នៅក្នុងសេចក្ដីសន្និដ្ឋានបិទការពិភាក្សាដេញដោល មេធាវីការពារក្ដី ខៀវ សំផន បានអះអាងថា ការជម្លៀសប្រជាជនដោយបង្ខំទៅកាន់ភូមិភាគដែលដីមានជីវជាតិ បង្ហាញថា មានហេតុផលសេដ្ឋកិច្ចមួយដើម្បីបញ្ជាក់អំពីការជម្លៀសនេះ។ មេធាវីការពារក្ដីបាននិយាយថា៖ “ការណ៍នេះ គឺដើម្បីសម្រាល

កង្វះខាតស្បៀង ទោះបីមានកង្វះខាតនៅកន្លែងខ្លះក៏ដោយ។ ជាថ្មីម្តងទៀត ដូច នួន ជា ដែរ ខៀវ សំផន មិនបានផ្តល់ភស្តុតាងដើម្បីគាំទ្រការអះអាងនេះទេ។ ខៀវ សំផន បានអះអាងផងដែរបន្ទាប់ពីការបិទដំណើរការនីតិវិធីដេញដោលលើភស្តុតាងដែលនៅពេលនោះគាត់ដកខ្លួនមិនផ្តល់ចម្លើយមុនពេលចៅក្រម សហព្រះរាជអាជ្ញា និងមេធាវីផ្សេងៗទៀតសួរគាត់។ ប៉ុន្តែផ្ទុយទៅវិញ ការអះអាងរបស់ ខៀវ សំផន ខុសទិសដៅស្រឡះ។ ដោយមិនគិតពីអ្វីដែលជាមូលហេតុលាក់លៀមដែលមេដឹកនាំបក្សជាអ្នកដាក់ចេញផែនការជម្លៀស ភស្តុតាងបង្ហាញថា នេះជាសហឧក្រិដ្ឋកម្មទាំងអស់ ដែលមានអានុភាពទៅលើការធ្វើទុក្ខបុកម្នេញដល់ប្រជាជនថ្មី តាមរយៈឧក្រិដ្ឋកម្ម ការដាក់ឲ្យទៅជាទាសករ ការឃុំឃាំង ការសម្លាប់ ជាពិសេស ការធ្វើបាបបែបអមនុស្សធម៌។ ម្យ៉ាងទៀត គឺជាការបន្តនូវផែនការឧក្រិដ្ឋរួម។ ការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានដឹងថាការជម្លៀសប្រជាជនច្រើន ក្នុងរយៈពេលមួយខ្លីយ៉ាងដូច្នេះទៅកាន់ភូមិភាគពាយ័ព្យ អាចធ្វើឲ្យវិបត្តិខ្វះស្បៀងកាន់តែដុនដាបថែមទៀត ហើយប្រជាជនអាចស្លាប់ចៀសមិនរួច។ នេះគ្រាន់តែមិនមានស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ប្រជាជនកន្លះលាននាក់ដែលត្រូវជម្លៀស គឺជម្លៀសទៅនៅក្នុងព្រៃ។ ប្រជាជនថ្មីមិនមានជំនាញ មិនមានបទពិសោធន៍ ឬមិនមានឧបករណ៍សម្រាប់ធ្វើស្រែចម្ការ។ ថាតើមាននរណាម្នាក់អាចព្យាករបាន ប្រជាជនថ្មីអាចរស់បាន?

[១៥:៥៣:៤៦]

លោក លោកស្រីចៅក្រម ពិតណាស់ពួកគេមិនអាចរស់បានទេ។ អៀង ធីរិទ្ធ បានទទួលស្គាល់កិច្ចសម្ភាសន៍ដែលមានការថតសំឡេងមួយធ្វើឡើងកាលពីឆ្នាំ១៩៨០ ថាគាត់បានធ្វើទស្សនកិច្ចទៅពិនិត្យមើលភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៦ ក្នុងត្រីមាសទី២ ខណៈពេលដែលការជម្លៀសដោយបង្ខំដំណាក់កាលទី២ កំពុងកើតមាន។ គាត់បានសង្កេតឃើញស្ថានភាពអមនុស្សធម៌នៅតាមតំបន់នានាដែលជាទីកន្លែងប្រជាជនរាប់រយពាន់នាក់ត្រូវបានគេផ្លាស់ទីលំនៅឲ្យទៅរស់នៅទីនោះ។ លោក- លោកស្រីលើកឡើងថា -- លោកស្រីបានលើកឡើងថា៖ “នៅបាត់ដំបង ខ្ញុំបានឃើញច្បាស់ថា ពួកគេបានបង្ខំប្រជាជនទាំងអស់ឲ្យទៅធ្វើការនៅស្រែនៅឆ្ងាយពីភូមិ។ ប្រជាជនមិនមានផ្ទះស្នាក់នៅ ពួកគេទាំងអស់ផ្អាក់ខ្លួនឈើ។ ខ្ញុំឃើញនរណាក៏នៅ ធ្វើការនៅស្រែដែរនៅហាលខ្យល់ ក្រោមពន្លឺថ្ងៃ ថ្ងៃក្តៅខ្លាំងណាស់។ ខ្ញុំបានឃើញប្រជាជនស្លាប់ដោយជំងឺរាគ និងគ្រុនចាញ់”។ ជាការសំខាន់ដើម្បីយល់អង្គហេតុនេះឲ្យបានត្រឹមត្រូវ សូមរំឭក ដំណើរទស្សនកិច្ចនេះធ្វើឡើងក្រោយប៉ុន្មានខែបន្ទាប់ពីការជម្លៀសដោយបង្ខំបានចាប់ផ្តើម។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនគ្មានជម្រក ហើយទទួលរងការវេទនា ប្រជាជនទទួល

រងទុក្ខលំបាកវេទនា ដោយសារតែពួកគេជាទាសករ ចាប់តាំងពីដំបូងមក។ មិនមានភស្តុតាងដាច់ខាតណាមួយដែលអាចដាក់នៅចំពោះមុខលោក លោកស្រីចៅក្រមថា បក្សបានចាត់វិធានការត្រឹមកម្រិតណាមួយនោះ ដើម្បីលើកកម្ពស់លក្ខខណ្ឌនៃការរស់នៅ ឬកាត់បន្ថយទុក្ខលំបាកវេទនារបស់អ្នកជម្លៀសឡើយ។

[១៥:៥៥:៥៥]

សេចក្តីសម្រេចដាច់ខាតរបស់មជ្ឈិមបក្សដាក់ចូលជាធរមាន ហើយការជម្លៀសដោយបង្ខំដំណាក់កាលទី២ បានចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥។ ភស្តុតាងបានបង្ហាញថា មានឧក្រិដ្ឋកម្មកើតឡើងជាផ្នែកមួយនៃផែនការជម្លៀសនេះ ដែលបានដំណើរការចាប់តាំងពីខែវិច្ឆិកា ឆ្នាំ១៩៧៥។

លោកប្រធាន ម៉ោងខ្ញុំឃើញជិតដល់ តើខ្ញុំត្រូវបន្តទៀត ព្រោះខ្ញុំត្រូវការប្រហែលជា២០នាទីទៀតកន្លះម៉ោងទៀតចប់ ឬមួយចាំស្អែកព្រឹក ព្រោះខ្ញុំមើលទៅម៉ោងដូចម៉ោងបួនដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មិនអាចបន្តវែងឆ្ងាយបានទេ បើត្រូវធ្វើថ្ងៃស្អែកទៀតក៏ធ្វើចុះ។ បាទ អរគុណលោកជំទាវសហព្រះរាជអាជ្ញាជាតិ។

បាទ ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការ

សម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី១៨ ខែតុលា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី ហើយនិងសាធារណជនឲ្យបានជ្រាបផងដែរថានៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនបន្តទៀត។ ហេតុដូច្នេះសូមភាគី និងសាធារណជនជ្រាប និងសូមអញ្ជើញចូលរួមឲ្យបានមុនម៉ោងកំណត់។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញ ដោយលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកត្រឹមបន្ទប់ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ចូលមករួមសវនាការផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៨ នាទី)*